EN15

# ទស្សនាវដ្ដី បរិស្ថាន




លេខ ១២ ខែ កក្កដា ឆ្នាំ ២០០៤

# មាតិកា



I-លិខិតថ្វាយព្រះពរ



II-សារលិខិតសម្តេច ហ៊ុន សែន......៣



III-សុន្ទរកថាសម្តេច ហ៊ុន សែន.......១៣




IV-សុន្ទរកថា និងសកម្មភាពឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន.......១៩



V-សុន្ទរកថាឯកឧត្តម ខាន់ សាផាន រដ្ឋលេខាធិការក្រសួងបរិស្ថាន.......៥២

បោះពុម្ពផ្សាយដោយក្រសួងបរិស្ថានតាមច្បាប់អនុញ្ញាតលេខៈ 087/01 ព.ម.ប្រ.ក ចុះថ្ងៃទី 02-03-2001
ចាងហ្វាងៈ លោក នុប និមល អនុប្រធាននាយកដ្ឋាន អប់រំ ពត៌មាននិងផ្សព្វផ្សាយបរិស្ថាន
ទូរស័ព្ទ : 012 934 558
អាសយដ្ឋាន : លេខ ៤៨ វិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ

# លិខិតថ្វាយព្រះពរ



សូមក្រាបបង្គំទូលថ្វាយ

ចំពោះ

សម្ដេចព្រះរាជអគ្គមហេសី

នរោត្តម មុនីនាថសីហនុ

ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់

**ក្នុង**ឱកាសដ៏មហានក្ខត្តឫក្ស នៃព្រះរាជពិធីចំរើនព្រះជន្មគំរប់ ៦៨ យាងចូល ៦៩ព្រះវស្សា (១៨ មិថុនា ១៩៣៩_១៨ មិថុនា ២០០៨) របស់សម្ដេចព្រះរាជអគ្គមហេសី ទូលព្រះបង្គំយើងខ្ញុំ ថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងបរិស្ថានគ្រប់លំដាប់ថ្នាក់ សូមលំអោនកាយ ក្រាបថ្វាយបង្គំ គោរពប្រណម្យ ថ្វាយព្រះពរជ័យសិរីសួស្ដី វិបុលសុខមហាប្រសើរថ្វាយចំពោះ សម្ដេចព្រះរាជអគ្គមហេសី សូមទ្រង់ប្រកបដោយព្រះសុខភាពបរិបូណ៌ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីប្រថាប់គង់នៅជម្ពៃព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូងសំរាប់ប្រជានុរាស្ត្រខ្មែរ ជាកូន ជាចៅ ជាចៅទួតជ្រកកោនប្រកបដោយសេចក្ដីសុខចំរើន និងភាពសំបូរ សប្បាយរុងរឿងជានិរន្តរ៍តរៀងទៅ ។

សូមបារមីព្រះមហាស្វេត្រច្ឆត្រ និងវត្ថុសក្តិសិទ្ធិក្នុងលោកតាមបីបាច់ថែរក្សាព្រះករុណាជាអម្ចាស់ជីវិតដំកល់លើត្បូង និងសម្ដេចព្រះអគ្គមហេសីជានិច្ច ព្រមទាំងសូមទ្រង់ឈ្នះអស់មារសត្រូវគ្រប់ទិសទី ហើយសូមព្រះករុណាទ្រង់ប្រថាប់គង់នៅសោយរាជសម្បត្តិជាអង្វែងតទៅ ។

# អារម្ភកថា

សតវត្សទី២១ ត្រូវបានអង្គការកម្មវិធីបរិស្ថានសហប្រជាជាតិប្រសិទ្ធនាមថាជា "**សហាសវត្សបរិស្ថាន**" ហើយឆ្នាំនេះ ជាឆ្នាំទី១១ ដែលក្រសួងបរិស្ថានបានបំពេញបេសកកម្មជាប្រវត្តិសាស្ត្រក្នុងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ។ ប្រាកដណាស់បេសកកម្មដែលមានវិសាលភាពធំធេងនេះក្រសួងបរិស្ថានម្នាក់ឯងមិនអាចបំពេញបានជោគជ័យឡើយ ។

ក្រសួងបរិស្ថានទទួលស្គាល់ថា រាល់សមិទ្ធផលដែលក្រសួងសំរេចបាន គឺជាស្នាដៃរបស់ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ពិសេសគឺ ការចូលរួមពីស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងកងកម្លាំងប្រដាប់អាវុធគ្រប់ផ្នែក ព្រមទាំងអាជីវករ ពាណិជ្ជករ និងការជួយគាំទ្រពីមជ្ឈដ្ឋានអន្តរជាតិ និងពីរដ្ឋាភិបាលនៃប្រទេសជាមិត្ត ។

ដំណាក់កាលដំបូងនៃការចាប់បដិសន្ធិក្រសួងបរិស្ថាន មន្ត្រីក្រសួងបរិស្ថានធ្វើការក្នុងលក្ខណៈរៀនសូត្រផង និងធ្វើការដកពិសោធន៍ផង តែជាជំហានៗ ហើយក្នុងពេលបច្ចុប្បន្ននេះ មន្ត្រីទាំងនោះមានការយល់ដឹង និងមានលទ្ធភាពបំពេញភារកិច្ចក្នុងកិច្ចការពារបរិស្ថានបានទទួលលទ្ធផលគួរជាទីមោទនៈ ។

តែទោះបីយ៉ាងដូច្នេះក៏ដោយក៏ក្រសួងបរិស្ថាននៅជួបឧបសគ្គជាច្រើនទៀតក្នុងការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិអោយមានដំណើរការប្រព្រឹត្តិទៅដោយ និរន្តរភាពក្នុងការអភិវឌ្ឍន៍ដើម្បីស្តារសេដ្ឋកិច្ចជាតិឡើងវិញ និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនព្រោះនៅមានជនខិលខូចជាជនឱកាសនិយមមួយក្តាប់តូចលួចធ្វើអាជីវកម្មបំផ្លាញធនធានធម្មជាតិ ដែលក្នុងនោះបញ្ហាលេចធ្លោជាងគេគឺ ធនធានព្រៃឈើដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន និងបក្សពួកខ្លួនដែលជាអាទិពេលថ្មីៗនេះគឺការធ្វើអាជីវកម្មឈើបែបអានាធិបតេយ្យនៅតំបន់កន្ទុយនាគ ក្នុងដែនឧទ្យាន ជាតិវីរៈជ័យ ខេត្តរតនគីរី ដែលជាតំបន់ត្រូវអភិរក្ស ។

ក្រសួងបរិស្ថានមានការសោកស្តាយណាស់ចំពោះទង្វើរបស់ជនដែលខ្វះមនសិការស្នេហាជាតិ និងស្នេហាបរិស្ថាន មួយក្តាប់តូចនោះ ។ ទង្វើរបស់ពួកគេទាំងនោះជាហេតុនាំអោយប៉ះពាល់ដល់បញ្ហាសន្តិសុខស្បៀងដែលជាកង្វល់របស់រាជ រដ្ឋាភិបាល មានសម្តេច **ហ៊ុន សែន** ជាប្រមុខ ព្រមទាំងរបស់មុនស្សជាតិ ។ ព្រោះការធ្វើអោយបាត់បង់លំនឹងបរិស្ថាននាំអោយមានផលប៉ះពាល់ធនធានជីវៈចំរុះជាប្រភពស្បៀងអាហារ និងជាប្រភពវត្ថុធាតុដើមផ្សេងៗទៀត ។ បើធនធានជីវៈចំរុះត្រូវបំផ្លាញសេចក្តីស្រេកឃ្លាននឹងកើតមានឡើងព្រមជាមួយសេចក្តីទុក្ខវេទនាផ្សេងៗទៀត ។

លោក KAMALA MARKANDAYA បានមានប្រសាសន៍ថា "*ការស្រេកឃ្លានឬសេចក្តីស្រេចឃ្លានវាជារឿង មួយគួរអោយឆ្ងល់ណាស់ ។ បើមានសេចក្តីស្រេកឃ្លាន នោះការឈឺចាប់វានៅជាមួយយើងគ្រប់ពេលទាំងពេលយើងធ្វើការ ទាំងពេលយើងចូលនិទ្រា ព្រមទាំងពេលយើងយល់សប្តិផងដែរ ។ ចំណែកពោះយើងវិញវាស្រែកថ្ងូរយ៉ាងរីងរូស ហើយវាបណ្តាលអោយកើតមានការកកេរខ្វាំនិងការឈឺចាប់ ហាក់បីដូចជាជីវិតយើងត្រូវបានបំផ្លាញ ។ យើងអាចបញ្ឈប់វាបានទាល់តែយើងត្រូវចំណាយក្នុងតម្លៃណាមួយ..... ។ ក្រោយនោះការឈឺចាប់វាមិននៅខ្លាំងក្លាទៀតទេ តែវានៅបន្តការឈឺស្ពឹកៗ ។ ប៉ុន្តែវា ស្ថិតនៅជាមួយយើងជានិច្ច ។*"

នេះសរបញ្ជាក់ថា សេចក្តីស្រេកឃ្លានវាមានទំហំធំធេងណាស់ ហើយមានតែអ្នកធ្លាប់ជួបប្រទះសេចក្តីស្រេកឃ្លានទេទើបអាចយល់បានច្បាស់ពីសេចក្តីស្រេកឃ្លាននោះ វាឈឺចាប់ប៉ុណ្ណា ។

ដូច្នេះចូរនាំគ្នាការពារ គាំពារបរិស្ថានធម្មជាតិ ព្រមទាំងរាល់ការធ្វើអាជីវកម្មធនធានធម្មជាតិត្រូវធានានិរន្តរភាពបរិស្ថាន ដើម្បីរក្សាសន្តិសុខស្បៀងសំរាប់ប្រជាពលរដ្ឋខ្មែរ និងសំរាប់មនុស្សជាតិ ដូចការអំពាវនាវរបស់អង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ ដែលកំណត់យកសតវត្សទី២១ ជាសហសវត្សបរិស្ថាន ។

**ក្រសួងបរិស្ថាន**

សម្ដេច **ហ៊ុន សែន**

*នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា*

## សារលិខិត

## របស់ សម្ដេច ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា



មូលដ្ឋានគ្រឹះនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន គឺការបន្តអនុវត្តន៍កំណែទំរង់គ្របវិស័យឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅឆ្ពោះទៅមុខថែមទៀត ។ កិច្ចការទាំងនេះត្រូវពួតផ្ដុំចូលគ្នាជាប្រព័ន្ធតែមួយ ប្រទាក់ក្រឡាគ្នា និងយោងគ្នាទៅវិញទៅមក ក្នុងគោលដៅនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចិរភាព សំដៅកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន ។

ជាមួយគ្នានោះ ភារកិច្ចដែលយើងកំពុងតែបំពេញនេះ ស្ថិតក្នុងយុគសម័យមួយដែលពិភពលោកកំពុងតែផ្ដោតការយកចិត្តទុកដាក់អំពីការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងសុវត្ថិភាពបរិស្ថាន ។ ក្នុងនោះកិច្ចការពារស្រទាប់អូសូន គឺជាភារកិច្ចមួយដ៏មានសារៈសំខាន់ និងចាំបាច់ជាបន្ទាន់ផងដែរ ។

ក្នុងក្របខ័ណ្ឌនយោបាយថ្នាក់តំបន់ រាជរដ្ឋាភិបាលបានកំណត់ជំហររបស់ខ្លួនយ៉ាងប្រត្យក្ស ក្នុងការចូលរួមកិច្ចសហប្រតិបត្តិការផ្នែកបរិស្ថានជាមួយបណ្តាប្រទេសក្នុងសហគមន៍អាស៊ាន ក៏ដូចជាក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកទាំងមូលផងដែរ ។ ក្នុងនាមជាភាគីហត្ថលេខីមួយនៃអនុសញ្ញាវីយែនស្តីពីកិច្ចការពារស្រទាប់អូសូន និងពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុដែលបំផ្លាញស្រទាប់អូសូន រាជរដ្ឋាភិបាលបានសំដែងការគាំទ្រយ៉ាងពេញទំហឹងចំពោះជំហររបស់បណ្តាប្រទេសដែលជាសមាជិកនៃអនុសញ្ញានេះ ។

រាជរដ្ឋាភិបាលសូមស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះការរៀបចំ **«កម្មវិធីជាតិស្តីពីផែនការគ្រប់គ្រងសារធាតុត្រជាក់»** ដោយបានរំលេចឡើងនូវបញ្ហាយ៉ាងច្បាស់លាស់ ដែលទាក់ទងនឹងការប្រើប្រាស់សារធាតុត្រជាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង និងបានផ្តល់នូវកម្មវិធីជាយុទ្ធសាស្ត្រ សំរាប់ការដោះស្រាយបញ្ហាទាំងនេះ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលសូមប្រកាសជាឱឡារិកក្នុងការគាំទ្រកម្មវិធីជាតិស្តីពីផែនការគ្រប់គ្រងសារធាតុត្រជាក់ ដែលក្រសួងបរិស្ថានបានរៀបចំឡើង ដោយមានការចូលរួមសហការពីក្រសួងស្ថាប័ន-ពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិនានា ។ ជាការពិត កម្មវិធីជាតិនេះនឹងណែនាំដល់អង្គការ និងស្ថាប័នទាំងអស់ ឱ្យផ្តោតការយកចិត្តទុកដាក់ចំពោះការប្រែប្រួលអាកាសធាតុ ដោយសារការធ្លុះធ្លាយស្រទាប់អូសូន ដែលបណ្តាលមកពីការប្រើប្រាស់សារធាតុដែលបំផ្លាញស្រទាប់អូសូន ។

ខ្ញុំសូមយកឱកាសនេះ ដើម្បីសំដែងនូវការកោតសរសើរ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកម្មវិធីបរិស្ថានសហប្រជាជាតិ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងមូលនិធិពហុភាគី ព្រមទាំងក្រសួង- ស្ថាប័ន អង្គការជាតិ និងអន្តរជាតិទាំងអស់ ដែលបានជួយឧបត្ថម្ភ និងគាំទ្រយ៉ាងអស់ពីចិត្តពីថ្លើមទាំងផ្នែកមូលនិធិ និងបច្ចេកទេស ដើម្បីស្រាវជ្រាវ និងរៀបចំកម្មវិធីជាតិដ៏មានសារៈសំខាន់នេះ សំរាប់មាតុភូមិយើង ។ ជាការពិតណាស់ ឯកសារនេះនឹងជួយជាវិភាគទាន ក្នុងការរួមចំណែកការពារ និងថែរក្សាស្រទាប់អូសូននៅលើភពផែនដីយើងឱ្យមានភាពល្អប្រសើរឡើង ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០០៤

**ហ៊ុន សែន**



# សម្ដេច ហ៊ុន សែន

*នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា*

## សារលិខិត

**សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា**

**ថ្លែងក្នុងឱកាសអបអរសាទរទិវាបរិស្ថានជាតិ និង បរិស្ថានពិភពលោក**

**ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០០៤**

*- សូមក្រាបថ្វាយបង្គំសម្ដេចព្រះសង្ឃរាជទាំង ២ គណៈ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*- ឯកឧត្ដម លោកជំទាវ លោក លោកស្រី*

*- បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា*

ថ្ងៃទី ៥ មិថុនា ឆ្នាំ ២០០៤ នេះ គឺជាឆ្នាំទី ១០ ហើយ ដែលប្រជាជនកម្ពុជាបានអបអរសាទរ ដើម្បីប្រារព្ធទិវាបរិស្ថានជាតិ និង បរិស្ថានពិភពលោក ។

ដើម្បីសំដែងឆន្ទៈ និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងបុព្វហេតុការពារ ថែរក្សា និងគាំពារបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា បរិស្ថានតំបន់ និងបរិស្ថានភពផែនដី ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងក្ដីសោមនស្សរីករាយ ដើម្បីថ្លែងសារទៅកាន់បងប្អូនជនរួមជាតិទាំងអស់ឱ្យបន្តមនសិការស្នេហាការចូលរួមគាំពារ និងថែរក្សាបរិស្ថាននៅកម្ពុជា ទាំងគុណភាព និងបរិមាណឱ្យបានកាន់តែល្អប្រសើរ ។

*- បងប្អូនជនរួមជាតិទីស្នេហា*

តាមគំនិតផ្ដួចផ្ដើមរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិឆ្នាំនេះ ទិវាបរិស្ថាន ៥ មិថុនា បានប្រព្រឹត្តទៅក្រោមទិសស្លោកថា «***បរិស្ថានសមុទ្រ និងមហាសមុទ្រស្អាត ឬ កខ្វក់ គឺជាជីវិតរបស់យើង***» និង «***តើយើងត្រូវធ្វើសកម្មភាពបច្ចុប្បន្ននេះដូចម្ដេច ដើម្បីថែរក្សាធនធានសមុទ្រ និងមហាសមុទ្រ ឬ ក៏យើងត្រូវមើលធនធានសមុទ្រ និងមហាសមុទ្រដ៏សំបូរបែបនេះឱ្យបន្តខូចខាត និងធាក់ចុះហូតដល់ដំណាក់កាល ដែលមិនអាចស្ដារឡើងវិញរួចនោះ ?***» ។

យើងបានដឹងរួចហើយថា ភពផែនដីជាជំរករបស់យើង ជាផ្ទះរបស់យើងដែលយើងត្រូវការពារ ។ ចំណែកសមុទ្រ និងមហាសមុទ្រ បានគ្របដណ្ដប់ផ្ទៃដី ដែលយើងកំពុងរស់នៅប្រមាណ ៧០% ។ ជាការពិតណាស់ សមុទ្រ និងមហាសមុទ្រ បានផ្ដល់នូវសារៈប្រយោជន៍មហាសាលដល់មនុស្សទូទៅ ដូចជាការផ្ដល់ប្រភពចំណីអាហារ ថ្នាំសង្កូវ វត្ថុធាតុដើម សំរាប់ជាគ្រឿងលំអ រ៉ែ ប្រព័ន្ធគមនាគមន៍ តំបន់ទេសចរណ៍ និងការស្រាវជ្រាវវិទ្យាសាស្ត្រ ។

ជាមួយគ្នានេះ គួរកត់សំគាល់ថា សកម្មភាពរបស់មនុស្សជាតិ បាន និងកំពុងធ្វើឱ្យធនធានសមុទ្រ និងមហាសមុទ្រត្រូវរេចរិលបន្តិចម្ដងៗ ហើយទឹកសមុទ្រត្រូវបំពុលដោយផ្ដើមចេញពីការកើនឡើងចំនួនមនុស្ស និងទីក្រុង តាមតំបន់ឆ្នេរ ការនេសាទហួសកំរិត ការបំផ្លាញដែនជំរកវារីជាតិ ការបង្ហូរកាកសំណល់ ការសាងសង់តំបន់ឧស្សាហកម្មតាមតំបន់ឆ្នេរ ការធ្លុះធ្លាយ និងកំពប់ប្រេងនៃជលយាន និងនាវាដឹកប្រេង ការសាងសង់កំពង់ផែ ការបង្កើតតំបន់ទេសចរណ៍ ។ ល ។ និង។ ល ។

- *បងប្អូនជនរួមជាតិជាទីស្នេហា*

តំបន់ឆ្នេរសមុទ្រកម្ពុជា ពោរពេញទៅដោយធនធានជីវៈចំរុះ និងធនធានប្រព័ន្ធអេកូឡូស៊ីជាច្រើន ដែលប្រកបដោយសក្ដានុពលដើម្បីទ្រទ្រង់ការអភិវឌ្ឍន៍សេដ្ឋកិច្ច លើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន និងជាប្រភពផ្ដល់កាងារ និងជាទីកន្លែងផ្ដល់ការដឹកជញ្ជូន ដែលទាក់ទងទៅនឹងសង្គម- សេដ្ឋកិច្ចកម្ពុជា និងតភ្ជាប់ប្រព័ន្ធគមនាគមន៍សមុទ្រទៅក្នុងក្របខ័ណ្ឌសកលលោកផងដែរ ។ ប្រជាជនកម្ពុជាជាច្រើន នៅតាមតំបន់ឆ្នេរ បាននិងកំពុងពឹងផ្អែកទាំងស្រុងលើសកម្មភាពនេសាទ ហើយក៏មានប្រជាសហគមន៍ នៅលើកោះជាច្រើនទៀតរស់នៅមានជីវិតដោយសារដីដាំដំណាំ ។ នៅពេលខាងមុខដ៏ឆាប់នេះការអភិវឌ្ឍន៍ វារីវប្បកម្ម និងកសិកម្ម ការអភិវឌ្ឍន៍ទេសចរណ៍ ការធ្វើអាជីវកម្មស្រែអំបិលនឹងកើនឡើង ដើម្បីធានាដល់ការកើនឡើងនៃប្រជាជន និងសកម្មភាពសេដ្ឋកិច្ច ។

ក្នុងក្របខ័ណ្ឌនេះ យើងអាចប្រមើលឃើញច្បាស់ថា ធនធានទាំងនោះ នឹងត្រូវទទួលការខូចខាតយ៉ាងធ្ងន់ធ្ងរ ក្នុងករណីគ្មានការអភិវឌ្ឍន៍មួយប្រកបដោយចិរភាពខាងផ្នែកបរិស្ថាន ឬ ខ្វះសមត្ថកិច្ចក្នុងការគ្រប់គ្រងធនធានធម្មជាតិមានប្រសិទ្ធភាពនោះទេ ។

ដោយសារប្រការនេះហើយ ទើបរាជរដ្ឋាភិបាលបានផ្ដោតការយកចិត្តទុកដាក់អនុវត្តគោលនយោបាយសេដ្ឋកិច្ច- សង្គមកិច្ច ដែលមានទិសដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ហើយបានផ្ដល់អាទិភាពយ៉ាងខ្ពស់ ដល់ការគ្រប់គ្រងបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព ដែលជាកត្តាគន្លឹះដ៏សំខាន់បំផុត សំរាប់ធានាតុល្យភាព និងនិរន្តរភាពនៃការអភិវឌ្ឍន៍ ដោយគិតទាំងបរិស្ថានតំបន់ឆ្នេរ និងសមុទ្រផង ។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាលក៏បានលើកឡើងនូវវិធានការដោះស្រាយជាក់ស្ដែងមួយចំនួន ដើម្បីទប់ស្កាត់ផលប៉ះពាល់ជាអវិជ្ជមានដែលកើតមាននៅលើតំបន់ឆ្នេរ និងសមុទ្រ រាប់ទាំងការរំលោភកាន់កាប់ដីធ្លីនៅតំបន់ឆ្នេរផងដែរ ។ ប្រការនេះ ទាមទារឱ្យមានការធ្វើសមាហរណកម្មកំលាំង និងស្ថាប័នពាក់ព័ន្ធ កិច្ចសហការនិងសំរបសំរួលរវាងដៃគូសាធារណៈ និងឯកជន ព្រមទាំងការចូលរួមពីសហគមន៍មូលដ្ឋានក្នុងការទទួលខុសត្រូវ និងការគួបផ្សំកំលាំងគ្នា ទាំងក្នុងថ្នាក់សហគមន៍មូលដ្ឋាន អាជ្ញាធរដែនដីខេត្ត-ក្រុង និងថ្នាក់ជាតិក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងតំបន់ឆ្នេរ ។ ទន្ទឹមនោះ ក្រសួងបរិស្ថានត្រូវផ្ដួចផ្ដើមកសាងបទដ្ឋានច្បាប់ និងគោលនយោបាយបរិស្ថានតំបន់ឆ្នេរបន្ថែមទៀត ដ៏ដូចជាការពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលទទួលខុសត្រូវក្នុងវិស័យនេះ ។

ក្នុងក្របខ័ណ្ឌអន្តរជាតិ ព្រះរាជាណាចក្រកម្ពុជា ជាសមាជិកកម្មវិធីបរិស្ថានសហប្រជាជាតិ · ហើយព្រះរាជាណាចក្រកម្ពុជា ក៏ជាហត្ថលេខីលើសន្ធិសញ្ញា និងអនុសញ្ញាធំៗជាច្រើន ក្នុងនោះរួមមានទាំងការចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិស្ដីពីការបំពុលសមុទ្រនៅឆ្នាំ ១៩៩៤ និងកិច្ចសហការថ្នាក់តំបន់ជាមួយអង្គការសំរបសំរួលសមុទ្រនៃទ្វីបអាស៊ីបូព៌ានៅឆ្នាំ ១៩៩៥ ។ ដោយឡែក ក្នុងឆ្នាំ ២០០៣ កន្លងមកនេះ យើង

ក៏បានចុះហត្ថលេខាលើសេចក្ដីប្រកាសរួមស្ដីពីកិច្ចសហការថ្នាក់តំបន់ សំរាប់ការអភិវឌ្ឍន៍ដោយចីរភាពនៅសមុទ្រអាស៊ីបូព៌ាផងដែរ ។

*- បងប្អូនជនរួមជាតិជាទីស្នេហា*

ជាមួយគ្នានេះដែរ ទន្ទឹមនឹងការយកចិត្តទុកដាក់គាំពារបរិស្ថានសមុទ្រ និងមហាសមុទ្រ យើងមិនត្រូវបំភ្លេច ឬ មើលស្រាលចំពោះកិច្ចគាំពារបរិស្ថានតំបន់ទឹកសាបទេ ដែលក្នុងនោះក៏មានបរិស្ថានបឹងទន្លេសាប ដែលជាសមុទ្រទឹកសាបមានវិសាលភាពយ៉ាងធំល្វឹងល្វើយនៅក្នុងប្រទេស ហើយក៏ជាជង្រុកត្រីដ៏ធំសំរាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ និងសន្តិសុខស្បៀងដល់ប្រជាពលរដ្ឋ ។

បច្ចុប្បន្ននេះ បរិស្ថានបឹងទន្លេសាប ក៏ជួបប្រទះនូវហេតុប៉ះពាល់ជាច្រើនដែរ ដែលកើតឡើងពីកត្តាសត្យានុម័ត និងអត្តនោម័ត ។ ឆ្នាំនេះ គឺជាការប្រកាសអាសន្នមួយដែលពុំធ្លាប់មាន គឺការខ្វះត្រីសំរាប់ធ្វើប្រហុកនៅរដូវនេសាទពេលទឹកស្រក ។ ដូច្នេះយើងត្រូវគិតគូរឱ្យបានខ្ពស់ក្នុងកិច្ចគាំពារបរិស្ថានទាំងបរិស្ថានតំបន់សមុទ្រ និងបរិស្ថានតំបន់ទឹកសាប ដែលមានទន្លេ បឹង ស្ទឹង ព្រែក ។ ល ។

ក្នុងឱកាសដ៏មានអត្ថន័យជាប្រវត្តិសាស្ត្រនេះ ខ្ញុំព្រះករុណាខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងបរិស្ថាន និងគ្រប់ក្រសួង- ស្ថាប័នរដ្ឋ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ព្រះសង្ឃគ្រប់ព្រះអង្គ ប្រជាពលរដ្ឋគ្រប់រូប និងសិស្សានុសិស្សគ្រប់ភូមិសិក្សាដែលបានចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តន៍បេសកកម្មរបស់ខ្លួនក្នុងការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈបំផុត ។ ខ្ញុំព្រះករុណាខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រទេស ជាមិត្ត អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល និងសប្បុរសជននានាដែលបានចូលរួមឧបត្ថម្ភថវិកាសំភារៈធនធានមនុស្ស ដើម្បីជួយទ្រទ្រង់ដល់សកម្មភាពគាំពារបរិស្ថានក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្នុងតំបន់ និងក្នុងសកលលោកទាំងមូលផងដែរ ។

ខ្ញុំព្រះករុណាខ្ញុំមានសង្ឃឹម និងមានជំនឿយ៉ាងមុតមាំថា នៅក្នុងសហស្សវត្សរ៍ថ្មីនេះ ពិភពលោកនឹងមានការរីកចំរើនទៅមុខប្រកបដោយចិរភាពបរិស្ថាន ។ ដោយឡែកសំរាប់ប្រទេស និងប្រជាជនកម្ពុជា បរិស្ថានជាតិនឹងត្រូវបានរក្សាឱ្យនៅស្រស់បំព្រងរហូតតរៀងទៅ ទាំងបរិស្ថានតំបន់ឆ្នេរ និងសមុទ្រ និងបរិស្ថានទឹកសាបទាំងមូល ។,

***ជយោ ! ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា ២០០៤***

***ចូរនាំគ្នាការពារបរិស្ថានសមុទ្រ និង មហាសមុទ្រឱ្យស្អាតជានិច្ច !***

*រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៤*

**ហ៊ុន សែន**

## សុន្ទរកថា
## របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ
## រាជរដ្ឋាភិបាលកម្ពុជាក្នុងពិធីសម្ពោធអគាររដ្ឋបាលព្រៃឈើ
## ( រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ )

**ក្នុងគោលបំណងរួមចំណែកផ្សព្វផ្សាយគោលនយោបាយព្រៃឈើ និងគោលនយោបាយគ្រប់គ្រងដីព្រៃឈើ របស់រាជរដ្ឋាភិបាល អោយមានដំណើរប្រព្រឹត្តិទៅដោយចីរភាព និងនិរន្តរភាពបរិស្ថាន ក្នុងការអភិវឌ្ឍន៍ និងផ្តល់ចំណេះដឹងជាសាធារណៈ ទស្សនាវដ្តីបរិស្ថាន សូមធ្វើការចុះផ្សាយទាំងស្រុង ខ្លឹមសារសុន្ទរកថាសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងពិធីសម្ពោធអគាររដ្ឋបាលព្រៃឈើ កាលពីថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០៤ ដូចតទៅ :**



**សម្តេច ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី**
**នៃរាជរដ្ឋាភិបាលកម្ពុជា**

*-សូមក្រាបថ្វាយបង្គំសម្តេចព្រះឧត្តមបញ្ញា សម្តេចព្រះឧត្តមចរិយា ព្រះតេជគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*-ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត និងឯកអគ្គរដ្ឋទូតប្រចាំព្រះរាជាណាចក្រកម្ពុជា*

*-ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ជាទីមេត្រី*

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយជាអនេកប្បការដែលបានមកចូលរួមក្នុងពិធីសម្ពោធសមិទ្ធផលថ្មីមួយទៀតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាជំនួយឧបត្ថម្ភរបស់ធានាគារពិភពលោក និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ការសាងសង់អគាររដ្ឋបាលព្រៃឈើនេះ ក៏មានការរួមចំណែកពីថវិកាសន្សំនៃប្រាក់រង្វាន់ ដែលជាវិភាគទានរបស់មន្ត្រីរដ្ឋបាលព្រៃឈើដោយផ្ទាល់បន្ទាប់ពីសម្ពោធអគារ "***មជ្ឈមណ្ឌលបណ្តុះបណ្តាល វិស័យព្រៃឈើ និងសត្វព្រៃ***" នៅសង្កាត់ភ្នំពេញថ្មីក្រោមជំនួយឧបត្ថម្ភរបស់រាជរដ្ឋាភិបាលជប៉ុន តាមរយៈអង្គការចាយកា (JICA) នៃគំរោងស្តីពី "ការពង្រឹងសមត្ថភាព វិស័យព្រៃឈើនៅកម្ពុជា" ។

ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ សូមកោតសរសើរ និងវាយតំលៃខ្ពស់ ចំពោះការខិតខំប្រឹងប្រែង របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកទាំងអស់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលសម្រេចបាននូវលទ្ធផលល្អៗ ជាបន្តបន្ទាប់នៅក្នុងដំណើរការកែទម្រង់ការគ្រប់គ្រងវិស័យព្រៃឈើ និងសត្វព្រៃនៅកម្ពុជា ។ ការប្រារព្ធនូវពិធីដ៏មហោឡារិកនាថ្ងៃនេះ គឺជាសក្ខីភាពមួយទៀតដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីភាពរីកចំរើន ក្នុងការពង្រឹង

សមត្ថភាពរបស់មន្ត្រីរាជការ បុគ្គលិកនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសរដ្ឋបាលព្រៃឈើដែលបានធ្វើដំណើរឆ្លងកាត់ដំណាក់កាលនៃកំណែទម្រង់វិស័យព្រៃឈើកន្លងមកក្នុងទិសដៅលើកស្ទួយការគ្រប់គ្រង **និងអភិវឌ្ឍន៍** ធនធានព្រៃឈើឱ្យបានប្រកបដោយចិរភាព ។

ខ្ញុំព្រះករុណា ខ្ញុំសូមឆ្លៀតយកឱកាស**នេះដើម្បីថ្លែង** អំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះរដ្ឋាភិបាល **និង** ប្រជាជននៃប្រទេស និងសហគមន៍អ្នកផ្ដល់**ជំនួយទាំងអស់** ដែលតែងតែយកចិត្តទុកដាក់ក្នុងការផ្ដល់ជំនួយ **បច្ចេកទេស** សម្ភារៈ និងហិរញ្ញវត្ថុសំរាប់ការស្ដារ **និងអភិវឌ្ឍន៍វិស័យ** ហេដ្ឋារចនាសម្ព័ន្ធសង្គមកិច្ច និងវិស័យជាច្រើនទៀតនៅព្រះរាជាណាចក្រកម្ពុជា ។

វិស័យព្រៃឈើ គឺជាអាទិភាពមួយដែលទទួលបាននូវការយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អ្នកផ្ដល់ជំនួយ ក៏ដូចជាមជ្ឈដ្ឋានសាធារណមតិជាតិ និងអន្តរជាតិជាទូទៅផងដែរ ។ ជាក់ស្ដែងអគារ ដែលទើបទទួលបាននៅចំពោះមុខយើងនេះគឺជាសមិទ្ធផលមួយនៃកិច្ចសហប្រតិបត្តិការរួមគ្នា របស់យើងទាំងអស់គ្នា ហើយជាការឆ្លុះបញ្ចាំងឱ្យឃើញផងដែរ ពីការគាំទ្រដ៏ខ្លាំងក្លារបស់សហគមន៍អ្នកផ្ដល់ជំនួយ ចំពោះរាជរដ្ឋាភិបាលកម្ពុជានៅក្នុងដំណើរការកំណែទំរង់វិស័យព្រៃឈើ ។

*-សម្ដេច ព្រះតេជគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*-ឯកឧត្ដម លោកជំទាវ លោក លោកស្រីទាំងអស់ជាទីមេត្រី*

ដូចដែលឯកឧត្ដម **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានជំរាបជូនអង្គពិធីអម្បាញ់មិញនេះ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អង្គភាពរុក្ខាប្រមាញ់បានបោះបង់ដំណើរការរបស់ខ្លួន ដូចជាស្ថាប័នផ្សេងៗទៀតដែរ ហើយធនធានមនុស្សជាមន្ត្រីបច្ចេកទេសព្រៃឈើក៏ត្រូវបានក្លាយទៅជាមុខសញ្ញាកាប់សំលាប់យ៉ាងព្រៃផ្សៃបំផុតក្នុងរបបនោះ ។ បណ្ដាឯកសារច្បាប់ និងលិខិតបទដ្ឋាន**នានា** ព្រមទាំងមធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធទាំងឡាយ**របស់វិស័យព្រៃឈើ** ក៏ត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង ។ ជា**ការពិតណាស់ការបង្កើតឡើងបានមកវិញនូវ** ធនធានមនុស្ស **និងហេដ្ឋារចនាសម្ព័ន្ធនៃស្ថាប័ន** រុក្ខាប្រមាញ់ ពីបាតដៃទទេក្រោយថ្ងៃ៧ មករា ១៩៧៩ គឺអាស្រ័យដោយឆន្ទៈ និងកិច្ចខិតខំប្រឹងប្រែងយ៉ាងប្តូរផ្ដាច់ បំផុតរបស់អតីតរដ្ឋកម្ពុជា ជាពិសេសគឺដោយស្មារតីស្នេហាជាតិ ការពុះពារ និងពលិកម្មយ៉ាងធំធេងមិនអាចកាត់ថ្លៃបានរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជ-ការទាំងអស់ក្នុងក្រសួងកសិកម្ម ក្នុងរយៈពេលកន្លងមករហូតដល់ពេលបច្ចុប្បន្ននេះ ។ ដោយសារការចងចាំមិនអាចបំភ្លេចបាននូវគុណូបការៈដ៏ថ្លៃថ្លាទាំងនេះ ខ្ញុំព្រះករុណាខ្ញុំ សូមយកឱកាសនេះដើម្បីសំដែងនូវការគោរពកោតសរសើរ យ៉ាងជ្រាលជ្រៅបំផុតចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់របស់អតីតនាយកដ្ឋានរុក្ខាប្រមាញ់នៃក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ដែលធ្លាប់បាន និងកំពុងបន្តចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការស្ដារ កសាង និងអភិវឌ្ឍន៍ស្ថាប័នដ៏មានសារៈសំខាន់នេះឡើងវិញ។

ថ្ងៃនេះ យើងទាំងអស់គ្នាមានសេចក្ដីរីករាយទទួលនូវសមិទ្ធផលថ្មីៗប៉ុន្តែយើងក៏ត្រូវហ៊ានសម្លឹងមើលទៅថ្ងៃ ស្អែក និងអនាគត ដែលតំរូវឱ្យយើងធ្វើការប្ដេជ្ញាចិត្តឥតងាករេក្នុងការបង្កើនល្បឿននៃកិច្ចការកែទំរង់វិស័យព្រៃឈើ ដោយខ្លួនឯងបន្តទៀត ដើម្បីគ្រប់គ្រង ការពារធនធានព្រៃឈើឱ្យចៀសផុតពីការបំផ្លិចបំផ្លាញនានា ដើម្បីជាប្រយោជន៍នៃជន

កម្ពុជា ជំនាន់ក្រោយៗទៀត ។ កាលពីដើមអាណត្តិទី២នៃរាជរដ្ឋាភិបាល ខ្ញុំព្រះករុណាខ្ញុំ បានប្រកាសចាប់ផ្តើមជាឱឡារិកនូវកំណែទម្រង់វិស័យព្រៃឈើដ៏ស៊ីជំរៅមួយ ប្រកបដោយប្រសិទ្ធភាព ។ ជាមួយនឹងការខិតខំប្រឹងប្រែងជាប្រចាំ និងដោយឥតងាករេ យើងទទួលបាននូវការវាយតំលៃខ្ពស់ និងការគាំទ្រពីមតិជាតិ និងអន្តរជាតិ ក្នុងនោះក៏មានធនាគារពិភពលោកផងដែរ ចំពោះកិច្ចការកែទម្រង់របស់យើង ជាពិសេសគឺការលុបបំបាត់អំពើអនាធិបតេយ្យព្រៃឈើ និងកំណែទំរង់ព្រៃសម្បទានដែលជាមូលដ្ឋានគ្រឹះសំរាប់ឈានឆ្ពោះទៅរកការគ្រប់គ្រងព្រៃឈើ ប្រកបដោយចិរភាព និងនិរន្តរភាព។

យ៉ាងណាក៏ដោយ បច្ចុប្បន្ននេះសកម្មភាពកាប់រានដុតព្រៃឈើយកដីព្រៃធម្មជាតិ និងចំការព្រៃដំណាំរបស់រដ្ឋមកធ្វើជាកម្មសិទ្ធបាន និងបន្តកើតមានឡើងជាបន្តបន្ទាប់នៅតាមបណ្តាខេត្ត-ក្រុងមួយចំនួន ដែលជាទង្វើប្រព្រឹត្តផ្ទុយនឹងច្បាប់ ផ្ទុយនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងជាឧក្រិដ្ឋកម្មព្រៃឈើ និងការខូចខាតបរិស្ថានជីវសាស្ត្ររបស់ជាតិ ។ រាជរដ្ឋាភិបាលមិនអាចព្រងើយកន្តើយ និងអត់អោនចំពោះការបំផ្លិចបំផ្លាញទាំងអស់នេះបានឡើយ ។ ដូច្នេះឆ្លៀតឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំ សូមប្រកាសបើកឡើងនូវយុទ្ធនាការរួមគ្នាប្រឆាំង នឹងការកាប់រានដុត ឈូសឆាយ និងហ៊ុំព័ទ្ធកាន់កាប់ដីព្រៃឈើ ដោយខុសច្បាប់ ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំព្រះករុណាខ្ញុំ សូមប្រកាសដាក់បទបញ្ជាឱ្យគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ កងកម្លាំង ប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវចូលរួមសហការយ៉ាងជិតស្និទ និងប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុតជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងក្រសួង បរិស្ថាន ដើម្បីបង្ក្រាប និងលុបបំបាត់ឱ្យបានដាច់ខាត និងទាន់ពេលវេលានូវការកាប់ដុត រុករានដីព្រៃឈើយកធ្វើជាកម្មសិទ្ធិនៅក្នុងទូទាំងផ្ទៃប្រទេស។ ខ្ញុំព្រះករុណាខ្ញុំក៏សូមប្រកាសព្រមានជាសាធារណៈ: ចំពោះជនទាំងឡាយណាដែលមានការពាក់ព័ន្ធនឹងបញ្ហានេះ ទោះជាអ្នកមានបុណ្យសក្តិ អំណាច ឬទ្រព្យសម្បត្តិយ៉ាងណាក្តី ត្រូវបញ្ឈប់ជាបន្ទាន់នូវទង្វើរលោភបំពានច្បាប់ទាំងអស់នេះ ហើយប្រគល់ជាបន្ទាន់នូវអតីតដីព្រៃទាំងនោះមកទុកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បីធ្វើការស្តារ ដាំដុះដើមឈើឡើងវិញ ។ ប្រសិនបើមិនដូច្នោះទេ ទោះជានរណាក៏ដោយឱ្យតែហ៊ានប្រព្រឹត្តិខុសច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាស់ជានឹងត្រូវប្រឈមមុខចំពោះវិធានការដ៏មធ្យ៉ត និងធ្ងន់ធ្ងរជាក់ជាមិនខាន ។

*-សម្តេច ព្រះតេជគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*-ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ជាទីមេត្រី*

ជាការពិតណាស់ រាជរដ្ឋាភិបាលយល់យ៉ាងច្បាស់ថាសមិទ្ធផលទាំងអស់ ដែលយើងសំរេចបានកន្លងមកនេះនៅមិនទាន់អាចឆ្លើយតបសមរម្យទៅនឹងតំរូវការរបស់វិស័យព្រៃឈើជាតិនៅឡើយ ដែលយើងត្រូវការពេលវេលា និងកិច្ចខិតខំប្រឹងប្រែងទ្វេឡើងថែមទៀត ដើម្បីសំរេចបាននូវគោលដៅជាសកលរបស់ជាតិ ក្នុងការគ្រប់គ្រងធនធានព្រៃឈើកម្ពុជាប្រកបដោយចិរភាព និងនិរន្តរភាពនោះ។ តាមការវាយតម្លៃជារួម កំណែទំរង់វិស័យព្រៃឈើរបស់កម្ពុជាបានឆ្លងកាត់ផុតនូវដំណាក់កាល ***សង្គ្រោះបន្ទាន់*** ដែលតម្រូវឱ្យយើងប្រើប្រាស់នូវកម្លាំងសរុបរបស់ជាតិ ដើម្បីទប់ទល់ និងស្តារនូវស្ថានភាពបំផ្លិចបំផ្លាញព្រៃឈើដ៏អាក្រក់នៅក្នុងអាណត្តិទី១ ហើយឈានចូលមកក្នុងដំណាក់កាលបច្ចុប្បន្នគឺការខិតខំធានាឱ្យ ***មានប្រក្រតីភាព និងសណ្តាប់ធ្នាប់ជាធម្មតាវិញ*** នៅក្នុងវិស័យព្រៃឈើនេះ ។ ប្រាកដណាស់យើងនៅត្រូវធ្វើការងារដ៏ច្រើនថែម

ទៀត ដើម្បីចេញផុតពីដំណាក់កាលបច្ចុប្បន្ននេះឆ្ពោះទៅកាន់ដំណាក់កាល ***ចិរភាព និងនិរន្តរភាពល្អប្រសើរ*** នៅក្នុងការគ្រប់គ្រងព្រៃឈើ ។

ក្នុងការធ្វើដំណើរពីស្ថានភាពមាន ***ប្រក្រតីភាព*** និង ***សណ្ដាប់ធ្នាប់*** ជាធម្មតាវិញឆ្ពោះទៅកាន់ ***ភាពល្អប្រសើរ*** នៃ ***វិស័យព្រៃឈើ*** ដែលជាគំរូសកលនោះទាមទារឱ្យរាជរដ្ឋាភិបាលកំណត់ និងអនុវត្តន៍យុទ្ធសាស្ត្រជាប្រព័ន្ធគ្រប់គ្រងមួយមានការឯកភាពច្បាស់លាស់ សំរាប់វិស័យព្រៃឈើទាំងមូលរបស់ជាតិ គឺយុទ្ធសាស្ត្រជាកញ្ចប់ ដែលមានសមាសភាពចូលរួមដោយ "***អភិបាលកិច្ចល្អ***" បូកជាមួយ "***ការកាត់បន្ថយភាពក្រីក្រ***" "***ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម***" និង"***ការធានានូវចិរភាពនៃបរិស្ថាននិងជីវៈចំរុះ***" ។ នៅក្នុងស្មារតីនេះ និងដោយមានអនុសាសន៍ពីក្រុមអ្នកឯកទេសអន្តរជាតិនៃសហគមន៍អ្នកផ្ដល់ជំនួយផងដែរ ខ្ញុំព្រះករុណាខ្ញុំ សូមស្នើឱ្យទីស្តីការគណៈរដ្ឋមន្ត្រី រៀបចំពិភាក្សាជាមួយ នឹងក្រសួងស្ថាប័ន ដែលមានការពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល ដើម្បីពិនិត្យឡើងវិញ អំពីយន្តការគ្រប់គ្រងតំបន់ព្រៃឈើគ្រប់ប្រភេទទាំងអស់រួមទាំងតំបន់ការពារធម្មជាតិទាំង ២៣កន្លែងផង ក្នុងទិសដៅធានានូវឯកភាពសង្គតិភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានព្រៃឈើនេះ ។ កិច្ចការនេះមានរួមបញ្ចូលទាំងតម្រូវការពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សជូនរដ្ឋបាលព្រៃឈើផងដែរ។

ខ្ញុំព្រះករុណាខ្ញុំ សូមយកឱកាសនេះដើម្បីរំលឹកជាថ្មីម្តងទៀត ចំពោះគ្រប់ក្រសួងស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានរដ្ឋបាលព្រៃឈើជាសេនាធិការ សូមបន្តការខិតខំអនុវត្តន៍តួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានស្របតាមច្បាប់ ដោយជំរុញ និងលើកកំពស់សមត្ថភាពឱ្យសហគមន៍នៅតាមមូលដ្ឋានចូលរួមកាន់តែសកម្មច្រើនឡើង នៅក្នុងការគ្រប់គ្រងធនធានព្រៃឈើឱ្យមានប្រសិទ្ធភាពខ្ពស់ ហើយធានាឱ្យបាននូវចិរភាព និងនិរន្តរភាពនៃធនធានព្រៃឈើ ព្រមទាំងនូវការផ្តល់វិភាគទានជាអតិបរមារបស់ធនធានព្រៃឈើ ដល់ការលើកកំពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅជនបទ។

ទន្ទឹមនឹងនេះដែរ ដោយសារថារដ្ឋបាលព្រៃឈើដែលជាសេនាធិការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអ្នកចូលរួមគ្រប់គ្រងព្រៃឈើសហគមន៍ ជាមួយនឹងសហគមន៍មូលដ្ឋានដោយផ្ទាល់នោះ ខ្ញុំព្រះករុណាខ្ញុំ សូមឱ្យស្ថាប័ននេះខិតខំបំពេញតួនាទី និងភារកិច្ចរបស់ខ្លួននៅក្នុងការទទួលខុសត្រូវខ្ពស់ និងមានលក្ខណៈបើកចំហប្រកបដោយតម្លាភាព ដោយតម្កល់ឧត្តមប្រយោជន៍រយៈពេលវែងរបស់ជាតិ និងប្រជាជនជាធំ។

*-សម្តេច ព្រះតេជគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*-ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ជាទីមេត្រី*

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាខ្ញុំសូមសំដែងនូវមនោសញ្ចេតនាស្វាគមន៍យ៉ាងកក់ក្ដៅ និងការដឹងគុណដ៏ជ្រាលជ្រៅជាទីបំផុតចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាតំណាងឱ្យសហគមន៍អ្នកផ្ដល់ជំនួយគ្រប់រូប ដែលបានចូលរួមយ៉ាងសកម្ម និងតាមគ្រប់រូបភាពក្នុងការងារអភិវឌ្ឍន៍ និងអភិរក្សវិស័យព្រៃឈើនៅកម្ពុជា ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ សូមថ្លែងអំណរគុណជាពិសេសដល់ធានាគារពិភពលោកដែលបានជួយស្ថាបនាអគាររដ្ឋបាលព្រៃឈើថ្មីនេះ។ ខ្ញុំព្រះករុណាខ្ញុំ

ក៏មិនភ្លេចនឹងសំដែងការកោតសរសើរជាថ្មីម្តងទៀត ដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះរាល់ការចូលរួមវិភាគទាន និងការអនុវត្តន៍តួនាទីភារកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ ហើយធានាបាននូវប្រសិទ្ធភាពខ្ពស់ និងជោគជ័យច្រើនរាប់មិនអស់ ជូនជាតិមាតុភូមិ។

ជាទីបញ្ចប់ខ្ញុំ ព្រះករុណាខ្ញុំសូមប្រសិទ្ធិពរជ័យប្រគេនសម្តេច ព្រះតេជគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមជូនពរដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ដែលបានចូលរួមក្នុងពិធីនេះ សូមប្រកបដោយពុទ្ធពរទាំងប្រាំប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** និង**បដិភាណៈ** កុំបីឃ្លៀងឃ្លាតឡើយ។

***ខ្ញុំព្រះករុណាខ្ញុំ សូមប្រកាសបើកឱ្យប្រើប្រាស់ជាផ្លូវការអគាររបស់រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចាប់ពីពេលនេះតទៅ។***

***សូមអរព្រះគុណ និងសូមអរគុណ***



## សម្រង់សង្ឃដីកាសម្តេចមហាឃោសានន្ទ អំពីអត្ថប្រយោជន៍នៃដើមឈើ និងព្រៃឈើ

សម្តេច **មហាឃោសានន្ទ** បានមានសង្ឃដីកាក្នុងឯកសារ " *មជ្ឈមណ្ឌលធម្មយាត្រាដើម្បីសន្តិភាព និង អហឹង្សា* " ដែលដកស្រង់ចេញពីខ្សែវីដេអូក្រោមចំណងជើង " *ជីវិតបរិសុទ្ធ* " ទាក់ទងនឹងកិច្ចការពារព្រៃឈើមានខ្លឹមសារ ខាងក្រោមនេះ :

*ការកាប់ឈើដោយគ្មានវិចារណញ្ញាណ វានឹងនាំអោយមានផលវិបាកមិនល្អដល់អ្នកកាប់ហ្នឹងផង ដល់គ្រួសារអ្នកកាប់ ដល់ភូមិ ស្រុក ប្រទេសជាតិ របស់អ្នកកាប់ផងហើយនិងមនុស្សទាំងឡាយក្នុងសកលលោកទាំងមូល ផងដែរ ។*

*សកលលោកមានទំនាក់ទំនង អាស្រ័យគ្នាទៅវិញ ទៅមក ។ បើយើងកំពុងមានទុក្ខ ផ្នែកដទៃទៀតនៃសកលលោកក៏មានទុក្ខដែរ ។ប្រសិនបើកន្លែងយើងរាំងភ្លៀង កន្លែងគេដទៃទៀតក៏ពិបាកដែរ ។ ដើមឈើសំខាន់ណាស់ ដូចយើងដឹងស្រាប់ហើយ ព្រះពុទ្ធទ្រង់ប្រសូតក៏នៅក្រោមដើមឈើ ត្រាសដឹងក៏នៅក្រោមដើមឈើ បរិនិព្វានទៅក៏នៅក្រោមដើមឈើ ដើមឈើហ្នឹងសំខាន់ណាស់ ផ្ទះសំបែងយើងក៏មានដើមឈើដែរជីវិតយើងទទួលនូវផលប្រយោជន៍ពីដើមឈើ ផ្លែឈើមកសំរាប់ឧបត្ថម្ភផងដែរ រុក្ខជាតិនឹង សំខាន់ណាស់ ។*

## សុន្ទរកថា
## របស់សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ
## រាជរដ្ឋាភិបាលកម្ពុជា ក្នុងពិធីសម្ពោធបើកអោយប្រើប្រាស់
## ជាផ្លូវការមជ្ឈមណ្ឌលធនធានតំបន់ឆ្នេរ នៅឆ្នេរឯករាជ្យ
## ក្រុងព្រះសីហនុ ,នាថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៤



*- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*- ឯកឧត្តម ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រដាណឺម៉ាក់*

*- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ*

*- លោកស្រី អស់លោក មន្ត្រីរាជការ បងប្អូនជនរួមជាតិ និងក្មួយៗសិក្សានុសិស្សជាទីស្រឡាញ់*

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំមានកិត្តិយសនិងមានសេចក្ដីសោមនស្សរីករាយយ៉ាងខ្លាំង ដោយបានចូលរួមក្នុងពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការរួមគ្នានូវ **មជ្ឈមណ្ឌលធនធានតំបន់ឆ្នេរ ក្រុងព្រះសីហនុ ក្រុងកែប ខេត្តកំពត និងខេត្តកោះកុង** នៅលើទឹកដីក្រុងព្រះសីហនុ ដែលជាសមិទ្ធផលថ្មីបានកសាងឡើងក្រោមកិច្ចសហប្រតិបត្តិការ នៃជំនួយឧបត្ថម្ភពីរាជរដ្ឋាភិបាលប្រទេសដាណឺម៉ាកនាឱកាសដ៏ថ្លៃថ្លានេះ ។

ការចូលរួមយ៉ាងច្រើនកុះកររបស់យើងចំពោះមុខសមិទ្ធផលនេះ គឺជានិមិត្តរូបនៃការចូលរួមធ្វើជាសាក្សីលើព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដ៏សំខាន់មួយថ្មីទៀត នៅក្នុងការអភិវឌ្ឍន៍វិស័យការពារបរិស្ថានតំបន់ឆ្នេរនិងសមុទ្រ ។ មជ្ឈមណ្ឌលទាំងនេះ ក៏ជាការរួមចំណែកជួយទ្រទ្រង់ដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស ផ្សព្វផ្សាយពត៌មានបច្ចេកទេសនិងអភិវឌ្ឍន៍ប្រពន្ធ័ពត៌មានបរិស្ថាន និងសេដ្ឋកិច្ចសង្គមកិច្ចនៅតំបន់ឆ្នេរ និងសមុទ្រដែលជាវិស័យអាទិភាពស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងគោលនយោបាយ

វិមជ្ឈការនិងវិសហមជ្ឈការដែលកំពុងរីកចំរើនគួរឱ្យកត់សំគាល់ ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំព្រះករុណាខ្ញុំសូមសំដែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះថ្នាក់ដឹកនាំនិងមន្ត្រីរាជការទាំងអស់របស់ក្រសួងបរិស្ថាន ក្នុងកិច្ចសហការកសាងបានសំរេចនូវមជ្ឈមណ្ឌលធនធានតំបន់ឆ្នេរទាំងបួន ដើម្បីធានាដល់ការពង្រឹងសមត្ថភាព ការចែករំលែកពត៌មាន ការតាមដានត្រួតពិនិត្យបរិស្ថាន និងធនធានធម្មជាតិ និងធានាបានការរៀបចំធ្វើផែនការ និងដំណើរការធ្វើសេចក្តីសំរេចចិត្តឱ្យបានត្រឹមត្រូវ ។

ឆ្លៀតក្នុងឱកាសនេះ តាងនាមឱ្យប្រជាជននិងរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំព្រះករុណាខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលដាណឺម៉ាក ដែលបានរួមវិភាគទានដ៏ថ្លៃថ្លាទាំងថវិកា និងបច្ចេកទេស សំរាប់ការកសាងមជ្ឈមណ្ឌលធនធានតំបន់ឆ្នេរ និងការគាំទ្រដល់ការពង្រឹងតួនាទីនៅក្នុងការសិក្សាស្រាវជ្រាវ និងតាមដានពិនិត្យធនធានធម្មជាតិ និងបរិស្ថានដើម្បីការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានតំបន់ឆ្នេរ និងសមុទ្រប្រកបដោយចីរភាព និងប្រសិទ្ធភាពខ្ពស់នាពេលបច្ចុប្បន្ន និងទៅអនាគតសំរាប់កូនចៅជំនាន់ក្រោយ ។

*- ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីបងប្អូនជនរួមជាតិ និងក្មួយៗសិក្សានុសិស្សជាទីស្រឡាញ់*

ដោយសារថា នៅក្នុងពិភពលោកមានការកើនឡើងនូវកំណើនប្រជាជន និងការថយចុះនៃធនធានធម្មជាតិបានធ្វើឱ្យគ្រប់បណ្តាប្រទេសនីមួយៗ ចាំបាច់ត្រូវតែមានផែនការសំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ច ដោយគិតពីតុល្យភាពនៃការអភិឌ្ឍន៍ធនធាន និងការគ្រប់គ្រងបរិស្ថាន ដើម្បីបង្កើនសុខុមាលភាពចំណីអាហារលំនៅដ្ឋាន ថាមពល និងតំរូវការចាំបាច់សំខាន់ៗផ្សេងទៀតជាច្រើន ។ ដោយឡែក ក្នុងតំបន់ឆ្នេរ និងសមុទ្រនៅលើពិភពលោក ដង់ស៊ីតេរស់នៅរបស់ប្រជាជនមានកំរិតខ្ពស់ដោយសារតែភាពរីកចំរើននៃទីក្រុង ការពង្រីកវិស័យទេសចរណ៍ និងឧស្សាហកម្មដែលបង្កឱ្យមានការគំរាមកំហែងដល់ធនធានធម្មជាតិ និងជីវៈចំរុះ ។ ការពង្រីកទីក្រុង និងវិស័យទេសចរណ៍នេះ គឺមិនអាចបញ្ចៀសបានពីការប៉ះពាល់នាពេលអនាគត លើការផ្គត់ផ្គង់ទឹក និងការប្រែប្រួលមិនទៀងទាត់ក្នុងបរិស្ថានតំបន់ឆ្នេរ ដែលអាចបង្កគ្រោះថ្នាក់ប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរនិងសមុទ្រ តំបន់ដីសើម និងគំរាមកំហែងដល់ប្រភេទងាយរងគ្រោះថ្នាក់នានាទៀតផង ។

ដោយយល់ច្បាស់នូវសារៈសំខាន់ទាំងអស់នេះ រាជរដ្ឋាភិបាលមានតួនាទីក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាពបរិស្ថាន ដោយយើងបានបង្កើតច្បាប់ស្តីពី **កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ** និង **ច្បាប់ជលផល** ។ល។ ដែលប្រការទាំងអស់នេះឆ្លើយតបទៅនឹងតំរូវការ និងធានាបានប្រសិទ្ធភាព និងចិរភាព ។

ជាការពិតណាស់ មជ្ឈមណ្ឌលធនធានតំបន់ឆ្នេរគឺជាទីកន្លែងសំរាប់ធ្វើការរួមគ្នាដើម្បីកសាងសមត្ថភាព ជាវេទិកាពិភាក្សាផ្តល់ចំណេះដឹងបច្ចេកទេស មេរៀន បទពិសោធន៍ ដើម្បីកំណត់បញ្ហាអាទិភាព រៀបចំគោលនយោបាយ ផែនការ ការងារ និងអប់រំផ្សព្វផ្សាយដល់ប្រជាជន និងសាធារណៈជន តាមរយៈចងក្រងឯកសារ សិក្សាស្រាវជ្រាវ និងអនុវត្តន៍ជាក់ស្តែងទៅតាមរបៀបរៀនផង និងការអនុវត្តន៍បង្ហាញផង ។ ម្យ៉ាងទៀតមូលដ្ឋានពត៌មានស្តីពីវិទ្យាសាស្ត្រ និងបច្ចេកទេសដែលត្រឹមត្រូវច្បាស់លាស់ ពិតជាជួយរួមចំណែកក្នុងការធ្វើផែនការ និងធ្វើសេចក្តីសំរេចចិត្តបានត្រឹមត្រូវ ក្នុងគោលបំណងចូលរួមចំណែកលើកស្ទួយជីវភាពសង្គមជាតិ និងរក្សាបាននូវបរិស្ថានតំបន់ឆ្នេរនិងសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំសូមសំដែងការកោតសរសើរដោយស្មោះ ចំពោះគណៈកម្មាធិការជាតិគ្រប់គ្រងតំបន់ឆ្នេរ ដែលក្នុងរយៈពេល ៧ ឆ្នាំកន្លងមកនេះ បានបង្កើនកិច្ចសហប្រតិបត្តិការល្អប្រសើរ ក្នុងការគ្រប់គ្រង អភិរក្សតំបន់ឆ្នេរដែលក្នុងនោះ មានការទប់ស្កាត់ភាពអនាធិបតេយ្យតាមតំបន់ឆ្នេរការបង្កើនការផ្តល់សិទ្ធិវិសហមជ្ឈការដល់ខេត្ត-ក្រុង ក្នុងការគ្រប់គ្រងតំបន់ឆ្នេរ ព្រមទាំងការផ្តល់សិទ្ធិក្នុងការប្រើប្រាស់ធនធានធម្មជាតិ ដើម្បីលើកកំពស់កំរិតជីវភាព និងពង្រឹងការចូលរួមរបស់ប្រជាជនយ៉ាងសកម្ម ក្នុងការបង្កើតសហគមន៍មូលដ្ឋាន

តំបន់ឆ្នេរ ឱ្យចេះប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចិរភាព ។

ដូចដែលយើងទាំងអស់គ្នា បានដឹងរួចមកហើយថា ស្ថានភាពភូមិសាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជាផ្តល់អំណោយផលយ៉ាងល្អប្រសើរដោយមានឆ្នេរសមុទ្រប្រវែង ៤៣៥ គ.ម គឺមាន **ខេត្តកោះកុង ក្រុងព្រះសីហនុ ខេត្តកំពត** និង **ក្រុងកែប** ។ សព្វថ្ងៃនេះ ធនធានធម្មជាតិតំបន់ឆ្នេរ និងក្នុងសមុទ្រ បានរួមចំណែកជួយដល់ សកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលរួមមានការធ្វើនាវាចរណ៍ ការដឹកជញ្ជូនទំនិញ កំពង់ផែ ការនេសាទសមុទ្រ ការអភិវឌ្ឍន៍វិស័យឧស្សាហកម្មទេសចរណ៍ និងការប្រកបរបររកស៊ីរបស់ប្រជាពលរដ្ឋទៀតផង ។ ជាងនេះទៅទៀត ការអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រត្រូវបានចាត់ទុកជាអាទិភាពមួយរបស់រាជរដ្ឋាភិបាល នៅក្នុងយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងនោះមានការយកចិត្តទុកដាក់ពីសុខមាលភាព និងការអភិវឌ្ឍន៍បរិស្ថានធម្មជាតិ ប្រកបដោយចិរភាពសំរាប់ពេលអនាគតរបស់កម្ពុជា ។

នៅក្នុងបរិការណ៍ទាំងអស់នេះ **ការអនុវត្តន៍គោលនយោបាយសេដ្ឋកិច្ច និងសង្គមកិច្ច** ដែលមានទិសដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពយ៉ាងខ្ពស់ដល់ការគ្រប់គ្រង និងការប្រើប្រាស់ប្រកបដោយចិរភាព ដែលជាគន្លឹះដ៏សំខាន់បំផុតសំរាប់ធានាតុល្យភាព និងនិរន្តរភាពនៃការអភិវឌ្ឍន៍ រួមទាំងការរក្សាបរិស្ថានតំបន់ឆ្នេរសមុទ្រ និងក្នុងសមុទ្រផង ។ ក្នុងរយៈកាលកន្លងមក រាជ-រដ្ឋាភិបាលបានប្រើប្រាស់ធនធានជាច្រើន នៅក្នុងសកម្មភាពទាំងនេះក្នុងគោលបំណង ដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការលើកកំពស់ជីវភាពរស់នៅ និងសុខុមាលភាពប្រជាពលរដ្ឋ ។ ជាការពិត កិច្ចអភិវឌ្ឍន៍នេះត្រូវការជំនួយឧបត្ថម្ភពីអ្នកផ្តល់ជំនួយអន្តរជាតិជាលក្ខណៈទ្វេភាគីក្នុងដំណាក់កាលខ្លី ប៉ុន្តែនៅពេលអនាគត នឹងត្រូវពឹងផ្អែកលើការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចិរភាព ។

ដោយសារប្រការទាំងអស់នេះហើយ បានជានៅក្នុង *«ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ ឆ្នាំ លើកទី ២ ២០០១-២០០៥»* បានគូសបញ្ជាក់យ៉ាងច្បាស់អំពីភាពចាំបាច់ត្រូវធានាឱ្យបាននូវតុល្យភាពរវាងគោលដៅសេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន ក៏ដូចជារវាងប្រសិទ្ធភាពសេដ្ឋកិច្ច និងសមធម៌នៃការប្រើប្រាស់ធនធានទាំងនោះដែរ ។ យើងបានលើកឡើងនូវយុទ្ធសាស្ត្រសំខាន់ៗ ដូចជាការទប់ស្កាត់ការរិចរិលបរិស្ថាន និងធនធានធម្មជាតិ ការបង្កើតនិងអនុវត្តក្របខ័ណ្ឌច្បាប់សំរាប់ការគ្រប់គ្រងធនធានធម្មជាតិ ការលើកកំពស់ធនធានមនុស្ស សំរាប់គ្រប់គ្រងធនធានធម្មជាតិ និងការរៀបចំ និងអនុវត្តន៍ក្របខ័ណ្ឌគ្រប់គ្រងដីធ្លី សំដៅផ្តល់ជូនដល់ប្រជាជនក្រីក្រនូវដីធ្លីឱ្យបានសមស្រប ដោយគិតគូរអំពីសិទ្ធិរបស់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ធនធាននានាដែលជាកម្មសិទ្ធិរួម ។ នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងគោលនយោបាយទាំងនេះ រាជរដ្ឋាភិបាលបានទទួលស្គាល់ ទំនាក់ទំនងរវាងគោលនយោបាយកាត់បន្ថយភាពក្រីក្រជាមួយនឹងកិច្ចការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិ ព្រមទាំងទទួលស្គាល់នូវតួនាទីយ៉ាងសំខាន់ របស់សង្គមស៊ីវិលក្នុងការរួមចំណែកការពារបរិស្ថាន និងការអភិវឌ្ឍន៍ប្រកបដោយបរិស្ថានល្អ និងនិរន្តរភាពបរិស្ថាន ។

រាជរដ្ឋាភិបាលយល់ច្បាស់ថា ដើម្បីដោះស្រាយបញ្ហាបរិស្ថានតំបន់ឆ្នេរ និងសមុទ្រ ដូចជាការបំពុលសមុទ្រ ការធ្វើអាជីវកម្មនេសាទសមុទ្រខុសច្បាប់ ការធ្លាក់ចុះជីវៈចំរុះ ការខ្វះខាតទឹកស្អាតប្រើប្រាស់ ការធ្លាក់ចុះគុណភាពបរិស្ថាន និងការប្រើប្រាស់ដីធ្លី ។ល។ ទាមទារ និងតំរូវការឱ្យមានការធ្វើសមា-ហរណកម្ម ការសំរបសំរួលរវាងស្ថាប័នជាដៃគូកិច្ចសហប្រតិបត្តិការរវាងផ្នែកសាធារណៈ និងផ្នែកឯកជន ព្រមទាំងការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការទទួលខុសត្រូវរួម និងការគួបផ្សំកំលាំងគ្នា ទាំងក្នុងកំរិតសហគមន៍ អាជ្ញាធរដែនដី ខេត្ត-ក្រុង និងកំរិតថ្នាក់ជាតិ ក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

ជាការពិតណាស់ ប្រសិនបើពុំមានការចូលរួម និងការគាំទ្រពីប្រជាពលរដ្ឋទេ បរិស្ថានតំបន់ឆ្នេរ និងសមុទ្រពុំត្រូវបានធានាតុល្យភាពឡើយ ។ ម្យ៉ាងវិញទៀត ដើម្បីធានាប្រសិទ្ធភាព និង

ចិរភាពនៃកិច្ចគាំពារតំបន់ឆ្នេរ និងសមុទ្រ យើងទាំងអស់គ្នាត្រូវបន្តកិច្ចខិតខំប្រឹងប្រែងឱ្យខ្លាំងថែមទៀត ក្នុងការអនុវត្តន៍ និងរៀបរៀងបទដ្ឋានច្បាប់ គោលនយោបាយតំបន់ឆ្នេរសមុទ្រ និងការពង្រឹងសមត្ថភាពក្នុងក្របខ័ណ្ឌស្ថាប័ន ព្រមទាំងពង្រឹងការកសាងសមត្ថភាពឱ្យមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ។ ទន្ទឹមនឹងនេះ កិច្ចការទាំងអស់នេះមានទំហំធំធេង ដែលទាមទារឱ្យមានការចូលរួមសហការពីសំណាក់ដៃគូទាំងអស់ នៅក្នុងកំរិតថ្នាក់ជាតិ ថ្នាក់ខេត្ត-ក្រុង ពិសេស គឺពីសំណាក់សហគមន៍មូលដ្ឋានសង្គមស៊ីវិល និងសហគមន៍អ្នកផ្តល់ជំនួយនានា ដើម្បីធានាការប្រើប្រាស់ធនធាន និងការអភិវឌ្ឍន៍តំបន់ឆ្នេរ និងសមុទ្រឱ្យមាននិរន្តរភាពបរិស្ថាន សំរាប់ជាផលប្រយោជន៍មនុស្សនាបច្ចុប្បន្ន និងកូនចៅជំនាន់ក្រោយៗទៀត ។



**ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត ថ្លែងសុន្ទរកថាស្វាគមន៍**

ក្នុងក្របខ័ណ្ឌគោលនយោបាយ បរិស្ថានសមុទ្រអន្តរជាតិ ប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិមួយចំនួន ដូចជា ***«អនុសញ្ញាអន្តរជាតិស្តីពីការបំពុលសមុទ្រ»*** នៅឆ្នាំ ១៩៩៤ ***«អនុសញ្ញាអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ»*** នៅឆ្នាំ១៩៩៥ ***«អនុសញ្ញាអន្តរជាតិស្តីពីជីវៈចំរុះ» «អនុសញ្ញាអន្តរជាតិស្តីពីតំបន់ដីសើម»*** នៅឆ្នាំ ១៩៩៩ ។ម្យ៉ាងទៀត រាជរដ្ឋាភិបាលបានធ្វើកិច្ចសហប្រត្តិការថ្នាក់តំបន់ ដូចជា ***«អង្គការសំរបសំរួលសមុទ្រនៃទ្វីបអាស៊ីបូព៌ា»*** នៅឆ្នាំ ១៩៩៥ និង បានចុះហត្ថលេខាលើ ***«សេចក្តីប្រកាសរួមស្តីពីកិច្ចសហការថ្នាក់តំបន់សំរាប់ការអភិវឌ្ឍន៍ដោយចីរភាពនៅសមុទ្រអាស៊ីបូព៌ា»***នៅក្នុងឆ្នាំ ២០០៣ ។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជា សូមវាយតំលៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងចូលរួមយ៉ាងសកម្ម និងជំនួយឧបត្ថម្ភគាំទ្រយ៉ាងសំខាន់ ដែលផ្តល់ជូនប្រទេសកម្ពុជា ដោយអ្នកផ្តល់ជំនួយទ្វេភាគី និងពហុភាគី ព្រមទាំងផ្នែកឯកជន សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលនានា ។ ការចូលរួម និងជំនួយឧបត្ថម្ភទាំងនេះមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការទប់ស្កាត់ការពារទៅនឹងការរិចរឹលធនធានធម្មជាតិ ជាពិសេសដើម្បីធានាថាមានការឆ្លើយតបចំពោះតំរូវការក្នុងការអភិវឌ្ឍន៍ ដោយគ្មានការបំផ្លិចបំផ្លាញធនធានធម្មជាតិ និងរក្សាបានគុណភាពបរិស្ថានខ្ពស់ ។ ជាមួយគ្នានោះ យុទ្ធសាស្ត្រសំខាន់ៗ គឺការកសាងសមត្ថភាព ក្នុងក្របខណ្ឌ័ស្ថាប័នរដ្ឋ ដើម្បីរៀបចំផែនការ និងអនុវត្តកម្មវិធីនានា សំរាប់គ្រប់គ្រងការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពនាពេលអនាគតយូរអង្វែង ។ ជាក់ស្តែង កន្លងមកតាមរយៈគំរោងគ្រប់គ្រងបរិស្ថាននានា យើងបានអនុវត្តនូវការអភិវឌ្ឍន៍និងបណ្តុះបណ្តាលធនធានមនុស្ស ការរៀបចំផែនការខេត្ត-ក្រុងតំបន់ឆ្នេរ ការបង្កើតសហគមន៍សំរាប់គ្រប់គ្រងធនធានធម្មជាតិ និងការបង្កើតប្រព័ន្ធគ្រប់គ្រងពត៌មានបរិស្ថាន សេដ្ឋកិច្ច និងសង្គមកិច្ចនៅតាមតំបន់ឆ្នេរ និងសមុទ្រ ។

ខ្ញុំព្រះករុណាខ្ញុំ សូមយកឱកាសនេះដើម្បីអំពាវនាវចំពោះបងប្អូននេសាទទាំងអស់ ដែលប្រកបរបរនេសាទក្នុងដែនសមុទ្របញ្ឈប់ការធ្វើនេសាទខុសច្បាប់ ដោយប្រើប្រាស់ឧបករណ៍បំផ្លិចបំផ្លាញធនធានសមុទ្រ ដូចជាការប្រើប្រាស់អួនអូសនៅតំបន់ទឹកដែលមានជំរៅក្រោម ២០ ម៉ែត្រ ការបំផ្លាញផ្កាថ្ម ដោយប្រើប្រាស់គ្រឿងផ្ទុះ ការបំផ្លាញស្មៅសមុទ្រ ការកាប់ព្រៃកោងកាង និងការបំផ្លាញទីជំរកមច្ឆាជាតិផ្សេងៗទៀត ។ ការបំផ្លាញទាំងនេះ បានធ្វើឱ្យធនធានជីវៈចំរុះ និងប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ និងសមុទ្រត្រូវបានបាត់បង់ ហើយបណ្តាលឱ្យខូចដល់គុណភាពបរិស្ថាន ដែលនៅទីបញ្ចប់ យើងគ្មានត្រី បង្គា ក្តាម សំរាប់បរិភោគគ្រប់គ្រាន់ ។

ម្យ៉ាងទៀត ការបំពុលសមុទ្រចេញពីប្រភពផ្សេងៗ ដូចជា

រោងចក្រឧស្សាហកម្ម សិប្បកម្ម ការដឹកជញ្ជូន ប្រេង សំណល់រឹង សំណល់គ្រោះថ្នាក់ និងសំណល់រាវ តាមលំនៅដ្ឋាន សណ្ឋាគារ និងការកើនឡើងវិស័យទេសចរណ៍ ដែលបណ្តាលឱ្យមានផលប៉ះពាល់ដល់គុណភាពបរិស្ថាន ដែលយើងត្រូវតែខិតខំជួយថែរក្សា និងការពារឱ្យបាននូវសោភ័ណភាពបរិស្ថានស្អាតល្អ ដើម្បីថែរក្សានូវសុខុមាលភាព និងជីវភាពរុងរឿងរបស់ប្រជាពលរដ្ឋ ។

លេសពនេះទៅទៀត ក្រសួងបរិស្ថាន រួមជាមួយក្រសួងពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក៏ត្រូវជំរុញ និងយកចិត្តទុកដាក់ការពារ និងទប់ស្កាត់ការបំផ្លិចបំផ្លាញដូចបានរៀបរាប់ខាងលើ ទើបមជ្ឈមណ្ឌលធនធានតំបន់ឆ្នេរ ដែលយើងកំពុងដាក់សម្ពោធឱ្យប្រើប្រាស់នាថ្ងៃនេះ អាចចូលរួមចំណែកក្នុងការស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសបរិស្ថាន ដើម្បីរួមចំណែកដល់ការអភិឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ជាពិសេសបំរើឱ្យបានគោលដៅវិមជ្ឈការ និងវិសហមជ្ឈការដែលបំពេញឱ្យគ្នាទៅវិញទៅមកស្របតាមមាគ៌ានយោបាយរបស់រាជរដ្ឋាភិបាល ។

- *ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ*
- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីបងប្អូនជនរួមជាតិ និងក្មួយៗសិក្សានុសិស្សជាទីស្រឡាញ់*

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ ខ្ញុំព្រះករុណាខ្ញុំសូមស្នើ ឯកឧត្តមឯកអគ្គរាជទូត ឬ តំណាងនៃព្រះរាជាណាចក្រដាណឺម៉ាកមេត្តាពាំនាំនូវអំណរគុណ និងកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតពីសំណាក់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាជូនចំពោះរាជ-រដ្ឋាភិបាល និងប្រជាជនដាណឺម៉ាក ដែលបានចូលរួមវិភាគទានដ៏ថ្លៃថ្លា និងប្រកបដោយផ្លែផ្កា ក្នុងការសំរេចនូវការកសាងមជ្ឈមណ្ឌលធនធាន តំបន់ឆ្នេរខេត្ត-ក្រុងទាំងបួនរបស់ប្រទេសកម្ពុជា ក៏ដូចជាការចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីកម្ពុជាធានាបាននូវការប្រើប្រាស់ធនធានធម្មជាតិ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ។



**ឯកឧត្តម ម៉ូហ្គេន ឡាមែនគ្រីសស្តេន កុងស៊ុល**
**និងជាតំណាងព្រះរាជាណាចក្រដាណឺម៉ាកថ្លែងសុន្ទរកថាក្នុងឱកាសប្រារព្ធពិធី**

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំ ព្រះករុណាខ្ញុំសូមថ្លែងនូវការដឹងគុណចំពោះប្រទេសផ្តល់ជំនួយ និងដៃគូទាំងអស់របស់យើង ដែលបានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជាឱ្យបានរីកចំរើន និងមានការផ្លាស់ប្តូរមុខមាត់គួរជាទីកត់សំគាល់ ។ ប្រជាជនកម្ពុជា ពិតជាចារឹកទុកនូវកាយវិការសប្បុរសធម៌ដ៏ប្រពៃថ្លៃថ្លានេះនៅក្នុងផ្នត់គំនិតរបស់ខ្លួននិងសំរាប់កូនចៅជំនាន់ក្រោយៗទៀតដោយមិនអាចបំភ្លេចបានឡើយ ។

ខ្ញុំព្រះករុណាខ្ញុំសង្ឃឹមថា ក្រសួងបរិស្ថាននឹងចាត់ចែងរៀបចំនូវកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស និងការសិក្សាស្រាវជ្រាវបរិស្ថានតំបន់ឆ្នេរ និងសមុទ្រឱ្យទទួលបានផលជាវិជ្ជមានសំរាប់បំរើឱ្យសាធារណៈជន និងសង្គមជាតិទាំងមូល ដើម្បីជាការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនឱ្យបានឆាប់រហ័សនិងការចូលរួមធ្វើសមាណហរណកម្មក្នុងសហគមន៍តំបន់ និងអន្តរជាតិ ប្រកបដោយសក្តានុពលទាំងគុណភាព និងបរិមាណ ។ លើសពីនេះទៅទៀត ក្រសួងបរិស្ថានត្រូវថែរក្សាសមិទ្ធិផលទាំងនេះឱ្យបានគង់វង់ជានិរន្តរ៍តទៅ សំរាប់ជាមរតកប្រវត្តិសាស្ត្រសំរាប់កូនចៅបច្ចុប្បន្ន និងជំនាន់ក្រោយៗទៀត ។

ជាទីបញ្ចប់នេះ ខ្ញុំព្រះករុណាខ្ញុំសូមប្រគេនពរថ្វាយព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជូនពរដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី បងប្អូនជនរួមជាតិ និងសិស្សានុសិស្សទាំងអស់ សូមជួបប្រទះតែពុទ្ធពរទាំងប្រាំប្រការ **អាយុ វណ្ណៈ សុខៈ ពលៈ** និង **បដិភាណៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

ដើម្បីរួមចំណែកសំរាប់ ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** ក្នុងសង្គមកម្ពុជា ខ្ញុំព្រះករុណាខ្ញុំមានសេចក្តី រីករាយ សូមប្រកាសបើកឱ្យប្រើប្រាស់ជាផ្លូវការនូវមជ្ឈមណ្ឌល ធនធានតំបន់ឆ្នេរខេត្ត-ក្រុងទាំងបួនចាប់ពីពេលនេះតទៅ ។

***សូមអរព្រះគុណ និង អរគុណ***



សម្តេច ហ៊ុន សែន អញ្ជើញកាត់ខ្សែបូជានិមិត្តរូប នៃការបើកឱ្យប្រើប្រាស់ជាផ្លូវការអគារមជ្ឈមណ្ឌលធនធានតំបន់ឆ្នេរ



សម្តេច ហ៊ុន សែន និងភ្ញៀវកិត្តិយសអញ្ជើញទស្សនាពិព័រណ៍សមិទ្ធផលតំបន់ឆ្នេរដែលសំរេចបាននាបណ្តាឆ្នាំកន្លងមក

# ការប្រារព្ធទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា ឆ្នាំ ២០០៤ ក្រោមទិសស្លោក ដែលអង្គការកម្មវិធីបរិស្ថាន

សហប្រជាជន (UNEP) បានលើកឡើងថា :

WANTED!SEAS AND OCEANS DEAD OR ALIVE ?

ថ្ងៃទី ៥ មិថុនា ឆ្នាំ ២០០៤ កន្លងមក ក្រសួងបរិស្ថានក៏បានដឹកនាំប្រារព្ធមីទ្ទីញអបអរសាទរទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥មិថុនា ដូចបណ្តាឆ្នាំកន្លងមកដែរ។ ទន្ទឹមនោះ មន្ទីរបរិស្ថានខេត្ត-ក្រុងទូទាំងប្រទេស ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលដែលមានបេសកកម្មពាក់ពន្ធ័នឹងកិច្ចការពារធនធានធម្មជាតិនៅប្រទេសកម្ពុជា ក៏បានចូលរួមរៀប ចំមីទ្ទីញដែលមានចរិត ដូចគ្នានេះដែរ។

ដើម្បីជាពត៌មានដល់មិត្តអ្នកអាន ទស្សនាវដ្តីបរិស្ថានសូមចុះផ្សាយទាំងស្រុងខ្លឹមសារសុន្ទរកថាឯកឧត្តម បណ្ឌិត ម៉ុក~ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថានដែលបានថ្លែងក្នុងឱកាសប្រារព្ធមីទ្ទីញអបអរសាទរទិវាបរិស្ថាន ៥មិថុនា ឆ្នាំ២០០៤ នៅខេត្តកំពង់ឆ្នាំងទាំងស្រុងដូចតទៅ :



ឯកឧត្តមបណ្ឌិត **ម៉ុក~ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឧត្តម **ស៊ុំ~គិរីន្ទ** អភិបាលខេត្ត កំពង់ឆ្នាំង និងភ្ញៀវកិត្តិយសនាឱកាសប្រារព្ធពិធី

- **ខ្ញុំព្រះករុណាខ្ញុំ សូមក្រាបថ្វាយបង្គំព្រះថេរា នុថេរៈ គ្រប់ព្រះអង្គ**
- **សូមគោរព គណៈអធិបតី**
- **ឯកឧត្តម លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីស្នេហា**
- **លោក លោកស្រី មន្ត្រីរាជការ និងបងប្អូន ជនរួមជាតិជាទីមេត្រី**
- **ក្មួយៗ សិស្សានុសិស្ស ទាំងអស់ជាទីរាប់អាន !**

ថ្ងៃនេះ ក្នុងនាមខ្លួនខ្ញុំ និងក្នុងនាមថ្នាក់ដឹកនាំក្រសួងបរិស្ថាន ខ្ញុំមានមោទនៈណាស់ ដោយបានកិច្ចគាំទ្រពីឯកឧត្តមអភិបាលខេត្ត និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ក្នុងខេត្តកំពង់ឆ្នាំង បានអនុញ្ញាតិឱ្យប្រតិភូក្រសួងបរិស្ថានយើងខ្ញុំ មករៀបចំប្រារព្ធមីទ្ទីញអបអរសាទរទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥មិថុនា ឆ្នាំ២០០៤ នៅលើទឹកដីខេត្តកំពង់ឆ្នាំង ដែលកំពុងមានការអភិវឌ្ឍន៍ ប្រែមុខមាត់ថ្មីគួរឱ្យចាប់អារម្មណ៍ ក្រោមការដឹកនាំរបស់ **ឯកឧត្តម ស៊ូ ភិរិន្ទ** ជាអភិបាលខេត្ត ។

វត្តមានគណៈអធិបតី ភ្ញៀវកិត្តិយស និងបងប្អូនប្រជាពលរដ្ឋទាំងអស់ក្នុងឱកាសនេះ ជាសក្ខីភាពសរបញ្ជាក់ថា ឯកឧត្តម លោក លោកស្រី និងបងប្អូន ជនរួមជាតិយើងបានគាំទ្រដោយទឹកចិត្តជ្រះថ្លា កម្មវិធីនយោបាយបរិស្ថានរបស់រាជរដ្ឋាភិបាល ដែលមាន **សម្ដេច ហ៊ុន សែន** ជាប្រមុខ ។

ទន្ទឹមនេះដែរ ក៏ជាសក្ខីភាពឆ្លុះបញ្ចាំងអំពីស្មារតីចូលរួមយ៉ាងសកម្មជាមួយរដ្ឋាភិបាល នៃបណ្ដាប្រទេសនានាលើសកលលោក ក្នុងការថែរក្សាគុណភាពបរិស្ថានតំបន់ និងបរិស្ថានសកលលោកទាំងមូលឱ្យមាននិរន្តរភាពផងដែរ ។

**គណៈអធិបតីជាទីគោរព !**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជំរាបជូនថា រៀងរាល់ឆ្នាំ ថ្ងៃទី៥ ខែមិថុនា សហគមន៍ទូទាំងពិភពលោកបានជួបជុំគ្នា ដើម្បីប្រារព្ធទិវាបរិស្ថានពិភពលោក ។ ថ្ងៃប្រារព្ធទិវានេះ គឺជាជំនឿទុកចិត្តរបស់មនុស្សម្នាក់ៗថា ខ្លួនមានសិទ្ធិសេរីភាពពីធម្មជាតិ ក្នុងការទទួលបានខ្យល់បរិសុទ្ធ ដើម្បីដកដង្ហើម ទឹកស្អាតដើម្បីទទួលទាន និងផលប្រយោជន៍ជីវៈចំរុះផ្សេងៗទៀត ដើម្បីទ្រទ្រង់ជីវភាពរស់នៅប្រកបដោយសុភមង្គល និងផាសុកភាព ហើយមនុស្សម្នាក់ ៗ មានសិទ្ធិចូលរួមអនុវត្តន៍គ្របវិធានការ ដើម្បីទប់ស្កាត់រាល់បាតុភាពអវិជ្ជមាន ដែលប៉ះពាល់ដល់បរិស្ថាន ព្រោះកិច្ចការពារបរិស្ថាន ជាភារកិច្ចរួមរបស់មនុស្សជាតិ ។ ដោយឡែកនៅកម្ពុជា ដោយយល់ឃើញថា : ទិវានេះក៏មានអត្ថន័យយ៉ាងជ្រាលជ្រៅក្នុងកិច្ចគាំពារបរិស្ថាន រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យមួយលេខ ១៥ អនក្រ-បក ចុះថ្ងៃទី២៤ មេសា ឆ្នាំ១៩៩៦ កំណត់ យកថ្ងៃប្រារព្ធទិវាបរិស្ថានពិភពលោក ធ្វើជាឱកាសប្រារព្ធទិវាបរិស្ថានជាតិព្រមគ្នាផងដែរ ។

ឆ្នាំនេះ ដើម្បីអបអរសាទរការប្រារព្ធទិវានេះ អង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ ហៅកាត់ថា " UNEP " បានលើកឡើងនូវពាក្យស្លោកមួយថ្មីទៀត សំរាប់បំផុសចលនាគាំពារបរិស្ថាន ដោយបានផ្ដោតអារម្មណ៍ ទៅលើកិច្ចគាំពារបរិស្ថានសមុទ្រ ហើយបានលើកពាក្យស្លោកជាភាសាអង់គ្លេសថា "WANTED! SEAS AND OCEANS DEAD OR ALIVE ? " ។ បើយើងបកប្រែជាភាសាខ្មែរសាមញ្ញ ងាយយល់មកមានខ្លឹមសារ និងអត្ថន័យថា **"ចូរនាំគ្នា ការពារបរិស្ថានសមុទ្រ និងមហាសមុទ្រឱ្យបានស្អាតជានិច្ច"** ។

ដោយខេត្តកំពង់ឆ្នាំង ជាខេត្តមិនជាប់នឹងសមុទ្រ ប៉ុន្តែខេត្តនេះមានទីតាំងភូមិសាស្ត្រជាប់នឹងបឹងទន្លេសាប ក្រសួងបរិស្ថានក៏បានឯកភាពលើកទិសស្លោកជាក់ស្ដែង ក្នុងខ្លឹមសារថា " **បរិស្ថានបឹងទន្លេសាប អាក្រក់ឬល្អ គឺជាជំរើសរបស់យើង** " ឬ " **រួបរួមគ្នាគ្រប់គ្រង ការពារបរិស្ថានបឹងទន្លេសាបឱ្យបានចីរភាព សំរាប់ផលប្រយោជន៍របស់យើងគ្រប់គ្នា** " ។



**ពិធីបដិសណ្ឋារកិច្ចពេល ឯកឧត្តមរដ្ឋ មន្ត្រីអញ្ជើញដល់ វេទិកាប្រារព្ធពិធី**

**បងប្អូនជនរួមជាតិជាទីស្នេហា !**

មនុស្សជាតិបានរស់នៅ និងបន្តរស់នៅ លើភពតែមួយដោយមានសមុទ្រ និងមហាសមុទ្ររួម មានទឹកសាបរួម មានភ្លៀងរួម ខ្យល់អាកាសរួម ហើយភពផែនដីជាទីជំរកយើងជាផ្ទះយើង ។

ដូច្នេះការប្រារព្ធទិវាបរិស្ថាននេះ គឺជាការដាស់ស្មារតី និងអប់រំយើងឱ្យយល់ថា បុគ្គលគ្រប់រូប គឺជាមនុស្សជាតិតែមួយ ពោលគឺជាមហាគ្រួសារតែមួយ ទោះបីយើងមានវប្បធម៌ខ្លះខុសគ្នា ឬមាននិន្នាការនយោបាយខ្លះខុសគ្នាក៏ដោយ តែយើងរស់នៅក្រោមដំបូល នៃបរិស្ថាន និងធម្មជាតិរួមគ្នា ។

ទន្ទឹមនេះដែរ ការប្រារព្ធទិវាបរិស្ថាន ៥មិថុនានេះ ក៏ជាឱកាសមួយ ដើម្បីវាយតម្លៃរាល់កិច្ចការដែលសំរេចបានក្នុងការការពារបរិស្ថាន ឆ្នាំកន្លងមក ក៏ដូចជាការប្រមើលមើលអំពីបញ្ហាប្រឈមមុខ ដែលត្រូវដោះស្រាយ និងត្រៀមដោះស្រាយ ។

ដូច្នេះក្នុងឱកាសនេះ យើងត្រូវទទួលស្គាល់និងវាយតម្លៃឱ្យបានត្រឹមត្រូវ ការខិតខំរបស់រាជរដ្ឋាភិបាល ក្នុងអណត្តិកន្លងមក ក្នុងកិច្ចការពារបរិស្ថាន ក៏ដូចជាសេចក្ដីក្លាហាន និងការតាំងចិត្តរបស់មនុស្សទូទៅ ដែលមានតួនាទីចូលរួមការពារ និងអភិរក្សបរិស្ថានកម្ពុជា ដូចជាអង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងអន្តរជាតិ ដែលបាននិងកំពុងបន្តបំពេញបេសកកម្ម ក្នុងបុព្វហេតុបរិស្ថាននៅកម្ពុជា ពិសេសគឺការចូលរួមរបស់បងប្អូន ប្រជាពលរដ្ឋយើង ដែលជាម្ចាស់នៃភោគទ្រព្យធម្មជាតិទាំងអស់ ។

ដំណោះស្រាយពេលថ្មីៗនេះរបស់រាជរដ្ឋាភិបាលអំពីបញ្ហាបរិស្ថាន ដូចជាការទប់ស្កាត់ការបំផ្លាញព្រៃឈើ ការរុករានទន្ទ្រានដីពង្រីកកម្មសិទ្ធនៅតំបន់ឆ្នេរ រហូតដល់ការបំពុលបរិស្ថាន មានការបំពុលទឹក បំពុលដី បំពុលខ្យល់ ការរំខានដោយសម្លេងនិងរំញ័រ និងការទុកដាក់សំណល់គ្រប់ប្រភេទ ដែលយើងម្នាក់ៗមានចំណែកបានចូលរួមទទួលខុសត្រូវចំពោះរាល់សកម្មភាពទាំងនោះ ហើយយើងក៏មិនត្រូវបោះបង់ចោលសេចក្ដីសង្ឃឹមឡើយ ទោះបីសព្វថ្ងៃនេះបញ្ហាបរិស្ថាននៅកម្ពុជា នៅបន្តមានជួបបញ្ហាអសកម្មដោយអន្លើខ្លះៗយ៉ាងណាក៏ដោយ ។ គ្រប់ពេលវេលាទាំងអស់ មនុស្សគ្រប់រូបត្រូវក្រោកឈរឡើង ដើម្បីថែទាំ ការពារ និងបង្កើនគុណភាពបរិស្ថាន ។

ក្នុងឱកាសនេះ ខ្ញុំក៏សូមអនុញ្ញាតិបង្ហាញអំពីការខិតខំប្រឹងប្រែងរបស់ក្រសួងបរិស្ថាន ក្រោយពេលបានប្រសូតឡើង បន្ទាប់ពីការបង្កើតរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិនាឆ្នាំ១៩៩៣ ដែលរហូតដល់បច្ចុប្បន្ននេះមានអាយុកាល ១១ឆ្នាំហើយ ។ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងវិស័យបរិស្ថាន មន្ត្រីបរិស្ថានគ្រប់លំដាប់ថ្នាក់បានខិតខំប្រឹងប្រែង ដោយប្រើអស់ថាមពល បញ្ញាញាណ កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី និងធនធាន ទាំងធនធានមនុស្ស និងធនធានថវិកា សំរាប់ដំណើរការគាំពារនិងស្តារគុណភាពបរិស្ថានឡើងវិញ ដើម្បីឱ្យអ្វីៗដែលនៅជុំវិញពលរដ្ឋខ្មែរម្នាក់ៗ មានភាពកាន់តែល្អប្រសើរសំរាប់អ្នកកំពុងរស់នៅ និងអ្នកត្រូវបន្តវេនពីយើងជំនាន់នេះ ព្រមទាំងសំរាប់មនុស្សជាតិ ព្រោះមនុស្សម្នាក់ៗចង់កែប្រែគុណភាពនៃការរស់នៅ គឺភាពស្អាតបាត ភាពសមរម្យក្នុងការហូបចុក និងមានផ្ទះដ៏មានសុវត្ថិភាពសំរាប់ជ្រកកោន ។ល។ និង ។ល។

ខ្ញុំសូមប្រកាសជាឧឡារិកថា សមិទ្ធផលដែលក្រសួងបរិស្ថានសំរេចបានកន្លងមក ជាពិសេសសមិទ្ធផលក្នុងឆ្នាំ២០០៣ និងដើមឆ្នាំ២០០៤នេះ ជាសមិទ្ធផលរួម ដែលមិនអាចកាត់ផ្ដាច់បានពីកិច្ចសហការ និងសហប្រតិបត្តិការល្អ ពីបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធ ពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ពីកងកម្លាំងប្រដាប់

និងការជួយជ្រោមជ្រែងថវិកា និងសម្ភារៈពីរដ្ឋាភិបាលនៃបណ្ដាប្រទេសជាមិត្ត ពីសប្បុរសជនជាតិ និងអន្តរជាតិ ពិសេសគឺការចូលរួមទាំងស្មារតី និងកម្លាំងកាយចិត្តរបស់មហាជនយើងគ្រប់មជ្ឈដ្ឋាន ដែលជាកម្លាំងចលករ យ៉ាងសំខាន់បំផុតមិនអាចខ្វះបាន ដែលរួមក៏មានបងប្អូនទាំងអស់ ដែលកំពុងវត្តមានក្នុងអង្គមីទិញអបអរសាទរទិវាបរិស្ថាននៅទីនេះ ទាំងអស់ផងដែរ ។

ក្រសួងបរិស្ថានមានមោទនៈភាពណាស់ ក្នុងការសំរេចបានជោគជ័យទាំងនោះ ។ តែទោះបីដូច្នេះក៏ដោយក៏ក្រសួងនៅមានជួបការលំបាកស្មុគស្មាញជាច្រើនទៀត ដើម្បីធានាការអនុវត្តន៏បានជោគជ័យមួយរយភាគរយ (100%) តាមផែនការដែលបានលើកឡើង ក្នុងកិច្ចប្រតិបត្តិការ ធានារក្សាសន្តិសុខបរិស្ថាន បានគ្រប់ជ្រុងជ្រោយ ។

**គណៈអធិបតី ជាទីគោរព !**

យើងបានដឹងថា ប្រជាជនកម្ពុជាប៉ែតសិបប្រាំភាគរយ (85%) បានរស់នៅជនបទ ហើយក្នុងចំនួននេះភាគច្រើនពឹងផ្អែកលើធនធានព្រៃឈើ ដី ទឹក ដើម្បីរស់ ហើយបរិស្ថានប្រទេសកម្ពុជាបានចិញ្ចឹម និងទ្រទ្រង់ជីវភាពរស់នៅដល់ប្រជាជន ព្រមទាំងបានផ្ដល់ធនធានសំរាប់ចែករំលែកគ្នាកន្លងមក នឹងទៅអនាគត ។ ប៉ុន្តែដោយវិបត្តិសង្គ្រាមស៊ីវិលក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ និងផលវិបាកនៃសង្គ្រាមនោះបរិស្ថានកម្ពុជាកំពុងស្ថិតក្នុងសភាពគ្រោះថ្នាក់ ។ ដូច្នេះយើងត្រូវស្តារឡើងវិញរាល់ទំនាក់ទំនង និងអាកប្បកិរិយារបស់យើងជាមួយនឹងបរិស្ថានធម្មជាតិ ដែលជាអ្នកទ្រទ្រង់យើង និងចិញ្ចឹមយើងទាំងអស់គ្នា ។ យើងមិនអាចបន្តយកឈ្នះ និងរំលោភលើធម្មជាតិឡើយ យើងត្រូវតែថែរក្សាធម្មជាតិ គោរពធម្មជាតិ ដើម្បីឱ្យធម្មជាតិផ្តល់ផលប្រយោជន៏ដល់រូបយើង និងកូនចៅរបស់យើង ដូចដែលធម្មជាតិធ្លាប់បានផ្តល់ដល់បុព្វការីយើងដូច្នោះដែរ ។

**បងប្អូនរួមជាតិ ជាទីស្នេហា !**

នៅខេត្តកំពង់ឆ្នាំង បរិស្ថានធម្មជាតិមានភាពសំបូរបែបណាស់ ដូចជាព្រៃឈើ ធនធានជលផល ផលិតផលកសិកម្ម ក្នុងនោះក៏មានបឹងទន្លេសាប ដែលជាសក្តានុពល សេដ្ឋកិច្ចយ៉ាងសំខាន់មួយក្នុងការកសាងសេដ្ឋកិច្ចមូលដ្ឋាន និងសេដ្ឋកិច្ចជាតិ ។

ចំពោះមុខ បឹងទន្លេសាបបានទទួលរងនូវហេតុប៉ះពាល់ជាច្រើន ដែលបណ្តាលមកពីកត្តា សត្យានុម័ត និងអត្តនោម័ត ដូចជាការគោករាក់បណ្តាលមកពីកំណកល្បាប់ធ្លាក់ចូលពីតំបន់ខ្ពង់រាបជុំវិញ ការកាប់រានដីព្រៃលិចទឹកពង្រីកផ្ទៃដីកសិកម្ម ឬផលប្រយោជន៏សេដ្ឋកិច្ចផ្សេងៗទៀត ការសង់លំនៅស្ថានអនាធិបតេយ្យលើផ្ទៃទឹក ការបង្ហូរចូលសំណល់រាវទីក្រុង ការបង្ហូរសំណល់ប្រេងលើទឹកនៃជលយានគ្រប់ប្រភេទ ការទទួល

លើផ្ទៃទឹក ការបង្ហូរចូលសំណល់រាវទីក្រុង ការបង្ហូរសំណល់ប្រេងលើទឹកនៃជលយានគ្រប់ប្រភេទ ការទទួលរងនូវផលវិបាកដែលបណ្ដាលមកពីការប្រើថ្នាំគីមីកសិកម្មខុសលក្ខណៈបច្ចេកទេស ការប្រែប្រួលរបបទឹកយ៉ាងខ្លាំងដែលបណ្ដាលមកពីកត្តាអត្តនោម័ត និងសត្យានុម័តបរិស្ថាន រួមទាំងបទល្មើសនេសាទ ។ល។និង ។ល។

រូបភាព និងសកម្មភាព អវិជ្ជមានទាំងនោះ នាំឱ្យប៉ះពាល់ដល់គុណភាពទឹក សំរាប់ទ្រទ្រង់ការរស់នៅរបស់ប្រជាជន និងការបង្កបង្កើនផលកសិកម្ម ការរីកចំធាត់នៃជីវៈចំរុះគ្រប់ប្រភេទ ពិសេសគឺធនធានជលផល ។

ឆ្នាំនេះយើងបានដឹងហើយថា ទិន្នផលត្រីទឹកសាប បឹងទន្លេសាបបានធ្លាក់ចុះ ហើយប្រជាកសិករគ្មានត្រីសំរាប់ធ្វើប្រហុក ដែលជាស្បៀងមានចរិតយុទ្ធសាស្ត្ររបស់ប្រជាកសិករ ។ ដូច្នេះចូរយើងប្រមើលមើលពីផលវិបាកពេលទៅផ្សារ ហើយមិនឃើញមានត្រី ដែលនាំមកពីបឹងទន្លេសាបសំរាប់លក់ ដែលឆ្នាំមុនៗ មានលក់ពោរពាស ឬក៏ឃើញមានតិចតួចដែរ តែអ្នកមានជីវភាពសេដ្ឋកិច្ចទាប មិនអាចមានលទ្ធភាពទិញបាន ព្រោះវាថ្លៃពេក ។



ឯកឧត្តមរដ្ឋមន្ត្រីថ្លែងសុន្ទរកថា និងថ្លែងមតិសំណេះសំណាល ក្នុងឱកាសប្រារព្ធពិធី

ស្ថានភាពគួរឱ្យខ្លោចផ្សានេះ អាចនឹងបន្តកើតមាន នៅឆ្នាំបន្តបន្ទាប់ទៀតក្នុងករណីដែលយើង ទាំងអស់គ្នា មិនបានគិតគូរ និងលើកវិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីស្ដារឡើងវិញនិងទប់ស្កាត់ភាព អសកម្មទេនោះ ដោយរាប់បញ្ចូល ទាំងការទប់ស្កាត់ ការនេសាទហួសហេតុនិងការប្រើឧបករណ៍ល្មើសច្បាប់ផងដែរ ។

ពីលើវេទិកានេះ ខ្ញុំសូមសំណូមពរ ឱ្យអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ស្ថាប័នជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋយើង យកចិត្តទុកដាក់ឱ្យបានខ្ពស់ សកម្មចូលរួមគាំពារបរិស្ថានបឹងទន្លេសាប ឱ្យមានភាពល្អប្រសើរឡើងវិញ ដើម្បីឱ្យបរិស្ថានធម្មជាតិនៅទីនោះមាននិរន្តរភាព ។

ខ្ញុំមានសង្ឃឹម និងមានជំនឿថាការយល់ដឹងពីអត្ថន័យ និងខ្លឹមសារនៃការប្រារព្ធទិវាបរិស្ថានជាតិ និង ពិភពលោកនាឱកាសនេះវានឹងក្លាយជាពុទ្ធិមួយថ្មីទៀត ប្រកបដោយមនសិការស្នេហាបរិស្ថានខ្ពស់ ហើយបង ប្អូនប្រជាពលរដ្ឋយើង នឹងយកការយល់ដឹងនេះប្រែក្លាយជាសកម្មភាពអនុវត្តន៍ជាក់ស្តែងក្នុងសកម្មភាពប្រចាំថ្ងៃ និងក្នុងការផ្សព្វផ្សាយអប់រំបន្ត ដើម្បីបុព្វហេតុគុណភាពបរិស្ថាននៅខេត្តកំពង់ឆ្នាំង បរិស្ថានបឹងទន្លេសាប និយាយដោយឡែក ហើយបរិស្ថានកម្ពុជានិយាយជារួមមានភាពស្រស់ត្រកាលបៃតងជានិច្ច និងស្អាតផូផង ហើយបុគ្គលម្នាក់ៗត្រូវមានទស្សនៈថា :

- **ការរស់នៅក្នុងបរិស្ថានល្អ ជាសិទ្ធិរបស់ពលរដ្ឋគ្រប់រូប**
- បរិស្ថានល្អសុខភាពល្អ គ្រួសារមានសុភ-មង្គល និងផាសុកភាព
- កិច្ចការពារបរិស្ថានគឺជាភារកិច្ចយើងគ្របគ្នា ។

**គណៈអធិបតី ជាទីគោរព !**

**បងប្អូនជនរួមជាតិ ជាទីស្នេហា !**

មុនបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀត ចំពោះគណៈអធិបតី ឯកឧត្តមអភិបាលខេត្ត ភ្ញៀវកិត្តិយសទាំងអស់និងបងប្អូនប្រជាពលរដ្ឋយើងគ្រប់ស្រទាប់ឋានៈ ដែលបានចូលរួមនាឱកាសនេះ ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធិពរជ័យ ប្រគេន និងជូនឯកឧត្តម លោក លោកស្រី និងបងប្អូនជនរួមជាតិយើងទាំងអស់ បានប្រកបដោយសេចក្តីសុខចំរើន និងទទួលបានជោគជ័យលើគ្រប់ភារកិច្ច ។

- **ជយោ ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥មិថុនា ឆ្នាំ២០០៤ !**
- **សូមចូលរួមការពារបរិស្ថានបឹងទន្លេសាបឱ្យបានល្អប្រសើរ សំរាប់ផលប្រយោជន៍របស់យើងគ្រប់គ្នា !**

**សូមអរព្រះគុណ និងសូមអរគុណ**



**ក្រោយពីបញ្ចប់ពិធីមិទ្ទិញឯកឧត្តម រដ្ឋមន្ត្រី និងគណៈអធិបតី អញ្ជើញកាត់ខ្សែបូសម្ពោធបើកឱ្យ ប្រើប្រាស់ជាផ្លូវការមន្ទីរបរិស្ថាន ខេត្តដែលទើបបានសាងសង់ថ្មី ដោយថវិការបស់រាជរដ្ឋាភិបាល**

# សុន្ទរកថារបស់ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្នុងឱកាសប្រកាសឱ្យប្រើប្រាស់របាយការណ៍ ស្តីពី ការពិនិត្យឡើងវិញអំពីតំបន់ការពារធម្មជាតិ និងការអភិវឌ្ឍន៍(PAD)

**ភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៤**

*គណៈអធិបតីជាទីគោរព !*

*ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិជាទីស្នេហា !*

*សមាជិកបណ្តាញ PAD ជាទីមេត្រី !*

ថ្ងៃនេះ តាងនាមឱ្យក្រសួងបរិស្ថាននឹងរូបខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយស និងសេចក្តីរីករាយដែលបានមកចូលរួមធ្វើជាគណៈអធិបតីនាឱកាសនេះ ម្យ៉ាងវិញទៀត ក្រសួងបរិស្ថានមានមោទនភាពក្រៃលែងដែលមាននាទីជាស្ថាប័ននាំមុខក្នុងការពិនិត្យឡើងវិញអំពីតំបន់ការពារធម្មជាតិ និងការអភិវឌ្ឍន៍នៃប្រទេសកម្ពុជា សំរាប់រយៈពេលជាងពីរឆ្នាំកន្លងមកនេះ។ វាជាដំនើរការប្រកបដោយផ្លែផ្កា និងប្រព្រឹត្តទៅយ៉ាងទៀងទាត់ នៃការសិក្សានៅលើទីតាំងភូមិសាស្ត្រ ការវិភាគគោលនយោបាយអន្តរវិស័យ និងការពិគ្រោះយោបល់ ព្រមទាំងការធ្វើអត្តសញ្ញាណបណ្តាសកម្មភាពអាទិភាព ។ ពិធីប្រកាសឱ្យប្រើប្រាស់របាយការណ៍ **PAD** នេះ បង្ហាញពីការបញ្ចប់ដំនើរការពិនិត្យឡើងវិញនេះ ក្នុងប្រទេសទាំងបួននៅភាគខាងក្រោមនៃទន្លេមេគង្គ និងការប្តូរកិច្ចប្រឹងប្រែងរបស់យើងទៅជាការអនុវត្តន៍។



**គណៈអធិបតីក្នុងឱកាសប្រារព្ធពិធីបើកសិក្ខាសាលា**

ការពិនិត្យឡើងវិញនៃ **PAD**នេះ មានសារៈសំខាន់ណាស់ ព្រោះថាវាបង្ហាញអំពីថាតើតំបន់ការពារធម្មជាតិដើរតួនាទីសំខាន់បែបណានៅក្នុងការការពារ អភិរក្ស និងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចេរភាពក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ទន្លេមេគង្គ។ សារជាគន្លឹះនៅទីនេះ គឺតំបន់ការពារធម្មជាតិមាននាទីរក្សាស្ថេរភាពធនធាន និងប្រព័ន្ធធម្មជាតិដែលជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចតំបន់។ ប្រសិនបើតំបន់ការពារធម្មជាតិនៅក្នុងភូមិភាគនេះត្រូវខូចខាត នោះសេដ្ឋកិច្ចនៅក្នុងភូមិភាគនេះក៏ខូចខាតដូចគ្នាដែរ។ អ្នកដែលនឹងរងគ្រោះមុនគេគឺប្រជាពលរដ្ឋក្រីក្រ។

*ការពិនិត្យឡើងវិញនៃ PAD ផ្តល់ជាយុទ្ធសាស្ត្រសំរាប់ឱ្យតំបន់ការពារធម្មជាតិនៅបន្តដើរតួរយ៉ាងសំខាន់ ក្នុងការកាត់បន្ថយភាពក្រីក្រស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា* ។ យុទ្ធសាស្ត្រនេះទាក់ទងជាមួយធនធានធម្មជាតិដ៏សំបូរបែបខ្លះៗ និងសហគមន៍មូលដ្ឋានក្រីក្រជាងគេខ្លះៗនៅក្នុងតំបន់នេះ។ ការពិនិត្យឡើងវិញនេះបានបង្ហាញអំពី ថាតើរដ្ឋាភិបាលអាចកាត់បន្ថយភាពក្រីក្រតាមរយៈការប្រើប្រាស់ និងអភិរក្សតំបន់ការពារធម្មជាតិប្រកប ដោយប្រសិទ្ធិភាពខ្ពស់។

*ការពិនិត្យឡើងវិញនៃ PAD បង្ហាញអំពីថាតើកំនើនផលិតភាពក្នុងវិស័យសេដ្ឋកិច្ចជាច្រើននឹងមានទំនាក់ទំនងបែបណា ជាមួយការរួមវិភាគទាននៃតំបន់ការពារធម្មជាតិ*។

លទ្ធផល និងអនុសាសន៍ដែលបានរកឃើញនៅក្នុងការពិនិត្យឡើងវិញនៃ PAD បានគូសបញ្ជាក់អំពីតំរូវការ ដើម្បីផ្តល់មូលនិធិឱ្យបានគ្រប់គ្រាន់ និងប្រកបដោយសង្គតភាពសំរាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដោយទទួលស្គាល់អំពីតួនាទីយ៉ាងសំខាន់នៃតំបន់ការពារធម្មជាតិក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ នេះមានន័យថា សំរាប់រយៈពេលកំនត់មួយទៅអនាគត ទោះបីតំលៃនៃតំបន់ការពារធម្មជាតិ នៅតែស្ថិតនៅក្រៅក្របខ័ណ្ឌធម្មតានៃខ្ទង់គណនេយ្យសេដ្ឋកិច្ចក្តី យើងនឹងត្រូវការឱ្យមានការវិនិយោគយ៉ាងច្រើន ទាំងការវិនិយោគក្នុងស្រុក និងពីបរទេស ដើម្បីថែរក្សា ប្រព័ន្ធតំបន់ការពារធម្មជាតិរបស់ជាតិ។

ការពិនិត្យឡើងវិញនេះបានស្នើឱ្យ ក្រសួងបរិស្ថានធ្វើការជាមួយក្រសួងឧស្សាហកម្មរ៉ែនិងថាមពល និងក្រសួងកសិកម្ម-រុក្ខាប្រមាញ់ និងនេសាទ ក្រសួងស្ថាប័នពាក់ពន្ធ័ ដើម្បីរៀបចំគោលការណ៍ណែនាំពិសេសសំរាប់ធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ថាមពលនៅក្នុង ឬក្បែរតំបន់ការពារធម្មជាតិ។ ការពិនិត្យឡើងវិញនេះ បានស្នើឱ្យមានក្រិត្យច្បាប់រួមគ្នា ដែលកំនត់បទដ្ឋាន តួនាទី និងកាតព្វកិច្ចរបស់ក្រសួង ស្ថាប័នពាក់ពន្ធ័ សំរាប់ក្រុមហ៊ុនដែលលើកសំនើគំរោងវិនិយោគ និងសំរាប់ភាគីពាក់ព័ន្ធនានាផ្សេងទៀតនៅក្នុងដំនើរការនេះ។ ក្រឹត្យច្បាប់នេះគួរមានចែងផងដែរអំពីបែបបទសំរាប់ដាក់ឱ្យអនុវត្តគោលការណ៍បង់ថ្លៃប្រើប្រាស់ក្នុងស្ថានភាពដែលគំរោងថាមពលទទួលប្រយោជន៍ពីតំបន់ការពារធម្មជាតិ។ ការពិនិត្យឡើងវិញនៃPADនេះបញ្ជាក់ថា ត្រូវឱ្យមានការសិក្សាជីវៈចំរុះ និងការវាយតំលៃហេតុប៉ះពាល់បរិស្ថានមុនពេលមានការធ្វើសេចក្តីសំរេចលើគំរោងវិនិយោគ ហើយជំហានដំបូងគឺស្ថាប័ន និងក្រុមហ៊ុនដែលលើកសំនើគំរោងវិនិយោគ ត្រូវធានាឱ្យមានការពាក់ព័ន្ធយ៉ាងពេញលេញពីសំណាក់ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម-រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងក្រសួងស្ថាប័នពាក់ពន្ធ័ ចាប់តាំងពីនៅក្នុងដំណាក់កាលដំបូងនៃដំនើរកសាងផែនការ។

***ឯកឧត្តម លោក លោកស្រី ជាទីស្នេហា !***

លើសពីនេះក្នុងនាមជាគោលនយោបាយគ្រឹះ ការពិនិត្យឡើងវិញនៃ PADសន្និដ្ឋានថាគំរោងថាមពលវារីអគ្គីសនី គួរតែធ្វើការ "ទូទាត់" ចំពោះសហគមន៍មូលដ្ឋាន និងប្រព័ន្ធអេកូឡូស៊ី ដោយផ្តល់ការវិនិយោគឡើងវិញលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ។ ការទូទាត់បែបនេះត្រូវរាប់បញ្ចូលផងដែរលើការបង់ថ្លៃសំរាប់ ការស្តារនីតិសម្បទាសហគមន៍។

របាយការណ៍ PAD អំពីប្រទេសកម្ពុជាបញ្ជាក់ថា គំរោងអភិវឌ្ឍន៍ និងគំរោងថាមពលវារីអគ្គិសនី គួរតែត្រូវកសាង និងដាក់ឱ្យដំនើរការអនុលោមតាមគោលការណ៍បីជាសំខាន់ :

១. រាល់ផ្នែកនានានៃគំរោងថាមពលវារីអគ្គិសនីគួរបង់ថ្លៃសំរាប់សេវាប្រព័ន្ធអេកូឡូស៊ី និងសំរាប់ទូទាត់ចំពោះការបង្ក ឱ្យខូចខាតដល់សេវាប្រព័ន្ធអេកូឡូស៊ីទាំងនោះ ។

២. ក្នុងករណីដែលសេវាទាំងនោះត្រូវបានផ្តល់ ដោយផ្នែក ឬទាំងស្រុង ដោយតំបន់ការពារធម្មជាតិ ចំណូលពីការបង់ថ្លៃបែបនោះ គួរតែយកទៅប្រើប្រាស់សំរាប់ស្តារ ថែទាំ និងការពង្រឹងប្រព័ន្ធធម្មជាតិដែលបានការពារនោះ ។

៣. រាល់ការអភិវឌ្ឍន៍គួរតែនាំមកនូវផលចំណេញសុទ្ធសំរាប់ជីវភាព និងសុខុមាលភាពក្នុងមូលដ្ឋាន តាមរូបភាពដែលរួមវិភាគទានចំពោះការពាក់ព័ន្ធ និងពង្រឹងកិច្ចចូលរួមពាក់ព័ន្ធនៃសហគមន៍មូលដ្ឋាន នៅក្នុងការអភិរក្សសេវា និងផលិតផលពីប្រព័ន្ធអេកូឡូស៊ី ។

ទាំងនេះគឺជាប្រភេទគោលនយោបាយ ដែលខ្ញុំចង់ធ្វើការសិក្សាជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងធ្វើការសាកល្បងនៅក្នុងតំបន់មួយចំនួន ។ ការអនុវត្តន៍គោលនយោបាយទាំងនេះត្រូវធ្វើឡើងឱ្យស្របគ្នាជាមួយនឹងការវាយតំលៃសេដ្ឋកិច្ចនិងការចាត់ចែងគ្រប់គ្រងមូលនិធិ ដូចដែលឯកឧត្តម ហង់ជួន ណារ៉ុង បានបង្ហាញជូន ។

ការពិនិត្យឡើងវិញនៃ PAD បានស្នើឱ្យក្រសួងបរិស្ថានរៀបចំកិច្ចព្រមព្រៀងជាមួយវិស័យចំបងៗនៃរដ្ឋាភិបាល ដើម្បីជួយវិស័យទាំងនោះពិចារណា តាមរយៈការទទួលខុសត្រូវគ្រប់គ្រងបរិស្ថាន និងទំនាក់ទំនងជាមួយតំបន់ការពារធម្មជាតិ និងដើម្បីកំនត់គោលនយោបាយ និងនីតិវិធីសមស្រប ។ ខ្ញុំសូមគាំទ្រយ៉ាងពេញទំហឹងចំពោះអនុសាសន៍នេះ ។ វិស័យនានា ដូចជាថាមពលវារីអគ្គិសនីដែលក្នុងនោះ "អ្នកប្រើប្រាស់" ពិតជាទទួលប្រយោជន៍ពីសេវាប្រព័ន្ធអេកូឡូស៊ី ដូចជា និយ័តកម្មទឹក និងការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងសំណឹក និងមុខនាទីផ្សេងទៀតនៃការគ្រប់គ្រងទីជំរាល គឺជា ចំនុចសមស្របសំរាប់ចាប់ផ្តើមពិចារណាអនុវត្ត ។

ទីបញ្ចប់នេះ ក្រសួងបរិស្ថាននឹងខិតខំជំរុញការអនុវត្តន៍តាមរបាយការណ៍ជាតិពិនិត្យឡើងវិញនៃ PAD ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ ខ្ញុំចង់ឃើញក្រុមការងារអន្តរវិស័យ ដែលត្រួតត្រាដំណើរការពិនិត្យឡើងវិញនេះ កំណត់សកម្មភាពជាអាទិភាពរបស់ខ្លួនឱ្យបានច្បាស់លាស់ និងបន្តសកម្មភាពរបស់ខ្លួនតទៅមុខទៀត ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលនៃប្រទេសអូស្ត្រាលី ដាណឺម៉ាក់ និងស្វ៊ីស ចំពោះការគាំទ្រហិរញ្ញវត្ថុចាំបាច់សំរាប់ការពិនិត្យឡើងវិញនេះ និងសូមអំពាវនាវឱ្យរដ្ឋាភិបាលនៃប្រទេសទាំងនោះបន្តកម្មវិធី PAD ដើម្បីអនុវត្តតាមរបាយការណ៍ជាតិនេះ ។ ប្រការសំខាន់គឺភាពជាដៃគូ PAD អាចបន្តសកម្មភាពរបស់ខ្លួនជាមួយស្ថាប័ន បច្ចេកទេសនានា ដូចជា UNDP និង MRC ដោយធ្វើការរួមគ្នាជាមួយបណ្តាអង្គការអភិរក្សលើបណ្តាអាទិភាពរួម ដែលបាន កំនត់ឃើញតាមរយៈការពិនិត្យឡើងវិញនៃ PAD នេះ ។

ខ្ញុំសូមជូនពរដល់ឯកឧត្តម លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលមានវត្តមានក្នុងឱកាសនេះ ប្រកបដោយសិរីសួស្តី វិបុលសុខ ព្រមទាំងពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀង ឃ្លាតឡើយ ។

ខ្ញុំសូមអនុញ្ញាត ប្រកាសអោយប្រើប្រាស់របាយការណ៍ PADចាប់ពីពេលនេះតទៅ ។

**សូមអរគុណ**



# បាឋកថាគន្លឹះ
# ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន
# និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចំរុះ
# ថ្លែងក្នុងឱកាស "ទិវាជីវៈចំរុះអន្តរជាតិ"
# ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៤
# នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (មណ្ឌល២)

**សូមគោរព !**

ឯកឧត្តម **ចំរូង ឥុងម៉ុច** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឯកឧត្តម **ពិត ចំណាន** សាកលវិទ្យាធិការ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

**Mr. Ladistaus Beyenkya-Abwooli** តំណាងអង្គការ UNDP

ឯកឧត្តម អស់លោក លោកស្រី នាងកញ្ញា និស្សិត ភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី

តាងនាមអោយថ្នាក់ដឹកនាំក្រសួងបរិស្ថាន/គណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចំរុះ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយជាអនេក ដែលបានមកធ្វើជាអធិបតីក្នុងពិធី "*ទិវាជីវៈចំរុះអន្តរជាតិ*" នាថ្ងៃនេះ ។ ឧទ្ទិមនឹងនេះ ខ្ញុំសូមយកឱកាសនេះថ្លែងអំណរគុណដល់ ឯកឧត្តម អស់លោក លោកស្រី នាងកញ្ញា និស្សិត ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ដែលមានវត្តមាននាពេលនេះ ។ ការចូលរួមនេះជាសក្ខីភាពមួយផ្ទុះបញ្ចាំងនូវកិច្ចសហការគ្នាយ៉ាងល្អរវាងក្រសួងបរិស្ថាន ស្ថាប័នពាក់ព័ន្ធ បណ្ណមហាជន ស្ថាប័នឯកជន គ្រឹះស្ថានឧត្តមសិក្សា អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលនានា ដែលមានកាតព្វកិច្ចក្នុងការគ្រប់គ្រង និងការពារជីវៈចំរុះនៅប្រទេសកម្ពុជាប្រកបដោយចិរភាព ។

ជីវៈចំរុះជាធនធានដែលមានសារៈសំខាន់សំរាប់ការរស់រានរបស់មនុស្ស និងដើរតួដ៏សំខាន់ក្នុងការគាំទ្រការអភិវឌ្ឍប្រកបដោយនិរន្តរភាព ហើយនិងការលុបបំបាត់ចោលភាពក្រីក្រ ។ ការថែរក្សាជីវៈចំរុះគឺវាមិនមែនជាការងារសំរាប់ស្ថាប័នរដ្ឋាភិបាលតែឯងប៉ុណ្ណោះទេ ចំពោះអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា ផ្នែកឯកជន សហគមន៍មូលដ្ឋាន បុគ្គលម្នាក់ៗ និងគ្រប់រូប ក៏មានតួនាទីដ៏សំខាន់ក្នុងការចូលរួមចំណែកការពារ និងបញ្ចប់ការបំផ្លិចបំផ្លាញជីវៈចំរុះផងដែរ ។

ដើម្បីការពារជីវៈចំរុះនៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចំរុះ ក្នុងគោលបំណងដើម្បីពិភាក្សា ផ្តល់យោបល់ និងពិនិត្យមើលយុទ្ធសាស្ត្រ និងផែនការសកម្ម

ថ្នាក់ជាតិស្តីពីការអភិរក្សការប្រើប្រាស់ ការការពារ និងការគ្រប់គ្រងជីវៈចំរុះ ដើម្បីការអភិវឌ្ឍន៍ប្រកបដោយចិរភាពបរិស្ថាននៅកម្ពុជា ។ គណៈកម្មាធការនេះជាតិនេះមានសមាសភាព : ក្រសួងបរិស្ថាន, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងផែនការ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងទេសចរណ៍, ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, ក្រសួងសាធារណៈការ និង ដឹកជញ្ជូន, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងពាណិជ្ជកម្ម, ក្រសួងសុខាភិបាល, គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងខេត្ត-ក្រុងពាក់ព័ន្ធ ។

ក្រសួងបរិស្ថានចាំបាច់ត្រូវមានកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ បណ្តាមហាជន ស្ថាប័នឯកជន គ្រឹះស្ថានឧត្តមសិក្សា អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីចូលរួមការពារ និងគ្រប់គ្រងជីវៈចំរុះនៅក្នុងប្រទេសកម្ពុជា ដែលកំពុងទទួលរងនូវការគំរាមកំហែង ។ គួបផ្សំនឹងកំណើនប្រជាជន ការគំរាមកំហែងទាំងនេះអាចនឹងបង្កើនអត្រានៃការបាត់បង់ជីវៈចំរុះ ។ នៅពេលដែលជីវៈចំរុះកាន់តែច្រើនត្រូវបាត់បង់ គេកាន់តែមានការលំបាកថែមទៀត ក្នុងការកំណត់មាគ៌ាឆ្ពោះទៅការអភិវឌ្ឍប្រកបដោយចិរភាព និងភាពរុងរឿងនាពេលអនាគត សំខាន់ជាងនេះទៀតគឺគេនឹងកាន់តែមានការលំបាក ក្នុងការធានារក្សាសន្តិសុខស្បៀង និងមុខងារប្រព័ន្ធអេកូឡូស៊ី ដែលជាមូលដ្ឋានទ្រទ្រង់គុណភាពនៃការរស់នៅ ។ ភាពក្រីក្ររបស់ប្រជាជនបានជំរុញអោយពួកគាត់ មានការប្រើប្រាស់នូវធានធានជីវៈចំរុះកាន់តែច្រើន ។ ភាពក្រីក្រមិនមែនជាឬសគល់តែមួយនៃការបំផ្លិចបំផ្លាញជីវៈចំរុះប៉ុណ្ណោះទេ ប៉ុន្តែនិន្នាការនៃការរីកចំរើនសេដ្ឋកិច្ច ក៏ជាឬសគល់នៃការបំផ្លិចបំផ្លាញជីវៈចំរុះផងដែរ ។ ដូច្នេះការអភិវឌ្ឍសេដ្ឋកិច្ចដ៏ឆ្លាតវៃត្រូវតែធ្វើសមាហរណកម្មជាមួយកម្មវិធីកាត់បន្ថយភាពក្រីក្រ ដើម្បីធានានូវកិច្ចការពារការអភិរក្សនៃជីវៈចំរុះ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រកបដោយចិរភាព ។ បច្ចុប្បន្ននេះដោយសារភាពរីកចំរើននៃជីវៈបច្ចេកវិទ្យាដែលបានផ្តល់នូវសារៈសំខាន់ជាច្រើន ប៉ុន្តែព្រមជាមួយគ្នានេះវាក៏អាចបង្កអោយមានគ្រោះថ្នាក់យ៉ាងច្រើនផងដែរ ជាពិសេសចំពោះបរិស្ថាន និងជីវៈចំរុះប្រសិនបើយើងប្រើប្រាស់វាមិនបានល្អ ។

រាជរដ្ឋាភិបាលកម្ពុជា និងអង្គការអន្តរជាតិនានា បានទទួលស្គាល់នូវសារៈសំខាន់នៃជីវៈចំរុះក្នុងប្រទេសកម្ពុជា និងកំពុងបង្ហាញនូវការចាប់អារម្មណ៍កាន់តែខ្លាំងឡើង ក្នុងការអនុវត្តន៍សកម្មភាពដែលអាចកាត់បន្ថយការគំរាមកំហែងចំពោះជីវៈចំរុះ សកម្មភាពជាច្រើនដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន ផ្តោតជាពិសេសលើទំនាក់ទំនងចំបងរវាងជីវៈចំរុះ និងការអភិវឌ្ឍន៍ដោយចិរភាព ព្រមជាមួយនឹងការលើកទឹកចិត្តអោយមានកិច្ចការពារសមាសភាគសំខាន់ៗ ដែលតំណាងអោយជីវៈចំរុះក្នុងប្រទេស ។ វិធីសាស្ត្របែបនេះនឹងជួយធានាសមត្ថភាពស្ថាប័ន និងប្រជាជនកម្ពុជា ដើម្បីប្រើប្រាស់ ការពារ និងគ្រប់គ្រងជីវៈចំរុះ សំរាប់ការអភិវឌ្ឍន៍ដោយចិរភាព និងភាពរុងរឿងទៅអនាគត ។

**ឯកឧត្តម អស់លោក លោកស្រី នាងកញ្ញា និស្សិត ភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី!**



ភ្ញៀវកិត្តិយស និងសមាជិកសមាជិកា
ដែលបានអញ្ជើញចូលរួម
នាឱកាសប្រារព្ធពិធី

ឆ្លងតាមរយៈ " ***ទិវាជីវៈចំរុះអន្តរជាតិ*** " ដែលមានប្រធានបទថាៈ ជីវៈចំរុះទ្រទ្រង់ជាចំណីអាហារ ទឹក និងសុខភាព ។ ឫសគល់នៃចំណុចទាំងបីនេះៈ ចំណីអាហារ ទឹក និងសុខភាព ផ្សារភ្ជាប់យ៉ាងជិតស្និតជាមួយ ជីវៈចំរុះ ។ ជីវចំរុះបង្កើតនូវចំណីអាហារ ទឹកទ្រទ្រង់ជីវៈចំរុះឱ្យមានជីវិត ជីវៈចំរុះជាប្រភពនៃឱសថបុរាណ និង ធនធានសេនេទិចសំរាប់ផលិតឱសថទំនើបសំរាប់ព្យាបាល និងទ្រទ្រង់សុខភាពមនុស្ស ។ ដូច្នេះយើងឃើញថាៈ តំលៃនៃជីវៈចំរុះមានសារៈសំខាន់ណាស់ក្នុងការទ្រទ្រង់ជីវិតមនុស្ស និងភពផែនដី ដែលយើងទាំងអស់គ្នាចាំបាច់ ត្រូវតែចូលរួមការពារឱ្យបានគង់វង្ស ។ នៅថ្ងៃនេះខ្ញុំសង្ឃឹមយ៉ាងមុតមាំថាៈ បណ្ដាស្ថាប័នពាក់ព័ន្ធ បណ្ដាមហា ជននានា ស្ថាប័នឯកជន គ្រឹះស្ថានឧត្ដមសិក្សា អង្គការអន្ដរជាតិនានា អង្គការក្រៅរដ្ឋាភិបាល នឹងបានយល់ពី សារៈសំខាន់នៃជីវៈចំរុះ ព្រមទាំងរួមចំណែកយ៉ាងសកម្មក្នុងការការពារ អភិរក្សជីវៈចំរុះនៅក្នុងប្រទេសកម្ពុជា និង បញ្ឈប់ការបាត់បង់ធនធានជីវៈចំរុះ ដូចបានឯកភាពនៅក្នុងសេចក្ដីសំរេចនៃកិច្ចប្រជុំCOP7ត្រឹមឆ្នាំ២០១០ និងការ ធានាដល់មុខងារបន្តនៃប្រព័ន្ធអេកូឡូស៊ីភពផែនដី គួរតែផ្ដល់អាទិភាពខ្ពស់សំរាប់មនុស្សគ្រប់គ្នា ។ ក្នុងទិវា ជីវៈចំរុះអន្ដរជាតិនេះ ខ្ញុំសូមឱ្យយើងទាំងអស់គ្នាចងចាំពាក្យមួយឃ្លាថា " ***ជីវៈចំរុះជាអាយុជីវិតរបស់យើង និង ពិភពលោកទាំងមូល*** " ប្រសិនបើគ្មានជីវៈចំរុះ ជីវិតនៅលើភពផែនដីក៏ពុំមានដែរ ។

ជាថ្មីម្ដងទៀតក្នុងនាមថ្នាក់ដឹកនាំក្រសួងបរិស្ថាន/គណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចំរុះ និងក្នុងនាមខ្លួនខ្ញុំ ផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការ **UNDP, WWF** និងស្ថាប័នផ្សេងៗដែលបានជួយគាំទ្រតិចក្ដី ច្រើនក្ដី ក្នុងការរៀបចំ " ***ទិវាជីវៈចំរុះអន្តរជាតិ*** " នាពេលនេះ ។

ជាទីបញ្ចប់នេះ ខ្ញុំសូមប្រសិទ្ធិពរជ័យដល់ ឯកឧត្ដម អស់លោក លោកស្រី នាងកញ្ញា និស្សិត ភ្ញៀវជាតិ និងអន្ដរជាតិ ដែលបានអញ្ជើញចូលរួមក្នុងទិវានេះអោយជួបប្រទះនឹងសេចក្ដីសុខគ្រប់ប្រការគឺ អាយុៈ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ ។ **សូមអរគុណ !**

# សុន្ទរកថា

# ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន

# ក្នុងពិធីបើកសិក្ខាសាលា ស្តីពី

## " ការវាយតំលៃពីបញ្ហា POPs ក្នុងដំណើរការរៀបចំផែនការជាតិ សំរាប់អនុវត្តន៍អនុសញ្ញា ស្តុកខូម ស្តីពី សារធាតុបំពុលសរីរាង្គមិនបំបែកធាតុ "

**ថ្ងៃទី ២-៤ ខែមិថុនា ឆ្នាំ២០០៤**

**សណ្ឋាគារ ជូលីណា**




**-សូមគោរពដល់អង្គសិក្ខាសាលា**

**-សូមស្វាគមន៍ដល់ឯកឧត្តម អស់លោក លោកស្រីនិងតំណាងចូលរួមទាំងអស់ជាទីមេត្រី !**

នៅក្នុងទិវាដ៏ប្រសើរនេះ ខ្ញុំមានកិត្តិយសនិងបីតិសោមនស្សរីករាយយ៉ាងក្រៃលែងដោយបានមកចូលរួមក្នុងពិធីបើកសិក្ខាសាលាស្តីពី " **ការវាយតំលៃពីបញ្ហា POPs ក្នុងដំណើរការរៀបចំផែនការជាតិសំរាប់**

**អនុវត្តន៍អនុសញ្ញា ស្តុកខូម ស្តីពីសារធាតុបំពុលសរីរាង្គមិនបំបែកធាតុ** ” ។ ឆ្លៀតក្នុងឱកាសនេះ តាងនាមឱ្យក្រសួងបរិស្ថាន និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដល់មូលនិធិបរិស្ថានពិភពលោក **(GEF)** ដែលបានផ្តល់ជំនួយគាំទ្រ ដើម្បីជួយពង្រឹងសមត្ថភាពកម្ពុជាក្នុងការរៀបចំផែនការជាតិសំរាប់បំពេញកាតព្វកិច្ចនៅក្រោមអនុសញ្ញា ស្តុកខូម **(National Plans for Implementation of the Stockholm Convention on POPs)** ហើយក៏សូមវាយតំលៃយ៉ាងខ្ពស់ដល់កិច្ចសហការជាដៃគូរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ **(UNEP)** ក្នុងការជួយ សំរបសំរួលផ្នែកបច្ចេកទេសដល់ការអនុវត្តន៍គំរោងនេះផងដែរ ។ ជាមួយគ្នានេះ ជូនសមុខឱ្យក្រសួងបរិស្ថាន ខ្ញុំសូមថ្លែងអំណរគុណដល់លោកស្រី **Katarina Magulova** អ្នកឯកទេសអន្តរជាតិ ដែលបានអញ្ជើញមកចូលរួមជាអ្នកសំរបសំរួលដល់ដំណើរការវាយតំលៃពីបញ្ហា **POPs** នៅកម្ពុជា ។ ទន្ទឹមនេះ ខ្ញុំមានមោទនភាពយ៉ាងខ្លាំង ដោយមានឱកាសជាថ្មីបានមកជួបជាមួយ ឯកឧត្តម អស់លោក លោកស្រី ដែលជាសមាជិកអនុគណៈកម្មាធិការ សំរបសំរួលការអនុវត្តន៍អនុសញ្ញា ស្តុកខូម និងមន្ត្រីបច្ចេកទេសអញ្ជើញមកពីស្ថាប័នពាក់ព័ន្ធ វិទ្យាស្ថានស្រាវជ្រាវគំរោងពាក់ព័ន្ធអង្គការអន្តរជាតិ និងតំបន់ដែលជានិច្ចជាកាលតែងបានចូលរួមសហការ និងផ្តល់ដល់ការគាំទ្រដល់កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ឯកឧត្តម អស់លោក លោកស្រី និងតំណាងចូលរួមទាំងអស់ជាទីមេត្រី !

ជាការពិតណាស់ ការរីកចំរើននូវសេដ្ឋកិច្ចសង្គម គឺមិនអាចផ្តាច់ចេញពីភាពសំបូរបែបនៃការប្រើប្រាស់នូវសារធាតុគីមីបានឡើយ ។ ជាក់ស្តែងសារធាតុគីមីច្រើនប្រភេទត្រូវបានប្រើប្រាស់ក្នុងវិស័យកសិកម្ម សំរាប់ការពារ និងបង្កើនទិន្នផលដំណាំ ក្នុងវិស័យឧស្សាហកម្មសំរាប់បំរើការងារផលិតកម្ម ក្នុងវិស័យសុខាភិបាលសំរាប់ព្យាបាល និងលើកកំពស់សុខមាលភាព ក្នុងវិស័យគមនាគមន៍សំរាប់សាងសង់និងគាំទ្រដំណើរការដឹកជញ្ជូន ។ល។ ហេតុដូចនេះ ទើបនៅក្នុងមួយឆ្នាំៗ គឺមានសារធាតុគីមីប្រមាណជាង ១០០០ ប្រភេទត្រូវបានគេផលិតថ្មីនិងនាំចូលមកលក់នៅលើទីផ្សារអន្តរជាតិ ។ ជាលទ្ធផលក្រៅពីជួយជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និងភាពសំបូរបែបនូវ ផលិតផលនិងសំភារៈប្រើប្រាស់ដែលជាតំរូវការ ក្នុងជីវភាពសង្គម ភាពនិយម និងកំណើននៃការប្រើប្រាស់សារធាតុគីមីទាំងនោះ គឺបានបន្សល់នូវផលវិបាកជា ច្រើនដល់មនុស្សជាតិ និងសង្គមជំនាន់ក្រោយ ដូចជាបញ្ហាបំពុលបរិស្ថាន ដោយសំណល់ជាតិគីមីពុល ភាពកំណើនជាតិសំណល់គីមីនៅក្នុងអាហារ ការប៉ះពាល់ដល់សុខភាពមនុស្សដោយការទទួលរងនូវជាតិគីមីពុល ។ល។ បទពិសោធន៍នៃបញ្ហាបំពុលទាំងនេះ គឺបានផ្តល់ជាមេរៀនប្រវត្តិសាស្ត្រយ៉ាងជូរចត់ដល់ប្រទេសមួយចំនួន ដូចជាប្រទេសជប៉ុន

(បញ្ហាជំងឺមីណាម៉ាតា) ប្រទេសកូរ៉េខាងត្បូង និងប្រទេសបង់ក្លាដែសជាដើម ។ ពិសេស នៅក្នុងអំឡុង ២ ទសវត្សចុងក្រោយនេះ ភាពលេចចេញនូវគ្រោះថ្នាក់ទៅលើសុខភាព និងបរិស្ថាន ដូចជាទារកដែលកើតមក មិនគ្រប់លក្ខណៈ ភាពលេចចេញនូវរោគសញ្ញាប្លែកៗដែលមានលក្ខណៈរ៉ាំរ៉ៃ និងធ្ងន់ធ្ងរភាពថយចុះនូវលទ្ធ-ភាពបន្តពូជពពួកជីវៈចំរុះ ។ល។ ដែលបង្កដោយពពួកសារធាតុបំពុលប្រភេទសរីរាង្គមិនបំបែកធាតុ (Persistent Organic Pollutants, POPs) បានធ្វើឱ្យសហគមន៍អន្តរជាតិខិតខំរួមគ្នាដើម្បី ចាត់វិធានការលុបបំបាត់ POPs តាមរយៈការដាក់ចេញនូវវិធានច្បាប់អន្តរជាតិគឺអនុសញ្ញា ស្តុកខូម ដែលបាន ដាក់ឱ្យចុះហត្ថលេខានាខែឧសភា ២០០១ និងបានចូលជាធរមានកាលពីថ្ងៃទី ១៧ ឧសភា ២០០៤ កន្លងមកនេះ ។

## ឯកឧត្តម អស់លោក លោកស្រី និងតំណាងចូលរួមទាំងអស់ជាទីមេត្រី !

ថ្វីត្បិតតែ កម្ពុជាមិនទាន់បានធ្វើសច្ចាប័នចូលជាសមាជិកនៃអនុសញ្ញា ស្តុកខូម ប៉ុន្តែរាជរដ្ឋាភិបាល កម្ពុជា ដែលមានក្រសួងបរិស្ថានជាអ្នកសំរបសំរួល តែងបានគិតគូរទៅដល់ការរៀបចំនូវកម្មវិធីគ្រប់គ្រង ប្រកបដោយសុវត្ថិភាពបរិស្ថាននូវសារធាតុគីមីពុល ពិសេសសារធាតុ POPs ហើយជាលទ្ធផលគំរោងពង្រឹង សមត្ថភាពរៀបចំផែនការជាតិសំរាប់អនុវត្តន៍អនុសញ្ញា ស្តុកខូម ត្រូវបានចាប់ផ្តើមពីខែសីហា ២០០៣ ហើយដែលលទ្ធផលមួយចំនួនត្រូវបានសំរេចតាមផែនការគំរោង ដូចដែលលោក **ជា ស៊ីណា** អ្នកសំរបសំរួល គំរោងបានសង្ខេបជូន ដូចជាបានបញ្ចប់សេចក្តីព្រាងកំរងពតិមានជាតិស្តីពីការគ្រប់គ្រងសារធាតុគីមី និងបាន បញ្ចប់ការធ្វើសារពើភ័ណ្ឌសារធាតុ POPs ។ ជាការពិតណាស់ យើងនៅមានការងារជាច្រើនដែលត្រូវបំពេញ ដើម្បីឈានទៅសំរេចទទួលបាននូវផែនការជាតិសមស្របមួយសំរាប់ត្រៀមអនុវត្តន៍អនុសញ្ញា ស្តុកខូម ហើយ ដែលនៅក្នុងសិក្ខាសាលានេះ ប្រធានបទស្តីពីការវាយតំលៃពីបញ្ហា POPs រួមមាន ការវាយតំលៃពីស្ថាប័ន និងក្របខ័ណ្ឌច្បាប់គ្រប់គ្រងសារធាតុ POPs ការវាយតំលៃពីសេដ្ឋកិច្ចសង្គមទាក់ទងការលុបបំបាត់សារធាតុ POPs ការវាយតំលៃពីផលប៉ះពាល់លើបរិស្ថាន សុខភាពមនុស្សដោយសារធាតុ POPs និងការវាយតំលៃ ពីការយល់ដឹងជាសាធារណៈពីបញ្ហាសារធាតុ POPs ។

ជាទស្សនៈខ្ញុំផ្ទាល់ ខ្ញុំយល់ថាការវាយតំលៃពីបញ្ហាសារធាតុ POPs គឺជាចំនុចគន្លឹះដ៏សំខាន់ដែល អាចធ្វើឱ្យយើងកំណត់បានពីចំនុចខ្លាំង និងចំនុចខ្វះខាត ព្រមទាំងកំណត់បានពីបញ្ហានានាដែលបង្កដោយសារ ធាតុ POPs ហើយជាលទ្ធផល នឹងធ្វើឱ្យយើងអាចកំណត់ពីវិធានការដែលត្រូវដាក់ចេញដើម្បីកាត់បន្ថយ និងលុបបំបាត់បញ្ហា POPs តាមរយៈផែនការសកម្មភាពជាតិដែលគំរោងត្រូវរៀបចំនៅក្នុងជំហានបន្ត ។

ដូចនេះ ខ្ញុំសូមស្នើដល់ ឯកឧត្តម លោក លោកស្រី និងតំណាងចូលរួមទាំងអស់ ត្រូវយកចិត្តទុកដាក់ទទួលយកនូវបទពិសោធន៍ក្នុងការវាយតំលៃពីបញ្ហា POPs ដែលនឹងត្រូវបង្ហាញដោយលោកស្រី **Katarina Magulova** អ្នកឯកទេសអន្តរជាតិ សំរាប់ជាមូលដ្ឋានក្នុងការពិភាក្សាឆ្លុះបង្ហាញ និងកំណត់ពីបញ្ហាសារធាតុ POPs នៅកម្ពុជា ។ ទន្ទឹមនេះ ខ្ញុំក៏សូមស្នើឱ្យមានការចូលរួមអោយបានសកម្មក្នុងការពិភាក្សាផ្តល់យោបល់នៅលើប្រធានបទទាំង ៤ ខាងលើ ពីព្រោះនេះគឺជាឱកាសទី ១ របស់កម្ពុជាក្នុងការវាយតំលៃពីចំនុចខ្វះខាត និងបញ្ហាដែលទាក់ទងទៅនឹងសារធាតុ POPs ដើម្បីកំណត់ឱ្យបាននូវអ្វីដែលជាបញ្ហាប្រឈមរបស់កម្ពុជាដែលទាក់ទងនឹងការប្រើប្រាស់សារធាតុ POPs ហើយអ្វីជាតំរូវការចាំបាច់របស់កម្ពុជាសំរាប់ដោះស្រាយបញ្ហាទាំងនោះ ។

## ឯកឧត្តម អស់លោក លោកស្រី និងតំណាងចូលរួមទាំងអស់ជាទីមេត្រី !

តាមរយៈសិក្ខាសាលារយៈពេល ៣ថ្ងៃនេះ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា យើងអាចនឹងកំណត់បាននូវការវាយតំលៃដ៏ជាក់លាក់មួយពីបញ្ហាសារធាតុ POPs នៅកម្ពុជា ដែលជាមូលដ្ឋានក្នុងឈានទៅកំណត់វិធានការច្បាប់ និងរដ្ឋបាលសំរាប់គ្រប់គ្រងសារធាតុ POPs ប្រកបដោយសុវត្ថិភាពបរិស្ថានដែលវាជាការចូលរួម ចំណែករបស់កម្ពុជាជាមួយសហគមន៍អន្តរជាតិក្នុងការការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈឱ្យជៀសផុត ពីគ្រោះថ្នាក់ដែលបង្កដោយសារធាតុ POPs ។

ជាថ្មីម្តងទៀត តាងនាមឱ្យក្រសួងបរិស្ថាន ខ្ញុំក៏សូមថ្លែងអំណរគុណដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ដែលបានផ្តល់កិច្ចសហការល្អជាមួយក្រសួងបរិស្ថានក្នុងការត្រៀមលក្ខណៈអនុវត្តន៍កាតព្វកិច្ចក្រោមអនុសញ្ញាស្តុកខូម ពិសេសការចូលរួមយ៉ាងសកម្មក្នុងការអនុវត្តន៍គំរោងពង្រឹងសមត្ថភាពនេះ ។ ទន្ទឹមនេះ ខ្ញុំសូមវាយតំលៃយ៉ាងខ្ពស់ ដល់ការចូលរួមរបស់អ្នកឯកទេសជាតិ និងអន្តរជាតិមកផ្តល់បទពិសោធន៍ដ៏មានសារៈប្រយោជន៍ទាក់ទងទៅនឹងការប្រើប្រាស់ និងគ្រប់គ្រងសារធាតុគីមី ពិសេសសារធាតុបំពុលសរីរាង្គមិនបំបែកធាតុ **(POPs)** ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ឯកឧត្តម អស់លោក លោកស្រី នាងកញ្ញា និងតំណាងចូលរួមទាំងអស់សូមជួបប្រទះតែសេចក្តីសុខនិងចំរើនគ្រប់ប្រការ និងសូមប្រសិទ្ធពរឱ្យអង្គសិក្ខាសាលានេះប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងសូមអនុញ្ញាតប្រកាសបើកអង្គសិក្ខាសាលា ស្តីពី **ការវាយតំលៃពីបញ្ហាសារធាតុ POPs ក្នុងដំណើរការរៀបចំផែនការជាតិសំរាប់អនុវត្តអនុញ្ញា ស្តុកខូម** ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ !**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សុន្ទរកថាបើក

## របស់ឯកឧត្តម បណ្ឌិត ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន
## និងជាប្រធានគណៈកម្មាធិការជាតិ សំរបសំរួលតំបន់ឆ្នេរសមុទ្រ

ថ្លែងបើកក្នុងសិក្ខាសាលាថ្នាក់ជាតិលើកទី ៤ ស្ដីពីការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ

ថ្ងៃទី ១-៣ ខែ មេសា ឆ្នាំ ២០០៤

នៅសណ្ឋាគារខ្សាច់មាស ក្រុងព្រះសីហនុ




**សូមគោរព:**

- **ឯកឧត្តម កែវ ខេមរា អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
- **ឯកឧត្តម ឌិក សាខុន អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តម ឌូឡេន ឡៅម៉ែន គ្រីស្ដេនសិន កុលស៊ុល និងជាតំណាងនៃព្រះរាជាណាចក្រដាណឺម៉ាក់**
- **ឯកឧត្តម រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អភិបាលខេត្ត-ក្រុងតំបន់ឆ្នេរ**
- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីស្នេហា!**

ថ្ងៃនេះ តាងនាមឱ្យក្រសួងបរិស្ថាន និងគណៈកម្មាធិការជាតិសំរបសំរួលតំបន់ឆ្នេរ ខ្ញុំមានសេចក្តីសោមនស្ស រីករាយឥតឧបមា ដែលបានចូលរួមជាអធិបតីក្នុងពិធីបើកសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការគ្រប់គ្រងតំបន់ឆ្នេរ សមុទ្រ ។ ខ្ញុំសូមសំដែងបដិសណ្ឋារកិច្ចដ៏កក់ក្តៅដល់ ឯកឧត្តម មូហ្គេន អគ្គកុលស៊ុល នៃព្រះរាជាណាចក្រដាណឺម៉ាក់ ឯកឧត្តម លោកជំទាវ អស់លោក លោក ស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ដែលសុទ្ធសឹងតែពាក់ព័ន្ធនឹង ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ដែលបានចូលរួម ក្នុងអង្គសិក្ខាសាលាដ៏មានសារៈសំខាន់ នេះ ។

តំបន់ឆ្នេរសមុទ្រកម្ពុជាពោរពេញទៅដោយធនធានជីវចំរុះ និងធនធានប្រព័ន្ធអេកូឡូស៊ីដ៏ច្រើន ដែលមាន សក្តានុពល សំរាប់ទ្រទ្រង់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ផ្តល់សន្តិសុខស្បៀងសំរាប់ជីវភាពប្រជាជន និងជាប្រភពផ្តល់ ការងារ ព្រមទាំងជាកន្លែងផ្តល់ឱ្យការដឹកជញ្ជូន ការអភិវឌ្ឍន៍វិស័យទេសចរណ៍ កំពង់ផែ ឧស្សាហកម្ម ពាណិជ្ជកម្ម ។ ល ។ ដែលទាក់ទងទៅសង្គម វប្បធម៌ និងសកម្មភាពសេដ្ឋកិច្ចនៅក្នុងជីវភាព និងការរស់នៅប្រចាំថ្ងៃ ។ ម្យ៉ាង ទៀត មានប្រជាជនជាច្រើននៅតាមតំបន់ឆ្នេរដែលបច្ចុប្បន្ននេះ បាននឹងកំពុងពឹងផ្អែកទាំងស្រុងទៅលើធនធាន ធម្មជាតិ តាមរយៈសកម្មភាពនេសាទនៅតាមតំបន់ឆ្នេរ និងសមុទ្រ ។ ហើយនៅពេលអនាគតដ៏ឆាប់ខាងមុខនេះ ការអភិវឌ្ឍន៍វារីវប្បកម្ម ការអភិវឌ្ឍន៍ទេសចរណ៍ ការធ្វើអាជីវកម្មស្រែអំបិល បាននឹងកំពុងកើនឡើង ដើម្បីឆ្លើយ ដល់កំណើនប្រជាជន និងសកម្មភាពសេដ្ឋកិច្ច ។ សកម្មភាពទាំងអស់នេះ បាននឹងកំពុងតែធ្វើឱ្យធ្លាក់ចុះ និងការ បំផ្លាញទីជំរក ការធ្លាក់ចុះផលផល ការបំពុលតំបន់ទឹកឆ្នេរ និងសមុទ្រ និងការបាត់បង់ជីវចំរុះ និងប្រព័ន្ធអេកូឡូស៊ី រួមមាន ផ្កាថ្ម ស្មៅសមុទ្រ មច្ឆាជាតិ និងព្រៃកោងកាង ។ ហើយបញ្ហាទាំងនេះនៅតែបន្ត ដោយសារតែការធ្វើ អាជីវកម្មគ្មាននិរន្តរភាព ភាពអនាធិបតេយ្យនានា ការអនុវត្តន៍ និងការគ្រប់គ្រងពុំទាន់មានប្រសិទ្ធិភាព បញ្ហាភាព ក្រីក្ររបស់ប្រជាជន ជំលោះនានានៅក្នុងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ ការអនុវត្តន៍ច្បាប់ពុំសូវមាន ប្រសិទ្ធិភាព ដូចជា ករណីខ្លះ តួនាទីត្រួតស៊ីគ្នារវាងស្ថាប័ន ការខ្វះខាតពត៌មានទិន្នន័យនៅក្នុងការធ្វើសេចក្តី សំរេចចិត្ត ព្រមទាំងបញ្ហាខ្វះធនធានមនុស្ស នៅក្នុងការគ្រប់គ្រងធនធានធម្មជាតិតំបន់ឆ្នេរ ។

នៅក្នុងការអនុវត្តន៍គោលនយោបាយសេដ្ឋកិច្ចសង្គម ដែលមានទិសដៅកាត់បន្ថយភាពក្រីក្ររបស់ ប្រជាជន រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អទិភាពយ៉ាងខ្ពស់ដល់បញ្ហាការគ្រប់គ្រង និងការប្រើប្រាស់ប្រកបដោយចីរភាព ដែលជាគន្លឹះដ៏សំខាន់បំផុតសំរាប់ការធានាតុល្យភាព និងនិរន្តរភាពនៃការអភិវឌ្ឍន៍ រួមទាំងបរិស្ថានក្នុងតំបន់ឆ្នេរ និងសមុទ្រផង ។ រដ្ឋាភិបាលបានប្រើប្រាស់ធនធានជាច្រើនទៅក្នុងសកម្មភាពទាំងនេះ ក្នុងគោលបំណងជំរុញ ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការរីកចំរើនវិស័យសុខុមាលភាពប្រជាពលរដ្ឋ ។ ជាការពិតណាស់ ការអភិវឌ្ឍន៍ នេះត្រូវការជំនួយឧបត្ថម្ភអន្តរជាតិ និងជំនួយជាលក្ខណៈទ្វេភាគីជាច្រើន ក្នុងដំណាក់កាលខ្លី ប៉ុន្តែនៅពេលអនាគត

និងត្រូវពឹង ផ្អែកលើការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។

**ផែនការបរិស្ថានជាតិរបស់រាជរដ្ឋាភិបាល**បានកំណត់ពីគោលការណ៍ សំរាប់ការប្រើប្រាស់ធនធានធម្មជាតិ ដើម្បីធានា**អោយមាននិរន្តរភាពបរិស្ថាន** ។ ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការរីកចំរើនរបស់ប្រទេសកម្ពុជា ពឹងផ្អែកទៅលើ**សក្តានុពលភាព**នៃការប្រើប្រាស់ធនធានធម្មជាតិដែលមាននាពេលបច្ចុប្បន្ន ។ ដូច្នេះ ការប្រើប្រាស់ធនធាន និងការអភិវឌ្ឍន៍បច្ចុប្បន្នត្រូវធានាថា ធនធានធម្មជាតិនឹងឋិតនៅគង់វង្សសំរាប់មនុស្សជំនាន់ក្រោយ ។ ដើម្បីទទួលបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការរីកចំរើនសេដ្ឋកិច្ចសង្គម យើងត្រូវមានវិធានការ ធ្វើយ៉ាងណាមិនត្រូវថែទាំធនធានអោយបាន ដោយមិនត្រូវធ្វើអាជីវកម្មក្នុងរយៈពេលខ្លីនេះទេ គឺត្រូវធានាថាប្រជាជនទាំងអស់នៅក្នុងសង្គមនឹងទទួលផលប្រយោជន៍ពីការប្រើប្រាស់ធនធានទាំងនេះទៅអនាគត ។

ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើក្របខ័ណ្ឌគោលនយោបាយមួយចំនួនក្នុងការគ្រប់គ្រងតំបន់ឆ្នេរ ដែលរួមមាន :

- ការទទួលស្គាល់ចំពោះតំរូវការចាំបាច់ក្នុងគោលនយោបាយវិមជ្ឈការ ។
- គោលនយោបាយប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព រវាងតំរូវការក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ។
- តំរូវការក្នុងការធ្វើសមាហរណកម្ម ការសំរបសំរួលរវាងស្ថាប័ន ដៃគូសហការរវាងសាធារណៈ និងឯកជន ព្រមទាំងការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។

ម្យ៉ាងទៀត ទាក់ទងទៅនឹងបញ្ហាការបំពុលឆ្លងដែន ការធ្វើអន្តោប្រវេសន៍ឆ្លងដែននៃបក្សីសមុទ្រ មច្ឆាជាតិថ្នាក់តំបន់ និងអន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខា និងអនុម័តលើអនុសញ្ញាអន្តរជាតិមួយចំនួន ដូចជា MARPOL (ឆ្នាំ ១៩៩៤) អនុសញ្ញាស្តីពីជីវចំរុះ (ឆ្នាំ ១៩៩៤) អនុសញ្ញា CITES អនុសញ្ញា Ramsar (ឆ្នាំ ១៩៩៩) និងអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ (ឆ្នាំ ១៩៩៥) ។ ហើយនាពេលថ្មីៗនេះ ក្រសួងបរិស្ថានក៏បានចុះហត្ថលេខា លើសេចក្តីប្រកាសរួមស្តីពីកិច្ចសហការថ្នាក់តំបន់លើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពសមុទ្រអាស៊ីបូព៌ា ។

រាជរដ្ឋាភិបាលកម្ពុជាអោយតំលៃយ៉ាងខ្ពស់ចំពោះកិច្ចប្រឹងប្រែង និងជំនួយឧបត្ថម្ភគាំទ្រយ៉ាងសំខាន់ ដែលផ្តល់ជូនប្រទេសកម្ពុជា ដោយអ្នកផ្តល់ជំនួយទ្វេរភាគី និង អន្តរជាតិ ។ ជំនួយឧបត្ថម្ភទាំងនេះមានសារៈសំខាន់យ៉ាងខ្លាំងសំរាប់ប្រទេសកម្ពុជា ដែលថ្មីៗនេះបានប្រឈមមុខទៅនឹងការរិចរឹលធនធានធម្មជាតិជាច្រើន ជាពិសេស

ដើម្បីធានាថាមានការឆ្លើយតបចំពោះតំរូវការក្នុងការអភិវឌ្ឍន៍ ដោយគ្មានការបំផ្លិចបំផ្លាញធនធានក្នុងកំរិតខ្លាំងទេ និងរក្សាបាននូវគុណភាពបរិស្ថានខ្ពស់ ។ យុទ្ធសាស្ត្រសំខាន់ៗពីកសាងសមត្ថភាពក្នុងស្ថាប័នរដ្ឋ ដើម្បីធ្វើផែនការងគ្រប់គ្រងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនាពេលអនាគតយូរអង្វែង ។

នៅក្នុងន័យនេះ និងក្នុងបរិបទសិក្ខាសាលាថ្ងៃនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅកល់គំរោងប់គ្រងបរិស្ថានតំបន់ឆ្នេរសមុទ្រ ដែលទ្រទ្រង់ថវិកាដោយរាជរដ្ឋាភិបាលដាណឺម៉ាក់ ជាពិសេស បានជ្រើសរើសកតំបន់ឆ្នេរជាតំបន់យុទ្ធសាស្ត្រ ក្នុងការអនុវត្តគំរោងគ្រប់គ្រងតំបន់ឆ្នេរ ដែលបានផ្តល់អាទិភាពខ្ពស់លើការសាងសមត្ថភាពមន្ត្រីរាជការថ្នាក់ ខេត្ត-ក្រុង និងថ្នាក់មូលដ្ឋាន ដើម្បីបំពេញតួនាទីជាដៃគូក្នុងការគ្រប់គ្រង និងពារតំបន់នេះ។ ប្រការនេះ បានផ្តល់នូវមូលដ្ឋានដ៏រឹងមាំ សំរាប់មន្ត្រីរាជការថ្នាក់ជាតិ ថ្នាក់ខេត្ត-ក្រុង និងគមន៍មូលដ្ឋាន ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការពង្រឹងសមត្ថភាព ភាពជាម្ចាស់ការ ភាពជាអ្នកដឹកនាំ និងការទខុសត្រូវរបស់ខ្លួន ក្នុងការរក្សាបាននូវបរិស្ថាន និងធនធានធម្មជាតិល្អ ដើម្បីទ្រទ្រង់ដល់ជីភាពរស់នៅប់ខ្លួន ស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ខ្ញុំសូមកោតសរសើរចំពោះ ទីប្រឹក្សាបច្ចេកទេសទាំងអស់ ក្រុមមន្ត្រីសំរបសំរួល មន្ត្រីទំនាក់ទំនងអន្តរក្រសួងផ្ទាចរដែនដី ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្រុមការងារខេត្ត-ក្រុង និងសហគមន៍មូលដ្ឋាន ដែលបានធ្វើសហការគ្នា ដើម្បីបំពេញកតាព្វកិច្ច ការពារ និងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានតំបន់ឆ្នេរបានល្អប្រសើរ ។ ការរីកចំរើនក្នុងការសំរបសំរួល និងការធ្វើសមាហរណកម្មរវាងមន្ទីរស្ថាប័នរដ្ឋាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត និងរដ្ឋាភិបាល និងវិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន កំពុងធ្វើអោយមានការយល់ដឹងមួយ និងការយល់ដឹងអំពីតំរូវការបន្ថែមក្នុងការអភិវឌ្ឍន៍ស្ថានភាពសេដ្ឋកិច្ច និងសង្គមកម្ពុជា ដោយរក្សាធានធម្មជាតិ និងបរិស្ថានបានសមស្របល្អ ។

ខ្ញុំក៏សូមកោតសរសើរដល់លេខាធិការដ្ឋានគណៈកម្មាធិការជាតិ សំរបសំរួលតំបន់ឆ្នេរ ចំពោះការផ្តួចផ្តើមតរៀបចំសិក្ខាសាលាប្រចាំឆ្នាំដ៏សំខាន់នេះអោយមានរូបរាងឡើង ដែលផ្តល់ឱកាសអោយមានការធ្វើបទបង្ហាញពីសមិទ្ធិផលនានាដែលទាក់ទងទៅនឹងការរៀបចំក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងស្ថាប័ន ការបំពុលចេញពីដីគក ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ និងការគ្រប់គ្រងជីវចំរុះតំបន់ឆ្នេរ និងសមុទ្រ ។ គ្រប់ការធ្វើទបង្ហាញទាំងអស់នាថ្ងៃនេះ សុទ្ធសឹងជាសមិទ្ធិផលថ្មី ដែលលេចចេញពីកិច្ចខិតខំប្រឹងប្រែង និងសហការគ្នារួមដោយសហគមន៍មូលដ្ឋាន មន្ទីរ ស្ថាប័នរដ្ឋាភិបាលនៅខេត្ត-ក្រុង និងនៅថ្នាក់ជាតិ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន ។



## ភ្ញៀវជាតិ និងអន្តរជាតិព្រមទាំងសមាជិកនៃអង្គសិក្ខាសាលា បានតាមដានដោយយកចិត្តទុកដាក់របាយការណ៍ស្តីពីការគ្រប់គ្រងតំបន់ឆ្នេរ

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីស្នេហា!**

ខ្ញុំសង្ឃឹមថាបន្ទាប់ពីកិច្ចពិភាក្សានៅក្នុងសិក្ខាសាលារយៈពេល ២ ថ្ងៃនេះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ទាំងអស់នឹងអាចរកឃើញអនុសាសន៍ ដំណោះស្រាយ និងការផ្តួចផ្តើមគំនិតផ្សេងៗ ព្រមទាំងកំនត់បាននូវគំនិតយោបល់ជាមូលដ្ឋានដ៏សមស្រប ដើម្បីធានាអនុវត្តអោយបានជោគជ័យនូវគោលនយោបាយរដ្ឋាភិបាលក្នុងការការពារបរិស្ថាន និងធនធានធម្មជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

នៅក្នុងស្មារតីនេះ ខ្ញុំសូមប្រសិទ្ធិពរជ័យដល់ គណៈអធិបតី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ទាំងអស់ ដែលជាភ្ញៀវកត្តិយសជាតិ និងអន្តរជាតិ អោយសំរេចបានលទ្ធផលជាផ្លែផ្កា រួមទាំងមានការរីករាយ និងអនុស្សាវរីយ៍ដ៏ល្អក្នុងការស្នាក់នៅក្នុងទីក្រុងព្រះសីហនុ ។

**ខ្ញុំមានកិត្តិយសសូមប្រកាសបើកសិក្ខាសាលាជាតិលើកទី ៤ ស្តីពីការគ្រប់គ្រងតំបន់ឆ្នេរចាប់ពីពេលនេះតទៅ ។**

សូមអរគុណ

# សិក្ខាសាលាថ្នាក់តំបន់នៅអាស៊ី ស្ដីពី
# ការកសាងសមត្ថភាពសំរាប់យន្តការអភិវឌ្ឍន៍ស្អាត

រៀបចំដោយ វិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី ឧបត្ថម្ភដោយ មជ្ឈមណ្ឌលថាមពល និងបរិស្ថានរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ និង
វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោករបស់ប្រទេសជប៉ុន សហការជាមួយការិយាល័យប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថានកម្ពុជា
២៤-២៦ មីនា ២០០៤ នៅទីក្រុង សៀមរាប កម្ពុជា

## សុន្ទរកថាបើកសិក្ខាសាលារបស់ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថានកម្ពុជា




សូមគោរពបណ្ឌិត អ៊ីយ៉ូកា តំណាងវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក

សូមគោរពលោកបណ្ឌិត លី តំណាងមជ្ឈមណ្ឌលថាមពល និងបរិស្ថានរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ

សូមគោរពលោក វ៉ាម ស្រេស្ថា តំណាងវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី

ឯកឧត្តម លោក លោកស្រី ភ្ញៀវកិត្តិយសជាទីគោរព

ថ្ងៃនេះខ្ញុំមានកិត្តិយស និងសេចក្ដីរីករាយជាខ្លាំង ដោយបានចូលរួមនៅក្នុងពិធីបើកសិក្ខាសាលាថ្នាក់តំបន់អាស៊ី ស្ដីពីការកសាងសមត្ថភាពសំរាប់យន្តការអភិវឌ្ឍន៍ស្អាតនេះ ។ តាងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្ដៅ ចំពោះវត្តមានរបស់លោក លោកស្រី នៅលើទឹកដី សៀមរាបអង្គរ ដែលជាបេះដូងនៃវប្បធម៌ និងអារ្យធម៌ខ្មែរ ។ ខ្ញុំសូមសំដែងនូវអំណរអរគុណដោយស្មោះចំពោះមជ្ឈមណ្ឌលថាមពលនិងបរិស្ថានរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោករបស់ប្រទេសជប៉ុន និងវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី ដែលបានគាំទ្រដល់សិក្ខាសាលាដ៏សំខាន់នេះ ។ យើងក៏មានសេចក្ដីរីករាយ និងស្វាគមន៍លោក លោកស្រី មកពីប្រទេសជាង ១៥ ក្នុងទ្វីបអាស៊ី ជនបង្គោលនៃយន្តការអភិវឌ្ឍន៍ស្អាត

វិស័យឯកជន អង្គការជាតិ និងអន្តរជាតិ ដែលបានមកចូលរួមនៅក្នុងសិក្ខាសាលាដ៏មានសារៈសំខាន់នេះ ។ យើងសូមគាំទ្រយ៉ាងពេញទំហឹងដល់គោលបំនងនៃសិក្ខាសាលានេះ ក្នុងការចែករំលែកបទពិសោធន៍ និងចំណេះដឹងរវាងបណ្តាប្រទេសនានា ក៏ដូចជាការបង្កើតកិច្ចសហប្រតិបត្តិការ ត្បូង-ត្បូង ។

ឯកឧត្តម លោក លោកស្រី

យើងទាំងអស់គ្នាមានការប្តេជ្ញាចិត្តខ្ពស់ ដើម្បីរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងជាសកល ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ។ គឺក្នុងន័យនេះហើយ ដែលយើងបានមកជួបជុំគ្នាក្នុងថ្ងៃនេះ ។ ជាការពិតណាស់ យើងយល់ច្បាស់ពីសារៈសំខាន់នៃការចូលរួមក្នុងការអនុវត្តន៍យន្តការអភិវឌ្ឍន៍ស្អាត ដែលមិនត្រឹមតែអាចជួយកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប៉ុណ្ណោះទេ តែក៏នឹងគាំទ្រដល់ការអភិវឌ្ឍន៍ដោយចីរភាពនៅក្នុងប្រទេសយើងផងដែរ ។ ការអភិវឌ្ឍន៍ដោយចីរភាពជាគន្លឹះសំខាន់ណាស់ សំរាប់រំដោះប្រជាជនយើងឱ្យរួចផុតពីភាពក្រីក្រ សំដៅធានាថា ប្រជាជនយើង ព្រមទាំងកូនចៅជំនាន់ក្រោយអាចរក្សាទ្រទ្រង់ និងលើកកំពស់ការអភិវឌ្ឍន៍ និងគុណភាពជីវភាពរបស់ខ្លួន ។ ការអភិវឌ្ឍន៍ដែលពុំមានការគិតគូរគ្រប់ជ្រុងជ្រោយ អាចនាំទៅរការបំផ្លិចបំផ្លាញពុំអាចជួសជុលបាន សំរាប់កូនចៅជំនាន់ក្រោយ ។ សំរាប់ប្រទេសកម្ពុជា យើងត្រូវតែរក្សាដោយប្រុងប្រយត្ន័នូវតុល្យភាពរវាងតំរូវការផ្នែកសេដ្ឋកិច្ចបច្ចុប្បន្ន ជាមួយនឹងកិច្ចការពារបរិស្ថាន ។

គឺក្នុងន័យនេះហើយ ដែលយន្តការអភិវឌ្ឍន៍ស្អាតមានសារៈសំខាន់យ៉ាងខ្លាំង ។ ជំនួយរបស់បណ្តាប្រទេសរីកចំរើនតាមរយៈពិធីសារក្យូតូអាចមានន័យថា ជាកិច្ចគាំទ្រផ្នែកការផ្ទេរបច្ចេកវិទ្យាស្អាត ការកែលំអធនធានព្រៃឈើ និងគុណភាពបរិស្ថាន ការកែលំអហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការលើកកំពស់ការប្រើប្រាស់ថាមពលនិរន្តរភាព ។ សកម្មភាពទាំងនេះគឺជាផ្នែកមួយនៃបណ្តាអាទិភាពអភិវឌ្ឍន៍របស់យើង ។ ដូច្នេះហើយទើបយើងយល់ថា ចាំបាច់ត្រូវអនុវត្តកិច្ចការទាំងនេះ ក្នុងភាពជាដៃគូរតាមរយៈពិធីសារក្យូតូ ។ ទោះជាយ៉ាងណាក្តី យើងក៏យល់ច្បាស់ដែរពីសារៈសំខាន់ក្នុងការពិនិត្យឱ្យបានច្បាស់លាស់ លើសំណើគំរោងយន្តការអភិវឌ្ឍន៍ស្អាតដែលស្នើឡើង សំដៅធានាថា បណ្តាគំរោងទាំងនោះនឹងជួយកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពិតប្រាកដ ហើយក៏នឹងជួយគាំទ្រដល់គោលដៅអភិវឌ្ឍន៍ដោយចីរភាពរបស់ប្រទេសជាតិផងដែរ ។ យើងសង្ឃឹមថា យន្តការអភិវឌ្ឍន៍ស្អាតនឹងជួយប្រទេសយើងឱ្យផ្លោះរំលងចោលនូវបច្ចេកវិទ្យាចាស់គំរិលដែលបំផ្លាញបរិស្ថាន និងចៀសវាងនូវបណ្តាកំហុសទាំងឡាយក្នុងការអភិវឌ្ឍន៍ ដែលធ្លាប់បានកើតមានរួចមកហើយ នាអតីតកាល ។

ជាការពិត យើងទទួលស្គាល់ថាកម្ពុជាគឺជាប្រទេសតូចមួយ ដែលមានសក្តានុពលតូចផ្នែកយន្តការអភិវឌ្ឍន៍ស្អាត ហើយអាចពុំសូវមានអ្នករៀបចំគំរោងស្នើឡើង ។ យើងក៏យល់ច្បាស់ដែរថា កម្ពុជាស្ថិតនៅពីក្រោយបណ្តាប្រទេសជាច្រើនក្នុងការកំណត់រកគំរោងយន្តការអភិវឌ្ឍន៍ស្អាតនានា ដែលមានសក្តានុពល ។ ហេតុដូច្នេះហើយទើបយើងសូមសំដែងនូវអំណរអរគុណចំពោះការគាំទ្រពីសំណាក់វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក ក៏ដូចជាមជ្ឈមណ្ឌលថាមពល និងបរិស្ថានរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ ក្នុងការជួយយើងឱ្យត្រៀមរៀបចំខ្លួនដើម្បីចូលរួមក្នុងយន្តការអភិវឌ្ឍន៍ស្អាត ដោយសមភាព ។ យើងត្រៀមខ្លួនសហការជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីចាប់យកឱកាសនានាក្រោមយន្តការអភិវឌ្ឍន៍ស្អាត ។

# សុន្ទរកថា
## ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន
## ក្នុងពិធីបើកសិក្ខាសាលាបណ្តុះបណ្តាល ស្តីពី
## " ការរៀបចំគំរូពត៌មានជាតិសំរាប់ការគ្រប់គ្រងសារធាតុគីមី "

**ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៣**

**សណ្ឋាគារ ជូលីណា**




- សូមគោរពឯកឧត្តម អ៊ិត ប្រាំង រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- សូមគោរពឯកឧត្តម តេង ឡៅ អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- សូមគោរពឯកឧត្តម គីម ស៊ីថន អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម
- សូមស្វាគមន៍លោក Craig Boljkovac នាយករងកម្មវិធីគ្រប់គ្រងសារធាតុគីមីនិងសំណល់ នៃវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវសហប្រជាជាតិ UNITAR
- សូមស្វាគមន៍ដល់ឯកឧត្តម លោក លោកស្រី និងតំណាងចូលរួមទាំងអស់ជាទីមេត្រី !

ត្រឹមត្រូវនូវសារធាតុគីមីទាំងនោះ ដើម្បីធានាឱ្យបាននូវគោលបំណងនៃការអភិវឌ្ឍន៍ប្រកបដោយ និរន្តរភាព ការការពារសុខមាលភាព និងបរិស្ថាន ។ ចំនុចផ្តើមដ៏សំខាន់ ដើម្បីឈានទៅសំរេចបាននូវ ការគ្រប់គ្រងសារធាតុគីមីមានលក្ខណៈត្រឹមត្រូវ គឺចាំបាច់ត្រូវមានប្រព័ន្ធពត៌មានរួម ដែលទាក់ទងទៅ នឹងរាល់សកម្មភាពគ្រប់គ្រងសារធាតុគីមីទាំងនោះ ដោយរួមបញ្ចូលនូវទិន្នន័យការផលិតនិងប្រើប្រាស់ និងការវាយតំលៃទៅលើស្ថាប័ន ក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងលក្ខណៈបច្ចេកទេសគ្រប់គ្រង ដែលមាន ឬកំពុងអនុវត្តន៍នៅក្នុងប្រទេស ។

## ឯកឧត្តមគណៈអធិបតី លោក លោកស្រីនិងតំណាងចូលរួមទាំងអស់ជាទីមេត្រី!

សំរាប់កម្ពុជាយើង និន្នាការនៃការប្រើប្រាស់សារធាតុគីមី គឺត្រូវបានកត់សំគាល់ឃើញថាមានការកើនឡើងជាលំដាប់ ពិសេសសារធាតុគីមីសំរាប់បំរើវិស័យកសិកម្ម ឧស្សាហកម្ម និងការប្រើប្រាស់ក្នុងវិស័យផ្សេងៗមួយចំនួនទៀត ។ ទន្ទឹមនោះ ពត៌មានទាក់ទងនឹងសារធាតុគីមីទាំងនោះត្រូវបានគ្រប់គ្រងដោយឡែកៗ ទៅតាមស្ថាប័នទទួលខុសត្រូវនិមួយៗ ដូចជាស្ថាប័នពាក់ព័ន្ធការនាំចូល ការផលិត ការប្រើប្រាស់ និងការបោះបង់ចោល ។ល។ ពោលគឺយើងមានពត៌មានមួយចំនួនធំ តែយើងមិនទាន់បានប្រមូលផ្តុំសំរាប់ចងក្រងជាកំរងពត៌ជាតិរួមនៅឡើយ ។ បច្ចុប្បន្ននេះ ប្រសិនបើគេចង់ដឹងពីពត៌មាននៃការផលិត នាំចូល ប្រើប្រាស់ ឬបោះបង់ចោលនូវសារធាតុគីមី គេត្រូវដើរសាកសួរ និងប្រមូលពី ៧ ទៅ ៨ស្ថាប័ន ទើបអាចទទួលបាននូវពត៌មានទាំងនោះ ។ គោលបំណងនៃ ការប្រមូលផ្តុំចងក្រងនូវកំរងពត៌មានជាតិនេះ គឺមិនសំរាប់តែសំរួលក្នុងការផ្តល់ពត៌មាននោះទេ តែកំរងពត៌មាននេះ នឹងត្រូវប្រើប្រាស់ជាឯកសារគោលសំរាប់ឆ្លុះបង្ហាញពីការគ្រប់គ្រង និងបញ្ហាពាក់ព័ន្ធទាំងឡាយ សំរាប់ឈានទៅធ្វើការកំណត់នូវកម្មវិធី ឬគោលនយោបាយជាតិសំរាប់គ្រប់គ្រងសារធាតុគីមី តាមវិធីសាស្ត្រមួយដែលអាចធានាបាននូវការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព សុវត្ថិភាពសុខភាពសាធារណៈ និងបរិស្ថាន ។

ដោយពិនិត្យឃើញនូវភាពចាំបាច់ នៃកំរងពត៌មានជាតិសំរាប់ការគ្រប់គ្រងសារធាតុគីមីសំរាប់ជាប្រយោជន៍រួមរបស់សង្គមជាតិ ទើបក្រសួងបរិស្ថានបានស្នើសុំទៅ UNEP និង UNITAR ដើម្បីជួយជាបច្ចេកទេសក្នុងការរៀបចំនូវកំរងពត៌មានជាតិនេះ ជាផ្នែកមួយនៃគំរោងរៀបចំផែនការជាតិសំរាប់អនុវត្តន៍អនុសញ្ញា ស្តុកខូម (NIP) ។

ដូចនេះ តាមរយៈសិក្ខាសាលាបណ្តុះបណ្តាលនេះ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម អស់លោក លោកស្រី និងតំណាងចូលរួមទាំងអស់ នឹងទទួលបាននូវបទពិសោធន៍ល្អៗលើ ការគ្រប់គ្រងសារធាតុគីមីប្រកបដោយសុវត្ថិភាព និងពីដំណើរការរៀបចំកំរងពត៌មានជាតិ តាមរយៈ បទបង្ហាញរបស់តំណាងវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវសហប្រជាជាតិ UNITAR និងសូមស្នើឱ្យមានការពិភាក្សាឱ្យបាន

# សុន្ទរកថា

# ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ក្នុងពិធីបើកសិក្ខាសាលា ស្តីពី

## " ការចាប់ផ្តើមគំរោងពង្រឹងសមត្ថភាពរៀបចំផែនការជាតិសំរាប់អនុវត្ត អនុសញ្ញា ស្តុកខូម ស្តីពី សារធាតុបំពុលសរីរាង្គមិនបំបែកធាតុ (POPs) "

ថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០០៣

សណ្ឋាគារ ជូលីណា




**គណៈអធិបតីក្នុងអង្គសិក្ខាសាលា**

**សូមគោរពដល់អង្គសិក្ខាសាលា**

**សូមស្វាគមន៍ដល់ឯកឧត្តម អស់លោក លោកស្រីនិងតំណាងចូលរួមទាំងអស់ជាទីមេត្រី !**

នៅក្នុងទិវាដ៏ប្រសើរនេះ ខ្ញុំមានកិត្តិយសនិងបីតិសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកចូលរួមក្នុងពិធីបើកសិក្ខាសាលា ស្តីពី " ការចាប់ផ្តើមគំរោងពង្រឹងសមត្ថភាពរៀបចំផែនការជាតិសំរាប់អនុវត្តអនុសញ្ញាស្តុកខូម ស្តីពី សារធាតុបំពុលសរីរាង្គមិនបំបែកធាតុ " ។ ឆ្លៀតក្នុងឱកាសនេះ តាងនាមឱ្យក្រសួងបរិស្ថាន

ការផលិត និងការប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់ចំនួន ១២មុខ ដែលមានភាពគ្រោះថ្នាក់ខ្លាំងដល់សុខភាព មនុស្ស សត្វ និងបរិស្ថាន គឺប្រភេទសារធាតុបំពុលសរីរាង្គមិនបំបែកធាតុ (Persistent Organic Pollutants) ។

ឆ្លើយតបទៅនឹងចំណាត់ការរបស់សហគមន៍អន្តរជាតិ ក្នុងការការពារសុខភាពសាធារណៈនិងបរិស្ថាន ឱ្យជៀសផុតពីឥទ្ធិពលគ្រោះថ្នាក់នៃសារធាតុ (POPs) រាជរដ្ឋាភិបាលកម្ពុជាបានសំដែងការគាំទ្រដល់វិធានការនេះ តាមរយៈការចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិ ស្តុកខូម នាថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០០១ និងបានដាក់ស្នើសេចក្តីព្រាងច្បាប់ស្តីពី ការធ្វើសច្ចាប័នលើអនុសញ្ញានេះ ទៅសភាជាតិនាថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៣ ។

ថ្វីត្បិតតែកម្ពុជាយើងមិនមែនជាប្រទេសអ្នកផលិតសារធាតុគីមី និងមិនមែនជាប្រទេសដែលមានតំរូវការខ្ពស់ក្នុងការប្រើប្រាស់សារធាតុគីមីក៏ពិតមែន ប៉ុន្តែ ភាពប្រឈមទៅនឹងការទទួលរងគ្រោះថ្នាក់ដោយការប្រើប្រាស់សារធាតុគីមីមួយចំនួន អាចនឹងមានកំរិតខ្ពស់ដូចគ្នាទៅនឹងប្រទេសដែលមានតំរូវការខ្ពស់ផងដែរ ។ មូលហេតុគឺដោយសារភាពយល់ដឹងរបស់ប្រជាជនយើងពីការប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់ទាំងនោះ គឺនៅមានកំរិតទាប គួបផ្សំនឹងការខ្វះខាតនូវវិធានការគ្រប់គ្រងប្រកបដោយសុវត្ថិភាពបរិស្ថាន ពីចំនុចផ្តើមរហូតដល់ការបោះបង់ចោលនូវសារធាតុគីមីទាំងនោះ ។




**គណៈអធិបតី គ្រៀងកិត្តិយស និងសមាជិកសមាជិកាអង្គសិក្ខាសាលាថតរូបជាអនុស្សាវរីយ៍**

## ឯកឧត្តម អស់លោក លោកស្រី និងតំណាងចូលរួមទាំងអស់ជាទីមេត្រី !

គំរោងពង្រឹងសមត្ថភាពកម្ពុជា ដើម្បីរៀបចំផែនការជាតិសំរាប់អនុវត្តអនុសញ្ញា ស្តុកខូម ក្រោមជំនួយរបស់មូលនិធិបរិស្ថានពិភពលោក (GEF) និងក្រោមកិច្ចសហការបច្ចេកទេសពីកម្មវិធីបរិស្ថានសហប្រជាជាតិ

# សុន្ទរកថា
# របស់ឯកឧត្តម ឆាន់ សាផាន រដ្ឋលេខាធិការក្រសួងបរិស្ថាន
# ក្នុងឱកាសបើកសិក្ខាសាលា ការពិគ្រោះយោបល់លើអនុក្រឹត្យ ស្តីពី
# ការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូសូននៅកម្ពុជា

**រាជធានីភ្នំពេញ ថ្ងៃទី ០៧-០៨ ខែមេសា ឆ្នាំ២០០៤**




*ឯកឧត្តម*

- *អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ជាទីស្នេហា*
- *អស់លោក លោកស្រី អ្នកនាងកញ្ញា ជាទីមេត្រី*

ខ្ញុំមានកិត្តិយស ប្រកបដោយសេចក្តីសោមនស្សរីករាយ ដោយបានចូលរួមជាមួយ ឯកឧត្តម អស់លោក លោកស្រី នៅក្នុងឱកាសបើកសិក្ខាសាលា ការពិគ្រោះយោបល់លើអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូសូននៅកម្ពុជា ។ តាងនាមអោយរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅដល់ភ្ញៀវជាតិ អន្តរជាតិ សិក្ខាកាម មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ មន្ត្រីរាជការក្រសួងបរិស្ថាន និងតំណាងក្រុមហ៊ុនអាជីវកម្ម ដែលបានអញ្ជើញមកចូលរួមក្នុងសិក្ខាសាលាដ៏មានសារៈសំខាន់នេះ ។

*ឯកឧត្តម អស់លោក លោកស្រីជាទីមេត្រី*

មូលដ្ឋានគ្រឹះនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន គឺបំពេញភារកិច្ចស្តារ និងកសាងប្រទេស ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន ។ យើងកំពុងតែបំពេញភារកិច្ចនេះនៅក្នុងយុគសម័យដែលពិភពលោកកំពង់តែមានការយកចិត្តទុកដាក់ អំពីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងសុវត្ថិភាពបរិស្ថាន ។ ក្នុងនោះកិច្ចការពារស្រទាប់អូសូន គឺជាភារកិច្ចមួយដ៏សំខាន់ និងជាបន្ទាន់ផងដែរ ។

រាជរដ្ឋាភិបាលកម្ពុជាមានការប្ដេជ្ញាចិត្តខ្ពស់ ក្នុងការចូលរួមជាមួយសហគមន៍អន្តរជាតិ ដើម្បីខិតខំប្រឹងប្រែងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ទោះបីជាយើងមានបញ្ហាអាទិភាពផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ចជាច្រើនត្រូវដោះស្រាយជាបន្ទាន់ក្ដី ។ ក្នុងនាមជាភាគីហត្ថលេខីនៃអនុសញ្ញាទីក្រុងវីយែន ស្ដីពី កិច្ចការពារស្រទាប់អូសូន និងពិធីសារម៉ុងរ៉េអាល់ ស្ដីពី សារធាតុដែលបំផ្លាញស្រទាប់អូសូន រាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់នូវជំហរយ៉ាងរឹងមាំ ក្នុងការចូលរួមជាមួយបណ្ដាប្រទេសដែលជាសមាជិកទាំងអស់នៅលើពិភពលោក សំដៅលើកកំពស់ការ ថែរក្សាស្រទាប់អូសូនអោយបានល្អ ។

ការអភិវឌ្ឍន៍វិស័យថាមពលប្រកបដោយនិរន្តរភាព ការទប់ស្កាត់ និងការឆ្លើយតបជាបន្ទាន់ទៅនឹងគ្រោះមហន្តរាយបរិស្ថាន ការត្រួតពិនិត្យចរាចរសំណល់គ្រោះថ្នាក់ ការគ្រប់គ្រងប្រកបដោយនិរន្តរភាព ការប្រើប្រាស់ដោយសមហេតុសមផល និងការកាត់បន្ថយនូវសារធាតុដែលបំផ្លាញស្រទាប់អូសូនដូចជា CFCs, Methyl Bromide និង Halons ជាដើម ។ល។ ទាំងអស់នេះគឺជាកត្តារួមគ្នាដែលយើងចាំបាច់ត្រូវតែផ្ដោតអារម្មណ៍យកចិត្តទុកដាក់ទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងទាំងកំរិតអន្តរជាតិ ។ យើងចាត់ទុកអង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ ជាយន្តការយ៉ាងសំខាន់ដែលអាចជួយកម្ពុជាក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមមុខទាំងនេះ ។

ថ្មីៗនេះ ព្រះរាជាណាចក្រកម្ពុជាយើងទើបបានបញ្ចប់ការរៀបចំកម្មវិធីជាតិ និងផែនការគ្រប់គ្រងសារធាតុត្រជាក់ សំរាប់ការអនុវត្តន៍ពិធីសារម៉ុងរ៉េអាល់ សំដៅដឹកនាំនូវការដាក់បញ្ហាបរិស្ថានទៅក្នុងគោលនយោបាយអភិវឌ្ឍន៍ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ការធ្វើសេចក្ដីសំរេចផ្នែកសេដ្ឋកិច្ច និងការធ្វើផែនការវិនិយោគ ។ ថ្ងៃនេះ ដោយមានការឧបត្ថម្ភពីអង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ ទាំងថវិកា និងអ្នកឯកទេស និងការផ្ដល់បទពិសោធន៍ពីប្រទេសជិតខាងយើង ដូចជាប្រទេសថៃ វៀតណាម ឡាវ និងបណ្ដាប្រទេសជាសមាជិកដទៃទៀត ធ្វើអោយព្រះរាជាណាចក្រកម្ពុជាយើងសំរេចបាននូវសេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូសូននៅកម្ពុជា ដែលយើងនឹង ត្រូវលើកយកមកធ្វើការពិភាក្សាគ្នានៅក្នុងអង្គសិក្ខាសាលានេះ ។

ខ្ញុំមានជំនឿជឿជាក់ថា សិក្ខាសាលានេះគឺជាវេទិការដ៏ប្រសើរសំរាប់កិច្ចពិភាក្សាយ៉ាងប្រកដប្រជា និងប្រកបដោយកិច្ចស្ថាបនា ដែលនឹងជំរុញអោយសិក្ខាកាមទាំងអស់ មានស្ថាប័នរដ្ឋ ព្រមទាំងវិស័យឯកជនមានការយល់ដឹងកាន់តែប្រសើរឡើងថែមទៀត ស្ដីអំពីសារធាតុដែលបំផ្លាញស្រទាប់អូសូន និងជាពិសេសអំពីភារកិច្ចរបស់ប្រជាជនយើងទាំងអស់គ្នាក្នុងការជួយទប់ស្កាត់ និងការបន្ថយការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូសូន ។ ខ្ញុំសង្ឃឹមថាសិក្ខាសាលានេះ នឹងផ្ដល់ឱកាសយ៉ាងប្រសើរដល់កម្ពុជា ក្នុងការរៀបចំយុទ្ធសាស្ត្ររបស់ខ្លួនក្នុងការអនុវត្តន៍ពិធីសារម៉ុងរ៉េអាល់ និងអនុសញ្ញាទីក្រុងវីយែន ក៏ដូចជាការកសាងសមត្ថភាពជាតិសំរាប់ការចូលរួមដោយពេញលេញក្នុង

ដំណើរការរបស់ អង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ ។ វត្តមានរបស់យើងថ្ងៃនេះសបញ្ជាក់អោយឃើញនូវការប្តេជ្ញាចិត្តក្នុងការចូលរួមរៀនសូត្រ ព្រមទាំងលើកកំពស់ការពិភាក្សា និងកិច្ចសហប្រតិបត្តការជាមួយអស់លោក លោកស្រី ក៏ដូចជាមួយសហគមន៍អន្តរជាតិ ។ ខ្ញុំសូមអនុញ្ញាតិធ្វើការអះអាងថា ភាគីកម្ពុជានឹងខិតខំធ្វើគ្រប់បែបយ៉ាងសំដៅជំរុញអោយមាន ការចូលរួមពីគ្រប់ស្ថាប័ននៅក្នុងសកម្មភាពនានា ដែលនឹងរួមចំណែកក្នុងកិច្ចការពារស្រទាប់អូសូន ក៏ដូចជាបញ្ហា បរិស្ថានពិភពលោក ។



ទិដ្ឋភាពរួមនៃការធ្វើបទបង្ហាញ និងការធ្វើបទអន្តរាគមន៍

ខ្ញុំសូមថ្លែងអណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីក្រសួងបរិស្ថាន ដែលបានខិតខំប្រឹងប្រែងរៀបចំសិក្ខាសាលានេះឡើង ។ ខ្ញុំក៏សូមអរគុណចំពោះមន្ត្រីរាជការមកពី ក្រសួង-ស្ថាប័ននានា ព្រមទាំងអស់លោក លោកស្រី តំណាងអោយក្រុមហ៊ុនឯកជន ដែលបានអញ្ជើញមកចូលរួមនៅក្នុងសិក្ខាសាលា ដ៏សំខាន់នេះ ។

ជាទីបញ្ចប់ តាងនាមអោយថ្នាក់ដឹកនាំទាំងអស់របស់ក្រសួងបរិស្ថាន និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណសារជាថ្មីម្តងទៀតដល់ ឯកឧត្តម អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតំលៃ មកចូលរួមក្នុងសិក្ខាសាលានេះ និងសូមជូនពរដល់ ឯកឧត្តម អស់លោក លោកស្រី ទាំងអស់ នូវពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបើកសិក្ខាសាលាចាប់ពីពេលនេះតទៅ ។

**សូមអរគុណ**

# សកម្មភាពសំខាន់ៗរបស់ថ្នាក់ដឹកនាំ ក្រសួងបរិស្ថាន ក្នុងបុព្វហេតុគាំពារ ការពារ និង អភិរក្សបរិស្ថាន




ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារេត រដ្ឋមន្ត្រីក្រសួងបរិស្ថានដឹកនាំគណៈប្រតិភូកម្ពុជា
ទៅចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីបរិស្ថាន សេដ្ឋកិច្ច ហិរញ្ញវត្ថុស្តីពីការអភិវឌ្ឍន៍
ដោយចីរភាព រៀបចំដោយអង្គការប្រជាជាតិ CSD-12 នៅទីស្នាក់ការ
កណ្តាលអង្គការសហប្រជាជាតិ នាទីក្រុងញ៉ូវយ៉កសហរដ្ឋអាមេរិច
ពីថ្ងៃទី ២៨ ដល់ ៣០ មេសា ឆ្នាំ២០០៤

# បេសកកម្មនៅព្រះរាជាណាចក្រជប៉ុន




ឯកឧត្តមបណ្ឌិត ម៉ុក មារ៉េត ក្នុងសន្និសីទបរិស្ថានសំរាប់បណ្តាលប្រទេសក្នុងតំបន់អាស៊ី ប៉ាស៊ីភិច លើកទី១២នៅប្រទេសជប៉ុន



ឯកឧត្តមរដ្ឋមន្ត្រីអញ្ជើញធ្វើទស្សនកិច្ចសិក្សាស្វែងយល់ខ្សែសង្វាក់ផលិតកម្មកែឆ្នៃសំណល់របស់ក្រុមហ៊ុនសាជីវកម្ម មីស៊ូអ៊ិប៊ុសាន នៅប្រទេសជប៉ុន



ក្នុងដំណើរទស្សនកិច្ចខ្សែសង្វាក់ផលិតកម្មកែឆ្នៃសំណល់ឧបករណ៍អគ្គិសនីនៅក្រុមហ៊ុន MITSUI BUSSAN ឯកឧត្តមរដ្ឋមន្ត្រីបានផ្តល់បទសំភាសន៍ដល់អ្នកសារពត៌មានជប៉ុន

# ពិធីទទួលបដិសណ្ឋារកិច្ច និងជួបពិភាក្សាការងារជាមួយប្រតិភូអន្តរជាតិ

ឯកឧត្តមរដ្ឋមន្ត្រី និងមន្ត្រីជំនាញ នាយកដ្ឋានត្រួតពិនិត្យការបំពុល ជួបពិភាក្សាការងារជាមួយ [illegible] សំណល់គ្រោះថ្នាក់ ។





ឯកឧត្តមរដ្ឋមន្ត្រី និងមន្ត្រីជំនាញ នាយកដ្ឋាន EIA ជួបពិគ្រោះយោបល់ជាមួយអ្នកជំនាញការជប៉ុនអំពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា ។

ឯកឧត្តមរដ្ឋមន្ត្រី និងមន្ត្រីជំនាញនាយកដ្ឋាន គ្រប់គ្រងធនធានធម្មជាតិ ជួបពិភាក្សាការងារជាមួយមន្ត្រីអ្នកជំនាញការ FFI និងប្តូរយោបល់ពិភាក្សាគ្នាក្នុងកិច្ចអភិរក្សសត្វ និងរុក្ខជាតិព្រៃ (FLORA AND FAUNA)



# បេសកកម្មនៅខេត្តព្រះវិហារ

ឯកឧត្តមរដ្ឋមន្ត្រីអញ្ជើញ
ជាអធិបតីក្នុងឱកាស
ប្រកាសបង្កើត
ប្រជាសហគមន៍ព្រៃឈើ
នៅតំបន់ការពារធម្មជាតិ
ត្នាតប៉ើយជឿនក្រសាំង





ឯកឧត្តមពិនិត្យផែនទីភូមិ
សាស្ត្រព្រៃសហគមន៍

ក្រុមឧទ្យានុរក្ស
និងប្រជាសហគមន៍
ចូលរួមក្នុងការប្រារព្ធពិធី



# បេសកកម្មនៅខេត្តក្រចេះ



ឯកឧត្តមរដ្ឋមន្ត្រីបានប្រគល់ម៉ូតូ HONDA មួយគ្រឿង ប្រើប្រាស់ជាផលប្រយោជន៍រួមដល់ប្រធានសហគមន៍ និងចែកអំណោយដល់សមាជិកប្រជាសហគមន៍ ដែនជំរកសត្វព្រៃ ស្រុកស្នួល ខេត្តក្រចេះ



ឯកឧត្តមរដ្ឋមន្ត្រីចុះសួរសុខទុក្ខ ប្រជាសហគមន៍ព្រៃឈើនៅដែនជំរកសត្វព្រៃ ស្រុកស្នួលតាមលំនៅដ្ឋាន



ប្រជាសហគមន៍ព្រៃឈើ ចូលរួមស្ដាប់មតិណែនាំ របស់ឯកឧត្តមរដ្ឋមន្ត្រីពី អត្ថប្រយោជន៍នៃការ បង្កើតសហគមន៍ព្រៃឈើ

# កំណាព្យ

## សីល ៥



### រឿងសីល ៥

ព្រះពុទ្ធទ្រង់ផ្ដាំ    ធ្វើចិត្តអោយស្អាត    *ទី ១ហៅថា*
បាណាតិបាទ    ហាមឃាត់ដាច់ខាត    កុំសម្លាប់សត្វ ។
*ទី ២ អទិន្នា*
យើងទាំងអស់គ្នា    ត្រូវចេះអារកាត់    កុំលួចទ្រព្យគេ
អោយប្រុងប្រយ័ត្ន    ក្រែងមានវិបត្តិ    ជិតដល់ខ្លួនយើង ។
*ទី ៣ កាមេ*
ទាំងយើងទាំងគេ    កុំជេងចចើង    ប្រពន្ធប្ដីគេ
ទាបថោកមិនថ្កើង    ត្រូវលះវៀរឡើង    កុំយកខ្លួនបៀត ។
*ទី ៤ មុសា*
ព្រះពុទ្ធហាមថា    ធមិមុសាវាទ    កុំភូតកុហក
ប្រវ័ញ្ចមិត្តញាតិ    ធ្វើអោយឃ្លៀងឃ្លាត    អស់ទ្រព្យសម្បត្តិ ។
*ទី ៥ សុរា*
ចុងក្រោយហាមថា    អោយប្រុងប្រយ័ត្ន    កុំសេពសុរា
មេរ៉ៃវិបត្តិ    ត្រូវចេះដុសខាត់    រក្សាសីល៥ ។
បើយើងរក្សា
សីល៥ជាប់ណា    នោះត្រូវចងចាំ    ថាយើងស្លាប់ទៅ
មិនមានសាំញ៉ាំ    អ្នកជាប់សីល៥    ទៅកើតឋានសួគ៌
បើមិនទាន់ស្លាប់
ទំនាយទាយប្រាប់    ថាយើងជាតួ    ព្រះបាទធម្មិក
មានបុណ្យគាប់គួរ    ជ្រកក្រោមម្លប់ពោធិ៍    រួចផុតចាកទុក្ខ ។
ដូច្នេះត្រូវតែ
ក្មេងចាស់ជាតិខ្មែរ    បើចង់បានសុខ    រក្សាសីលប្រាំ
នាំយើងទៅមុខ    ស្ថានសួគ៌ស្ថានសុខ    បើកទ្វារចាំយើង ។

*(ដកស្រង់ចេញពីឯកសារ មជ្ឈមណ្ឌលធម្មយាត្រា នៃសម្ដេចព្រះមហាឃោសានន្ទ ដើម្បីសន្តិភាព និងអហឹង្សា)*

ពិនិត្យដោយសម្ដេច **ព្រះមហាឃោសានន្ទ**
និពន្ធដោយលោក **ស៊ុន គឹមសឿន**

## កំប្លែងបរិស្ថាន

# ចាំស្លាយហើយសិន !!!

ពូផ្លួយតែងខ្ជះខ្ជាយថវិកា ដែលខិតខំបង្ករពៀសឈាមរកបានមកអោយស្រាពង្វក់ស្មារតី **រាល់ថ្ងៃ ហើយ**តែងបង្កទំនាស់ក្នុងគ្រួសារ ដោយប្រពន្ធគាត់ខ្វាយខ្វល់ក្នុងការខិតខំសន្សំសំចៃ **ប្រាក់ផ្គត់ផ្គង់លុយ**កាក់អោយកូនទៅរៀនសូត្រដើម្បីមានចំណេះដឹងដូចកូនគេនៅក្បែរខាង ។

**ប៉ុន្តែ**ក្រោយមក ដោយការព្យាយាមណែនាំរបស់ប្រពន្ធ និងយល់ពីកំហុសរបស់ខ្លួន **ពូផ្លួយបាន**កែប្រែ ឥរិយាបថបជាមនុស្សលែងឱ្យស្រាដឹកមុខ ហើយខិតខំធ្វើការដូចគេឯង ។

ថ្ងៃមួយពូផ្លួយទៅចំការធ្វើការដូចសព្វដង ។ ប្រពន្ធឃើញប្ដីខិតខំធ្វើការនឿយហត់ ហើយថ្ងូរថាឈឺខ្នងឈឺចង្កេះ ក៏ទៅទិញស្រាថ្នាំប៉ូវសរសៃមួយដបទុកអោយប្ដី ។

ដល់ពេលបាយថ្ងៃត្រង់ ប្ដីក៏ត្រលប់មកផ្ទះវិញ ។ ពេលនោះ...........

**ប្ដី** : *នែម៉ែវា.............បានម្ហូបអីហូបបាយថ្ងៃត្រង់នេះ...............?*

**ប្រពន្ធ** : *អូ.......ឪវា......ទៅមុជទឹកអោយស្អាតខ្លួនសិនទៅចាំដាក់មួយហើយហូបបាយជុំគ្នា.........ហើយថ្ងៃនេះកូនយើងទៅលេងផ្ទះតាយាយវាអស់ហើយ ។.........ថ្ងៃនេះខ្ញុំបានស្លម្ជូរត្រកួនកូនត្រីជញ្ជាត់ និងធ្វើប្រហុកកប់ណោឪវា..........!*

**ប្ដី** : *ប្រាកដជាបានឆ្ងាញ់មាត់ហើយថ្ងៃនេះ........... ។*

ពេលប្ដីមុជទឹកជូតខ្លួនហើយ.......

**ប្រពន្ធ** : *នែឪវា..........ដាក់មួយសិនឬ..........?*

**ប្ដី** : *ចាំខ្ញុំហូបបាយរួចសិន..........ចាំដាក់មួយ ព្រោះឥឡូវនេះខ្ញុំហេវញ៉ូវខ្លួន...........អស់កម្លាំងណាស់ ។*

ប្ដីប្រពន្ធនាំគ្នាហូបបាយជុំគ្នាហើយសំណេះសំណាលពីនេះពីនោះ ។ ពេលហូបបាយហើយប្រពន្ធក៏ក្រោកទៅ យកដបស្រានិងកូនកែវមកហុចឱ្យប្ដីដើម្បីឱ្យប្ដីដាក់មួយបំបាត់ការឈឺខ្នងចង្កេះ....... ។

ពេលនោះ.............

**ប្ដី** : *អូស្រាទេ......ខ្ញុំស្មានតែដាក់មួយ........ដាក់ស៊ិៗគេនោះ.........បើដឹង**អញ្ចឹង**ខ្ញុំដាក់តាំងពីមុនហូបបាយម្ល៉េះ.........ដើម្បីអោយកាន់តែឆ្ងាញ់បាយ......... ។*

**ប្រពន្ធ** : *នែឪវា.......ឪវាស្មានតែដាក់ស៊ី...........តែផ្កាស់ !!!*

**ដោយនាយឃ្លេ**

ការអភិវឌ្ឍន៍ដោយចិរន្តរភាព
បរិស្ថានរួមមានវិសាល
ភាពបីគឺ: សេដ្ឋកិច្ច
អេកូឡូស៊ី និង សង្គម

SUSTAINABLE DEVELOPMENT COMPRISES THREE DIMENSIONS: ECONOMIC , ECOLOGY AND SOCIAL





ភពផែនដី និង ព្រៃឈើ
សំរាប់មនុស្សជំនាន់មុន
ជំនាន់បច្ចុប្បន្ន និង
មនុស្សជំនាន់ក្រោយ

THE EARTH AND FOREST ARE FOR PAST , PRESENT AND FUTURE GENERATION

រស់នៅលើភពផែនដីបាន
អាស្រ័យដោយបរិស្ថាន
ស្អាត និង បរិស្ថាន
ប្រកបដោយផាសុកភាព

LIFE ON EARTH DEPENDS ON CLEAN AND HEALTHY
ENT



